ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- កេរដំណែលរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់ មកពីស្រុកកំពង់សៀមទទួលការពិនិត្យសុខភាពដោយឥតគិតថ្លៃ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៣ ខែកញ្ញា ឆ្នាំ២០២២

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៣ ខែកញ្ញា ឆ្នាំ២០២២



សាធារណជនមកស្ដាប់សវនាការកាត់ទោស ខៀវ សំផន នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ កេរដំណែលរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា៖ អ៊ុនតាក់ ................ ១
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម...... ៤

### ផ្នែកឯកសារ

◆ ដៅ វេង ស្រី ៖ យុទ្ធជនបច្ចេកទេសជួសជុលម៉ាស៊ីនតំបន់៥ ភូមិភាគពាយ័ព្យ............. ៨

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ទូទ័ល សាវ៉ស់៖ អ្នកត្បាញក្រមាឲ្យអង្គការ... ១៧
◆ យ៉ុន យ៉ាង ៖ កងនេសាទ .................. ១៤
◆ ខ្ញុំវិលត្រឡប់មកស្រុកកំណើតវិញ......... ១៦
◆ ស្រេង ហុងគាវ៖ កងកុមារផលិតជី....... ១៨
◆ ហេម ហ៊ីន៖ អតីតពេទ្យសម័យខ្មែរក្រហម... ២០
◆ មាឃ ទូច៖ ខ្ញុំរស់នៅទាំងភ័យខ្លាច ....... ២២
◆ ទីន ញ៉ី ៖ អតីតកងចល័តវ័យកណ្ដាល ... ២៤
◆ ប្រាក់ តាំង ៖ អតីតកងចល័តនៅភូមិ ...... ២៦
◆ គៀម ជន៖ កងកុមារក្នុងរបបខ្មែរក្រហម .. ២៨
◆ ង្វួន ខេន ៖ ខ្មែរក្រហមបានអូសទាញ...... ៣០
◆ មាស វេន៖ កម្មករនៅឃ្លាំងរដ្ឋជ្រោយ... ៣២

### ផ្នែក វេទិកាពិភាក្សាសាធារណៈ

◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនកិច្ច.................................. ៣៥
◆ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនកិច្ចសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ........... ៣៧
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ចាម ចូលរួមស្ដាប់និងទស្សនាការប្រកាសសាលដីកា ខៀវ សំផន .................... ៣៩
◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិព្រៃតាម៉ៅ ................. ៤១
◆ យុវជន-យុវនារី១៥នាក់មកពីសហគមន៍ជនជាតិចាមនៅស្រុកត្បូងឃ្មុំ.............. ៤៣
◆ យុវជនមកពីស្រុកប៉ាធាយ ខេត្តកំពង់ចាមចូលរួមវេទិកាអន្តរជំនាន់ចុងសប្ដាហ៍ស្ដីពី ..... ៤៧
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តត្បូងឃ្មុំទៅពិនិត្យសុខភាព........... ៥០
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់ មកពីស្រុកកំពង់សៀម ..... ៥៤

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ នៅសល់តែប្រវត្តិរូប និងរូបថត........... ៥៧
◆ **«ធ្នូលពិឃាដ» (ត)**
កងចល័តកុមារ (ត) ........................ ៦៤

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, មីន សាណាស់, ភា រស្មី, អេង វណ្ណីកា, ហ៊ាន ពិសី, ឈុំ ង៉ា, យន់ ឃីម, មឿន ហាច, សួត វិចិត្រ, ផេង ពង្សរ៉ាស៊ី, ជុន ស្រីពេជ្រ, ទូច វណ្ណេត, ង៉ាន់ វីន, គាត ស្រីឡែន, វី ស៊ីថា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុកភីង និង ដ័យ ចាន់ស៊ីណែត **និពន្ធនាយករងទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# កេរដំណែលរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា៖ អ៊ុនតាក់, សាលាក្តីខ្មែរក្រហម និង ការអប់រំដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

*ខណៈពេលដែលសាលាក្តីខ្មែរក្រហមឈានមកដល់ទីបញ្ចប់ ការអប់រំ គឺជាជំហានបន្ទាប់ឈាន ទៅកាន់ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ*

**ឆាំង យុ**




*សិក្ខាសាលាស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ តាមរយៈការអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រៀបចំឡើងនៅក្នុងទីក្រុងបាងកក ប្រទេសថៃ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការិយាល័យទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពាររបស់អង្គការសហប្រជាជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មជ្ឈមណ្ឌលឯកសារកម្ពុជារួមសហការជាមួយនឹងការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍មានមោទកភាពក្នុងការបិទបញ្ចប់ផ្នែកចុងក្រោយនៃកម្មវិធីបណ្តុះបណ្តាលបីជំហាន ស្តីអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅតាមរយៈការអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ សិក្ខាសាលារយៈពេលបីថ្ងៃនេះ គឺជាផ្នែកទីបីនៃកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់ ដែលត្រូវបង្កើតឡើងក្នុងគោលបំណងបំពេញបន្ថែមនូវតម្រូវការក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ស្តីអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ដល់បុគ្គលិកផ្នែកអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ លោកគ្រូ-អ្នកគ្រូកម្រិតវិទ្យាល័យ និងមន្ត្រីរដ្ឋាភិបាលទទួលបន្ទុកផ្នែកអប់រំ ចំនួន២០រូប អញ្ជើញមកពីប្រទេសវៀតណាម, ប្រទេសថៃ និង

ប្រទេសកម្ពុជា ទទួលបានចំណេះដឹង និងបានចែករំលែកការយល់ឃើញផ្សេងៗ ស្តីពីវិធីសាស្ត្រក្នុងការដាក់បញ្ចូលការអប់រំស្តីពីឧក្រិដ្ឋកម្មឃោរឃៅទៅក្នុងកម្មវិធីសិក្សានៅតាមបណ្តាប្រព័ន្ធអប់រំ ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល។ បន្ថែមពីលើការទទួលបានការបណ្តុះបណ្តាលអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ បុគ្គលិកផ្នែកអប់រំទាំងអស់ខាងលើ ក៏ទទួលបានវិធីសាស្ត្របង្រៀន ព្រមទាំងអនុវត្តដោយផ្ទាល់លើរបៀបបង្រៀន និងបណ្តុះបណ្តាលដល់គ្រូដទៃទៀត។ នេះគឺជាគំរូនៃកម្មវិធីសិក្សាតាមបែបផែននៃការបណ្តុះបណ្តាលដើម្បីបណ្តុះបណ្តាលបន្ត។

ផ្នែកទីមួយនៃកម្មវិធីបណ្តុះបណ្តាលបីដំណាក់កាលនេះ រួមបញ្ចូលនូវសិក្ខាសាលារយៈពេល៦ម៉ោង តាមប្រព័ន្ធអនឡាញ ដែលផ្តល់ជូនបុគ្គលិកអប់រំនូវសេចក្តីផ្តើមនៃនិយមន័យផ្លូវច្បាប់ដែលទទួលស្គាល់ជាអន្តរជាតិ ចំពោះឧក្រិដ្ឋកម្មឃោរឃៅ និងកត្តាហានិភ័យពាក់ព័ន្ធជុំវិញឧក្រិដ្ឋកម្មទាំងនេះ ដូចដែលបានចែងនៅក្នុង «ក្របខណ្ឌនៃការវិភាគរបស់អង្គការសហប្រជាជាតិចំពោះឧក្រិដ្ឋកម្មឃោរឃៅ៖ ឧបករណ៍សម្រាប់ទប់ស្កាត់»។ ផ្នែកទីពីរនៃកម្មវិធីរួមបញ្ចូលសិក្ខាសាលាកូនកាត់រយៈពេលបីថ្ងៃ (ពាក់កណ្តាលអនឡាញនិងដោយផ្ទាល់) ដែលផ្តល់ជូនអ្នកចូលរួមនូវការយល់ដឹងជាសកលទូលំទូលាយជាងមុនអំពីឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រវត្តិសាស្ត្រ ក៏ដូចជាការបន្សាំខ្លួនទៅនឹងវិធីសាស្ត្របង្រៀន, មេរៀន និងសម្ភារឧបទេសបែបស៊ីជម្រៅពាក់ព័ន្ធនឹងការបង្រៀនប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មឃោរឃៅ ដោយផ្តោតទៅលើប្រវត្តិសាស្ត្ររបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ ផ្នែកទីបីនៃវគ្គបណ្តុះបណ្តាល ដែលប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី១៦ដល់១៨ ខែកញ្ញាកន្លងទៅ ដោយផ្តោតទៅលើការហ្វឹកហាត់ទៅលើលំហាត់គោល ដែលអ្នកចូលរួមត្រូវបានតម្រូវឲ្យបង្កើតនិងធ្វើបទបង្ហាញលើកិច្ចតែងការបង្រៀនអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនានា ដែលអាចដាក់បញ្ចូលទៅក្នុងប្រព័ន្ធអប់រំតាមបណ្តាសាលារៀនក្នុងប្រទេសរបស់ខ្លួន។ ប្រធានការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ លោកស្រី អាលីស វ៉ៃរីមូ អេនដេរីធូ (Alice Wairimu Nderitu) បានថ្លែងសុន្ទរកថាបើកសិក្ខាសិលាតាមប្រព័ន្ធអនឡាញ បន្ទាប់មកលោកស្រី ម៉ារៀ វេស្ទើហ្គ្រេន (Maria Westergren) អ្នកតំណាងការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដែលបានអញ្ជើញចូលរួមសិក្ខាសាលារយៈពេលបីថ្ងៃនេះដោយផ្ទាល់ បានថ្លែងសុន្ទរកថាបិទបញ្ចប់សិក្ខាសាលានេះ។

ការបង្កើតកម្មវិធីបណ្តុះបណ្តាលនេះឡើង ស្ថិតនៅចំពេលវេលាដ៏សំខាន់បំផុត ស្របពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្កើតឡើងរួមគ្នាដោយកម្ពុជា និងអង្គការសហប្រជាជាតិ



សិក្ខាសាលាស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ តាមរយៈការអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រៀបចំឡើងនៅក្នុងទីក្រុងបាងកក ប្រទេសថៃ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការិយាល័យទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពាររបស់អង្គការសហប្រជាជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




សិក្ខាសាលាស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ តាមរយៈការអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រៀបចំឡើងនៅក្នុងទីក្រុងបាងកក ប្រទេសថៃ ដោយមជ្ឈ-មណ្ឌលឯកសារកម្ពុជា និងការិយាល័យប្រឹក្សាពិសេសនៃអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការិយាល័យទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពាររបស់អង្គការសហប្រជាជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ដែលត្រូវបានស្គាល់ថាជា សាលាក្តីខ្មែរក្រហម កំពុងរៀបចំប្រកាសសេចក្តីសម្រេចចុងក្រោយចំពោះបណ្តឹងសារទុករបស់ ខៀវ សំផន។ សេចក្តីសម្រេចនេះគឺជាការបិទបញ្ចប់ប្រកបដោយប្រសិទ្ធភាពលើការងាររបស់តុលាការនេះ។ អង្គការសហប្រជាជាតិមានប្រវត្តិសាវតារដ៏យូរលង់នៃការបំពេញការងារសំខាន់ៗជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាពិសេសនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិ បានស្រវាស្រទេញក្នុងការជំរុញឲ្យខ្មែរក្រហមចូលរួមនៅក្នុងការបោះឆ្នោតតាមបែបផែនប្រជាធិបតេយ្យ ដើម្បីសម្រេចបាននូវដំណោះស្រាយសន្តិភាពចំពោះសង្គ្រាមរ៉ាំរ៉ៃជាងមួយទសវត្សរ៍។ ទោះបីជាយ៉ាងណាក្តី ខ្មែរក្រហមនៅតែរឹងទទឹងក្នុងការបន្តជាសង្គ្រាមតាមគ្រប់រូបភាព។ អង្គការសហប្រជាជាតិមិនធ្លាប់បោះបង់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ចំពោះការគាំពារដល់សន្តិភាពនៅក្នុងប្រទេសកម្ពុជាឡើយ ហើយការប្តេជ្ញាចិត្តនេះ បានវិវឌ្ឍទៅជាដំណើរស្វែងរកយុត្តិធម៌ដែលប្រព្រឹត្តទៅតាមរយៈការងាររបស់សាលាក្តីខ្មែរក្រហម។ ខណៈពេលដែលសាលាក្តីខ្មែរក្រហមឈានមកដល់ទីបញ្ចប់ នៅក្នុងកាលៈទេសៈជាច្រើនការបង្កើតជាកម្មវិធីអប់រំពីឧក្រិដ្ឋកម្មឃោរឃៅ គឺជាសក្តិភាពនៃការវិវឌ្ឍទៅមុខដ៏សមស្រប ឆ្លើយតបនិងលើកឡើងអំពីឧក្រិដ្ឋកម្មឃោរឃៅ តាមរយៈកិច្ចខិតខំប្រឹងប្រែងនានាក្នុងគោលដៅទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះពីការកើតមានឡើងវិញ។

ចាប់តាំងពីការរៀបចំការបោះឆ្នោតស្ថិតក្រោមការគាំពារពី អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) និងការបង្កើតជាសាលាក្តីខ្មែរក្រហម អង្គការសហប្រជាជាតិ តែងតែជាដៃគូឈានមុខ និងជាភាគីពាក់ព័ន្ធដ៏សំខាន់របស់ប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍ ក្នុងដំណើរពុះពារដ៏យូរអង្វែងប្រឈមទៅនឹងឥទ្ធិពលបន្សល់ទុកពីរបបខ្មែរក្រហម។ កម្មវិធីបណ្តុះបណ្តាលនេះ គឺជាសំអាងនៃជំហានបន្ទាប់ឈានទៅមុខដ៏វិសេសវិសាលនៅក្នុងកេរដំណែលរបស់អង្គការសហប្រជាជាតិចំពោះយុត្តិធម៌អន្តរកាលក្រោយជម្លោះនៅក្នុងតំបន់។ ការក្រេបយកចំណេះដឹងពីមេរៀនក្នុងរបបខ្មែរក្រហម និងការដាក់បញ្ចូលចំណេះដឹងទាំងនេះទៅក្នុងកម្មវិធីសិក្សាទូលំទូលាយជាងមុន ស្តីពីឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រវត្តិសាស្ត្រ សបញ្ជាក់អំពីជំហានឆ្ពោះទៅមុខរបស់សហគមន៍អន្តរជាតិក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ ទាំងនេះពីការកកើតឡើងវិញ។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ឆាំង យុ



*រូបទី១រាប់ពីឆ្វេង៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា, រូបទី២រាប់ពីឆ្វេង៖ វ៉ន វេត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច, រូបទី៣រាប់ពីឆ្វេង ៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ, រូបទី៤រាប់ពីឆ្វេង ៖ តា ម៉ុក លេខាភូមិភាគនិរតី, រូបទី៥រាប់ពីឆ្វេង (អង្គុយពីក្រោយ តាម៉ុក) ៖ ចេង អន ប្រធានគណៈកម្មាធិការឧស្សាហកម្ម, រូបទី១រាប់ពីស្តាំ ៖ កែ ពក លេខាភូមិភាគឧត្តរ (ភូមិភាគកណ្តាល), រូបទី២រាប់ពីស្តាំ ៖ ជូ ជេត លេខាភូមិភាគបស្ចិម, រូបទី៣រាប់ពីស្តាំទី ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អស់រយៈកាលជាងពីរទសវត្សរ៍មកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការស្ទង់មតិអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីបង្កើនការយល់ដឹងកាន់តែប្រសើរឡើងអំពីតម្រូវការចំណាប់អារម្មណ៍ និងទស្សនយល់ឃើញរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សូមអរគុណចំពោះជំនួយសប្បុរសពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ កាលពីខែសីហា ឆ្នាំ ២០២១ ដែលបង្កលក្ខណៈឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាពង្រីកកិច្ចខិតខំប្រឹងប្រែងយ៉ាងសំខាន់របស់ខ្លួន ក្នុងការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេស ទាក់ទងនឹងការអភិវឌ្ឍការយល់ដឹងឲ្យកាន់តែប្រសើរឡើងអំពីស្ថានភាពសុខភាព និងសុខុមាលភាពរបស់អ្នករស់រាន

មានជីវិតពីរបបខ្មែរក្រហម។ គិតត្រឹមខែសីហា ឆ្នាំ២០២២នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលព័ត៌មានពីអ្នករស់រានមានជីវិតពីខ្មែរក្រហមច្រើនជាង៣ម៉ឺននាក់។ ខាងក្រោមនេះបង្ហាញអំពីការសង្កេតបឋមមួយចំនួនដែលប្រមូលបានពីការងារនេះ។

ប្រហែលជាគ្មានអ្វីចម្លែកទេ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនដែលបានចូលរួមក្នុងការស្ទង់មតិ លើកឡើងពីកត្តាហិរញ្ញវត្ថុជាបញ្ហាប្រឈមចម្បង ក្នុងការសម្រេចចិត្តមិនស្វែងរកការព្យាបាល ផ្នែកសុខភាពផ្លូវចិត្តឬរាងកាយ ពិការភាពឬជំងឺផ្សេងៗរបស់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរកឃើញបន្ថែមទៀតថា ក្នុងចំណោមស្ថានភាពសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្តដកស្រង់ចេញពីការស្ទាប់ស្ទង់មតិអ្នករស់រានមានជីវិតខ្មែរក្រហមបានបង្ហាញថា ជំងឺលើសឈាម និងជំងឺក្រពះពោះវៀន បន្ទាប់មកលំដាប់ដោយជំងឺគ្រុនចាញ់ ជំងឺផ្លូវចិត្ត និងជំងឺបេះដូង គឺជាកត្តាដ៏គួរឲ្យព្រួយបារម្ភបំផុត និងជាកត្តាធ្វើឲ្យស្ថានភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចុះខ្សោយ។ ខណៈដែល មជ្ឈមណ្ឌលឯកសារកម្ពុជា មានការងារជាច្រើនទៀតដែលត្រូវធ្វើក្នុងការអភិវឌ្ឍការយល់ដឹងអំពីបញ្ហាសុខភាពទាំងនេះ គឺគួរឲ្យកត់សម្គាល់ថា ស្ថានភាពទាំងនេះស្របគ្នានឹងការសង្កេតបឋមលើការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការស្ទាបស្ទង់មតិចំនួន៨៧ភាគរយបង្ហាញថាមានផលលំបាកនៅតែនឹកតែនឹកឃើញអំពីបទពិសោធន៍ដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដល់បច្ចុប្បន្ន។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ២៥ភាគរយទៀត លើកឡើងថាខ្លួននៅតែយល់សុបិន្តអាក្រក់នៃរឿងរ៉ាវដែលជួបប្រទះក្នុងសម័យខ្មែរក្រហម បើទោះបីជារបបខ្មែរក្រហមបានបញ្ចប់ជាងសែសិបឆ្នាំកន្លងមកក៏ដោយ។

ចុងក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជ្រើសរើសការប្រើប្រាស់ថ្នាំពេទ្យជាវិធីសាស្ត្រចម្បងសម្រាប់ព្យាបាលជំងឺប្រចាំកាយ ឬបញ្ហាសុខភាពណាមួយដែលកើតឡើងមិនបានត្រៀងទុក



រូបទី១រាប់ពីឆ្វេង ៖ ខៀវ សំផន, រូបអង្គុយកៅអីខាងក្រោយទី១ ៖ ឈ្មោះ លាវ កងការពារ អៀង សារី, រូបអង្គុយកៅអីខាងក្រោយទី២៖ ឈ្មោះ កៀម កងការពារ ខៀវ សំផន, រូបអង្គុយកៅអីជាប់ដើមឈើ៖ មី ម៉ាន់, រូបអង្គុយកៅអីខាងស្តាំមុខគេ៖ អៀង សារី, រូបអង្គុយកៅអីជួរទី២ខាងស្តាំ ៖ ជួន ជុំ, រូបអង្គុយកៅអីជួរទី២កណ្តាល៖ ជួន មុម្ម, រូបអង្គុយកៅអីជួរទី២ខាងឆ្វេង៖ គាត ឈន់ ថតនៅម៉ាឡៃអំឡុងឆ្នាំ១៩៨០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបទី១រាប់ពីឆ្វេង៖ សុន សេនឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ, រូបទី២រាប់ពីឆ្វេង៖ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ, រូបទី៣រាប់ពីឆ្វេង៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា, រូបទី៤រាប់ពីឆ្វេង ៖ ប៉ុល ពត លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ, រូបទី៥រាប់ពីឆ្វេង ៖ យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ, រូបទី៦រាប់ពីឆ្វេង៖ មាន សុភី ប្រពន្ធទី២របស់ ប៉ុល ពត, រូបទី៧រាប់ពីឆ្វេង ៖ ស ផត្ថតា កូនស្រីរបស់ ប៉ុល ពត, រូបទី៩រាប់ពីឆ្វេង ៖ នូវណ្ណា ប្រពន្ធរបស់ តូច ខាំឌឿនៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ច្រើនជាងស្វែងរកសេវាសុខភាពនៅមន្ទីរពេទ្យសាធារណៈ ឬមន្ទីរសម្រាកព្យាបាលឯកជនៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពឹងផ្អែកលើការប្រើប្រាស់ថ្នាំពេទ្យ ដើម្បីបំពេញតម្រូវការថែទាំសុខភាព ចំណុចនេះបង្ហាញឲ្យឃើញថា កត្តាខ្វះខាតធនធានហិរញ្ញវត្ថុមិនមែនជាបញ្ហាទាំងស្រុងនោះទេ ប៉ុន្តែលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតម្នាក់ៗ ទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីលក្ខខណ្ឌភូមិសាស្ត្រ ឬប្រព័ន្ធអង្គការសង្គមផ្សេងទៀតៗ

ការទទួលបានសេវាសុខភាពអាចកំណត់តាមវិធីផ្សេងៗគ្នា - ពីការចែកចាយ ឬផ្តល់សេវាពិនិត្យសុខភាព ធនធានផ្សេងៗ និងសម្ភារបរិក្ខារទៅតាមតម្រូវការផ្ទាល់នៃប្រជាជន ដូចជាកញ្ចប់សេវាធានារ៉ាប់រង ការយល់ដឹងអំពីការថែទាំសុខភាព និងប្រាក់ចំណូលៗ ការធ្វើឲ្យប្រសើរឡើងនូវការទទួលបាននូវសេវាថែទាំសុខភាពអាចធ្វើបានៗ ជាលទ្ធផលចុងក្រោយ ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាព និងសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅ មិនផ្តោតចម្បងលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនោះទេ ប៉ុន្តែផ្តោតលើសំណួរថា តើធ្វើយ៉ាងណាដើម្បីឲ្យការទទួលបានសេវាថែទាំសុខភាពមានភាពងាយស្រួល ការជឿជាក់ និង

អាចទុកចិត្តបាន។

ការងារស្រាវជ្រាវរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងវិស័យនេះគឺមិនបានគ្រប់ជ្រុងជ្រោយនោះទេ។ ការរកឃើញទាំងនេះគឺមានលក្ខណៈជាការស្រាវជ្រាវកម្រិតបឋម។ ទោះយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជាលើកឡើងនូវសំណួរ និងការជាប់ពាក់ព័ន្ធជាច្រើន ដែលមានសារសំខាន់ពាក់ព័ន្ធនឹងការងារដែលកំពុងបន្ត និង សក្តានុពលនាពេលអនាគតក្នុងកិច្ចសហការជាមួយសហគមន៍អ្នករស់រានមានជីវិតនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសក្រោយជម្លោះផ្សេងទៀត។



ប្រាសាទអង្គរវត្តនៅក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា បន្តការងាររបស់ខ្លួននៅក្នុងវិស័យនេះ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចែករំលែកការរកឃើញ និងអនុសាសន៍ជាមួយសាធារណជន មិនត្រឹមតែការបង្ហាញអំពីស្ថានភាពលំបាក បញ្ហាប្រឈម និងឧបសគ្គនៃការទទួលបានសេវាសុខភាព និងសេវាសង្គមសំខាន់ៗសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប៉ុណ្ណោះទេ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបង្ហាញផ្នែកដែលអាចធ្វើឲ្យប្រសើរឡើងបាន ក្នុងផ្នត់គំនិតរបស់សហគមន៍អន្តរជាតិ លើយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មដ៏ឃោរឃៅនៅក្នុងសង្គមក្រោយជម្លោះទាំងអស់នៅជុំវិញពិភពលោក។



អ្នកស្ម័គ្រកម្ពុជាចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលនៅទូទាំងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ឆាំង យុ ជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ បេសកកម្មរបស់មជ្ឈមណ្ឌលកម្ពុជាផ្តោតលើការចងចាំ និងការស្វែងរកយុត្តិធម៌ ជួយគាំទ្រដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកការពិត ដែលជាការបង្រួបបង្រួមជាតិពិតប្រាកដ។ ក្នុងចំណោមការរួមចំណែកជាច្រើនចំពោះ ការពិត និងយុត្តិធម៌ លោក ឆាំង យុ បានផ្តល់សក្ខីកម្មនៅចំពោះមុខសាលាក្តីខ្មែរក្រហមក្នុងនាមជាសាក្សីរស់ចំពោះអំពើប្រល័យពូជសាសន៍ និងបានបង្កើតកម្មវិធីអប់រំអំពីអំពើប្រល័យពូជសាសន៍ទូទាំងប្រទេសដោយមានការគាំទ្រពីមូលដ្ឋានយ៉ាងរឹងមាំ និងបានបង្កើតមជ្ឈមណ្ឌលឯកសារអំពីអំពើប្រល័យពូជសាសន៍ក្នុងតំបន់ចំនួនប្រាំមួយ រួមទាំងបណ្ណាល័យសម្តេចម៉ែ ដើម្បីជួយសម្រួលដល់ការស្រាវជ្រាវ និងលើកកម្ពស់ដល់ការផ្សះផ្សាជាតិ។

# ដៅ វេង ស្រ៊ី ៖ យុទ្ធជនបច្ចេកទេសជួសជុលម៉ាស៊ីនតំបន់៥ ភូមិភាគពាយ័ព្យ

ផាត ចាន់សុនិតា



កុមារកំពុងជុសសម្អាតបំពង់បូមទឹកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដៅ វេង ស្រ៊ី គឺជាអតីតសាស្ត្រាចារ្យវិទ្យាល័យនេតយ៉ង នៅក្នុងរបបសាធារណរដ្ឋខ្មែរ។ នៅក្នុងសម័យខ្មែរក្រហម ដៅ វេង ស្រ៊ី ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាយុទ្ធជនបច្ចេកទេសជួសជុលម៉ាស៊ីននៅតំបន់៥ ភូមិភាគពាយ័ព្យ។ គាត់ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៧។ ខាងក្រោមនេះគឺជាសេចក្តីរាយការណ៍អំពីប្រវត្តិ និងសកម្មភាពរបស់ ដៅ វេង ស្រ៊ី នៅក្នុងចម្លើយសារភាពរបស់គាត់ជូនអង្គការ ៖

ខ្ញុំឈ្មោះ ដៅ វេង ស្រ៊ី ភេទប្រុស អាយុ២៩ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) មានទីកន្លែងកំណើតនៅភូមិច្បារ, ឃុំច្បារ, ស្រុកច្បារ, ខេត្តមណ្ឌលគិរី។ ឪពុករបស់ខ្ញុំឈ្មោះ ដៅ ស៊ីម និង ម្តាយឈ្មោះ ថ្វាំ ស្រ៊្យា។ ឪពុកម្តាយរបស់ខ្ញុំគឺជាកសិកររស់នៅភូមិព្រែកទេរ, ឃុំបុសលាវ, ស្រុកក្រចេះ, ខេត្តក្រចេះ។ ពីឆ្នាំ១៩៥៥ ដល់ ឆ្នាំ១៩៥៨ ខ្ញុំរៀននៅសាលាបឋមសិក្សាអូររាំង ខេត្តមណ្ឌលគិរី ចាប់ពីថ្នាក់ទី១២ដល់ថ្នាក់ទី១០។ ពីឆ្នាំ១៩៥៩ ដល់ ឆ្នាំ១៩៦១ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាក្រចេះ ខេត្តក្រចេះពីថ្នាក់ទី៩ ដល់ថ្នាក់ទី៧។ ពីឆ្នាំ១៩៦២ ដល់ ឆ្នាំ១៩៦៧

ខ្ញុំចូលរៀននៅសាលាបច្ចេកទេសយន្តវិទ្យាកំពង់ចាម ខេត្តកំពង់ចាម ពីថ្នាក់ទី៦ ដល់ថ្នាក់ទី១។ នៅឆ្នាំ១៩៦៨ ខ្ញុំប្រឡងចូលរៀនថ្នាក់បញ្ចប់នៅវិទ្យាល័យព្រះសីហនុកំពង់ចាម។ អំឡុងឆ្នាំ១៩៦៨ ដដែលមានចលនាបំផុសមនោគមវិជ្ជាក្រហមផុះឡើង នៅក្នុងវិទ្យាល័យ តាមរយៈការឃោសនា និងបាចត្រាក់របស់សិស្សមាននិន្នាការក្រហម។

សុក ប៉ោន គឺជានាយកសាលាព្រះសីហនុកំពង់ចាម បានអប់រំណែនាំខ្ញុំ និងសិស្ស៩ នាក់ទៀតឲ្យស្រឡាញ់ការសិក្សា ដើម្បីស្វែងរកការងារបានល្អ សម្រាប់ទ្រទ្រង់ជីវភាពខ្លួនឯង គ្រួសារ និង ចូលរួមកសាងប្រទេសជាតិ។ នាយកសាលាបានអប់រំខ្ញុំ និងសិស្សទាំង៩ នាក់ទៀតឲ្យស្អប់របបកុម្មុយនីស្ត និងខ្មែរក្រហមដោយគាត់បានណែនាំខ្ញុំនិងសិស្សផ្សេងទៀតថា បក្សពួកខ្មែរក្រហមមួយចំនួនដែលជាសិស្សខ្លះ បាននាំយកមនោគមវិជ្ជាក្រហម និងចលនារបស់ខ្លួនមកផ្សព្វផ្សាយ និងបំផុសបំផុលនៅក្នុងវិទ្យាល័យដើម្បីរាំងស្ទះចលនានៃការសិក្សារបស់យើង ដែលជាហេតុនាំឲ្យខាតបង់គុណប្រយោជន៍របស់យើង និងគុណប្រយោជន៍របស់ជាតិសព្វគ្រប់បែបយ៉ាង។ ដោយសារចលនាក្រហមនេះ យើងរៀនក៏មិនកើតអនាគតមិនដឹងទៅជាស្អី ជាតិត្រូវលិចលង់ ហើយត្រូវក្លាយជាខ្ញុំរបស់កុម្មុយនីស្ត ដោយសារខ្មែរក្រហម។ ប្រជាជននឹងរងទុក្ខវេទនា ព្រោះរបបកុម្មុយនីស្តពុំទុកសិទ្ធិឲ្យប្រជាជនមានសេរីភាពក្នុងការហូបចុកស្លៀកពាក់ មានសេរីភាពដើរលេងបងប្អូន និងកម្សាន្តសប្បាយតាមចំណង់នោះទេ។ ម្យ៉ាងទៀត របបកុម្មុយនីស្តពុំផ្តល់សិទ្ធិឲ្យប្រជាជនបណ្តុះបណ្តាលកូនចៅបានទៅរៀនសូត្រស្គាល់វប្បធម៌ខ្ពង់ខ្ពស់នោះទេ កូនខ្មែរនឹងត្រូវល្ងិតល្ងង់។

បន្ទាប់ពីទទួលបានការណែនាំពីលោកគ្រូនាយកសាលារួច ខ្ញុំនិងសិស្សផ្សេងទៀតបានបញ្ជាក់ជំហរខ្លួនឯងថា ត្រូវតែប្រឆាំងនឹងចលនាខ្មែរក្រហម ដើម្បីកុំឲ្យមានរបបកុម្មុនីស្តកើតឡើងនៅស្រុកខ្មែរ។ ដោយមើលឃើញពីជំហររបស់ខ្ញុំនិងសិស្សផ្សេងទៀតប្រឆាំងនឹងរបបកុម្មុយនីស្ត លោកគ្រូបានអប់រំខ្ញុំឲ្យចូលធ្វើគិញជាមួយគាត់ ដោយគាត់បានដាក់ភារកិច្ចឲ្យខ្ញុំទាំងអស់គ្នាអនុវត្តដូចតទៅ ១) ឲ្យខ្ញុំទាំងអស់គ្នាខិតខំតាមដានស៊ើបពិនិត្យសិស្សដែលជាខ្មែរក្រហមចូលមកបង្កប់ខ្លួនបាចត្រាក់ក្នុងសាលា។ ចំពោះខ្លឹមសារនៅលើត្រាក់និយាយពីសមាសភាពវណ្ណៈដែលត្រូវគេជិះជាន់ក្នុងសង្គមកម្ពុជា។ វាយរបបសក្តិភូមិ អំពាវនាវឲ្យសិស្សទាំងអស់ជាវណ្ណៈក្រីក្រមានស្មារតីភ្ញាក់រឭក ២) ឲ្យខិតខំទាក់ទងកសាងកម្លាំងឲ្យបានច្រើនក្នុងចំណោមសិស្សតាមសាលានីមួយៗ

នៅចុងឆ្នាំ១៩៦៩ ខ្ញុំបានប្រឡងចូលរៀនច្បាប់គ្រូនៅមហាវិទ្យាល័យគរុកោសល្យគ្រូនៅភ្នំពេញ។ ពេលនោះ សុក ប៉ោនបានសរសេរសំបុត្រខ្ទេសនាមខ្ញុំឲ្យទៅទាក់ទងជាមួយ ប៉ោង គឹមអន ព្រឹទ្ធាចារ្យបុរសនៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ។ ប៉ោង គឹមអន បានឲ្យខ្ញុំធ្វើសេចក្តីរាយការណ៍អំពីភារកិច្ចដែលខ្ញុំធ្លាប់អនុវត្តកាលពីនៅវិទ្យាល័យព្រះសីហនុ ហើយគាត់បានទទួលស្គាល់ខ្ញុំនិងចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានថ្នាក់គណិតវិទ្យា-រូបវិទ្យា និងឲ្យខ្ញុំបន្តភារកិច្ចជាគិញតទៅទៀត។ ខ្ញុំទាក់ទងកសាងកម្លាំងគិញបានចំនួន៣នាក់ ដោយខ្ញុំបានពន្យល់ខ្លឹមសារអប់រំទៅកាន់អ្នកទាំងបីថា "របបសេរីនិយម គឺជារបបដែលមនុស្សលោកត្រូវការ។ មនុស្សកើតមកត្រូវតែមានសេរីភាពពេញលេញតាមចំណង់ចំណូលចិត្តរបស់ខ្លួន។ យើងត្រូវស្រឡាញ់របបនេះ។ របបកុម្មុយនីស្តជារបបប្រមូលផ្តុំ ម្នាក់ៗរស់នៅក្នុងរបបនេះ ខ្វះសេរីភាពសព្វបែបយ៉ាង ហូបក៏ចែក ស្លៀកពាក់ក៏ចែក អ្វីៗផ្សេងទៀតសុទ្ធតែចែក" ។ ក្រោយមក ប៉ោង គឹមអនបានខ្ទេសនាមខ្ញុំឲ្យបានស្គាល់ នន់ នាវ៉ា អតីតប្រធានសមាគមនិស្សិតសាស្ត្រាចារ្យ និងជាភ្នាក់ងារអភិវឌ្ឍន៍ ផ្នែកកម្មវិធីសិក្សារបស់អង្គការជំនួយ «យូណេស្កូ»។

នៅឆ្នាំ១៩៧០ នន់នាវ៉ាបាននាំខ្ញុំឲ្យចូលសេ-អ៊ី-អានៅ នាយកក្រុងមធ្យមសិក្សាភ្នំពេញ ដោយខ្ញុំទទួល

បានប្រាក់ខែចំនួន១៨០០រៀល។ ភារកិច្ចដែលខ្ញុំត្រូវធ្វើពេលនោះគឺ ១) ដើរសង្កេតការណ៍ស្រាវជ្រាវពីខ្មែរក្រហមដែលបង្កប់នៅ ទីក្រុងភ្នំពេញតាមមជ្ឈដ្ឋាននានា ២) ខិតខំឃោសនា អប់រំអំពីរបបសេរីនិយមប្រឆាំងនឹងរបបកុម្មុយនីស្ត ដើម្បីទាក់ទងកសាងកម្លាំង។

នៅឆ្នាំ១៩៧១ ខ្ញុំបានផ្លាស់ទៅបង្រៀននៅអនុវិទ្យាល័យបវេលនៅខេត្តបាត់ដំបង។ នៅទីនោះខ្ញុំបន្តកសាងកម្លាំងបន្ថែម ដោយសុទ្ធតែជាគ្រូបង្រៀន និងកូនសិស្ស។ ខ្ញុំបានផ្សព្វផ្សាយខ្លឹមសារអប់រំថាការវិវឌ្ឍន៍នៃការសិក្សាដែលនាំឲ្យវិទ្យាសាស្ត្រជឿនលឿន និងជីវភាពប្រជាជនរីកចម្រើនគ្រប់ផ្នែកពុំដែលឃើញកកើតពីប្រទេសកុម្មុយនីស្តមុនទេគឺកើតចេញពីប្រទេសលោកសេរីមុន។ ឧទាហរណ៍, គ្រឿងម៉ាស៊ីនប្រើប្រាស់ពីប្រទេសចិនច្រើនតែចម្លងគេ ហើយអន់ទាំងគុណភាពអន់ទាំងរូបរាង។

នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវផ្លាស់ទៅបង្រៀននៅវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង។ នៅទីនោះ ខ្ញុំបានធ្វើការទាក់ទងកសាងកម្លាំងជាមួយសាស្ត្រាចារ្យវិទ្យាល័យ នេតយ៉ង ជាច្រើននាក់ ដូចជា ម៉ែន ភឿន, កុល យៀក, តូច ឈួង, ឡោក ឆូត, ជិន តៃហេង, ទ្រី ឈាងហួត, ម៉ុង ចាន់តាណា, អាំង អេងថាវ និង ជួប អេង ស្រ៊ុន។

នៅឆ្នាំ១៩៧៤ ខ្ញុំបានចូលរួមសកម្មភាពជាមួយ ហ៊ិន ស៊ីថាន សាស្ត្រាចារ្យវិទ្យាល័យនេតយ៉ង់ ទាក់ទងកសាងកម្លាំងបានបួននាក់ទៀតដើម្បីចូលបម្រើក្នុងអង្គការ សេ-អ៊ី-អា រួមមាន លាស់ សុគន្ធី, ហូ ភីណូ, កុយ មី និង ឡោ សារិត។ ហ៊ិន ស៊ីថាន បានអប់រំទៅកាន់គ្រូនិងសិស្សទាំងនោះថា "របបកុម្មុយនីស្តផ្តាច់ការណាស់ គួយ៉ាងដូចក្នុងប្រទេសយើងឥឡូវនេះប្រជាជនដែលរស់នៅតំបន់ដែលខ្មែរក្រហមកាន់កាប់ សុខចិត្តលះបង់ភូមិកំណើតផ្ទះសម្បែងជាទីស្រឡាញ់ ខំរត់កាត់គ្រាប់ទោះជាស្លាប់ក៏ដោយ ធ្វើយ៉ាងណាឲ្យតែបានរត់មករស់នៅក្នុងរបបសាធារណរដ្ឋនិយម ដោយហេតុតែចង់បានសេរីភាព។

នៅឆ្នាំ១៩៧៥ ខ្ញុំបានឈប់បង្រៀន ចេញមកប្រកបរបររកស៊ីជាងជួសជុលគ្រឿងម៉ាស៊ីន នៅចុងស្ពានថ្មថ្មីបាត់ដំបង។ ក្រោយមក ម៉ែន ភឿនបានខ្មេសនាមខ្ញុំឲ្យស្គាល់ ពិត ស៊ីត, អ៊ី ណយ, ជិន តៃហេង, កុល យៀត, សោម សំអុន និងសិស្សមួយចំនួននៅតំបន់រំដោះភូមិភាគពាយ័ព្យ ដើម្បីធ្វើការ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ខេត្តបាត់ដំបងត្រូវខ្មែរក្រហមរំដោះបាន។ នៅថ្ងៃបន្ទាប់ បងហឿន និង ម៉ែន ភឿន បានទៅជួបអ៊ំញឹមប្រធានគណភូមិភាគពាយ័ព្យនៅខេត្តបាត់ដំបង។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ អ៊ំញឹម បានបញ្ជូនខ្ញុំ, ម៉ែន ភឿន, ជិនតៃហេង និង សិស្ស១៣នាក់ទៀត ទៅរៀនសូត្រ និងធ្វើជាជំនួយការតំបន់៥។ ពេលទៅដល់ បងហ៊ីង្ស លេខាតំបន់៥ មកទទួលនិងចាត់តាំងបង ម៉ែន ភឿន ឲ្យធ្វើជាអ្នកទទួលខុសត្រូវនិងធ្វើជាជំនួយការគាត់ផ្ទាល់។ ម៉ែន ភឿន បានចាត់តាំងខ្ញុំឲ្យទៅវាស់ដីបែងចែកធ្វើប្រព័ន្ធភ្លឺប្រឡាយ នៅកសិដ្ឋានសាលាក្រៅ។ គាត់បានខ្មេសនាមខ្ញុំឲ្យភ្ជាប់ខ្សែទាក់ទងជាមួយ ចាន់ ប្រធានកសិដ្ឋានស្រែ ស្រុកសាលាក្រៅ តំបន់៥ ភូមិភាគពាយ័ព្យ។ បន្ទាប់មក ខ្ញុំក៏បានមកធ្វើការជាមួយ ចាន់ ហើយ ចាន់ បានណែនាំខ្ញុំឲ្យស្គាល់ខ្សែទាក់ទងគាត់៦នាក់ រួមមាន លី, ញ៉ាន, នៅ, សំបាត់, ហេង និង រេត។ បន្ទាប់ពីស្គាល់ខ្សែគ្នាអស់ហើយ ចាន់ ក៏បានប្រជុំកណ្តាលវាលស្រែកសិដ្ឋានសាលាក្រៅ និងដាក់ផែនការឲ្យឃោសនាអូសទាញប្រជាជនទៅធ្វើទ័ពខ្មែរសេរី។ គាត់បានណែនាំឲ្យប្រជាជនធ្វើការវិភាគប្រៀបធៀបពីការរស់នៅក្នុងរបបមុន ដែលមានភាពងាយស្រួល និងមានសេរីភាពជាងការរស់នៅក្នុងបដិវត្តន៍។ បន្ទាប់ពីបានស្តាប់តាមការណែនាំរបស់ចាន់ហើយ ខ្ញុំនិងអ្នកទាំង៦នាក់ទៀត ក៏បានចាប់ផ្តើមធ្វើសកម្មភាពឃោសនាបំផុសបំផុលនៅកសិដ្ឋានសាលាក្រៅជាបន្តបន្ទាប់។

ក្រោយមក ម៉ែន ភឿនបានដកខ្ញុំចេញពីកសិដ្ឋាន



កម្មករកំពុងតម្លើងស្នាបកន្លាវនៅក្នុងបំពង់បូមទឹក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សាលាក្រៅ ហើយចាត់តាំងខ្ញុំឲ្យកាន់ផ្នែកសង្គមកិច្ចទទួលប្រជាជនថ្មីនៅ ស្ថានីយ៍រថភ្លើងសេរីសោភ័ណតំបន់៥ ខេត្តបាត់ដំបង។ គាត់បានណែនាំនិងខ្ទេសនាមខ្ញុំឲ្យស្គាល់ខ្សែរបស់គាត់ពីរនាក់ឈ្មោះ ភឿន គឺជាប្រធាននយោបាយពេទ្យ និងសង្គមកិច្ចតំបន់៥ និង ម៉ោង គឺជាប្រធានគណៈស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ។ នៅឆ្នាំ១៩៧៦ ខ្ញុំ, ភឿន និង ម៉ោង បានរួមសកម្មភាពអនុវត្តផែនការមិនដោះស្រាយផ្នែកសង្គមកិច្ចរបស់ប្រជាជនថ្មី ដោយលាក់ថ្នាំមិនព្យាបាល ទុកឲ្យប្រជាជនអត់ជម្រកឈឺស្លាប់អស់ជាច្រើននាក់។ បន្ទាប់ពី លែងមានការបញ្ជូនប្រជាជនថ្មីទៅតំបន់៥ មែន ភឿន បានចាត់តាំងខ្ញុំឲ្យធ្វើជាអ្នកបច្ចេកទេសធ្វើម៉ាស៊ីន ដាក់កប្បាស នៅរោងចក្រក្រឡឹងសេរីសោភ័ណ ដើម្បីឲ្យខ្ញុំបាននៅមួយកន្លែងសម្រួលដល់ការអនុវត្តផែនការដែលខ្ញុំត្រូវទាក់ទងនឹងឈ្មោះ សារ៉ាត ប្រធានពាណិជ្ជកម្មតំបន់៥។

ខ្ញុំក៏បានទៅប្រជុំជាមួយ សារ៉ាត នៅមន្ទីរពាណិជ្ជកម្មតំបន់៥ ដោយគាត់បានលើកពីផែនការធ្វើសង្គ្រាមប្រឆាំងនឹងបដិវត្តន៍នៅ ឆ្នាំ១៩៧៧។ សារ៉ាត បានប្រាប់ពីផែនការរបស់ បង ហ៊ីង ឲ្យខ្ញុំត្រៀមលួចយកគ្រឿង ឡាន និងគ្រឿងត្រាក់ទ័រ ដែលអង្គការទិញសម្រាប់ផ្តល់ឲ្យតំបន់៥ យកទៅលាក់ទុក។ បន្ទាប់ពីប្រជុំចប់ខ្ញុំក៏បានអនុវត្តផែនការលាក់ទុកគ្រឿងសម្រាប់តំឡើងត្រាក់ទ័រ និង ឡាន សម្រាប់ដឹកសម្ភារនិងបក្ខពួកទៅកាន់ស្រុកសៀម។ នៅចុងឆ្នាំ១៩៧៦ ហ៊ីង បានឲ្យខ្ញុំរៀបចំប្តូរ ឡានដែលអង្គការទុកទទួលភ្ញៀវក្នុងតំបន់៥ចំនួន៣០ គ្រឿងសម្រាប់ផែនការរត់ទៅស្រុកសៀម។

បន្ទាប់ពីរៀបចំ ឡានរួច ហ៊ីង បានហៅ ម៉ែន ភឿន និងខ្ញុំ ទៅប្រជុំជាមួយមនុស្ស៣០នាក់ជាងទៀត។ បន្ទាប់ពីប្រជុំចប់ ហ៊ីង បានប្រគល់មនុស្សទាំង៣០នាក់ជាងឲ្យទៅ ម៉ែន ភឿន ដើម្បីចាត់ចែងរាយកម្លាំងបង្កប់ក្នុងជួរប្រជាជនតាមការដ្ឋានទំនប់ត្រពាំងថ្ម។ ខ្ញុំបានទៅបង្កប់ខ្លួននៅតាមកងចល័តតាមការចាត់តាំងរបស់ ហ៊ីង។ ក្រោយមក អង្គការបានចាប់ខ្លួន មែន ភឿន នៅខែឧសភា ឆ្នាំ១៩៧៧។ បន្ទាប់ពី មែន ភឿន ត្រូវចាប់ខ្លួន ហ៊ីង បានដកខ្ញុំចេញពីកងចល័តឲ្យមកនៅកន្លែង ឡានតូចវិញ ដោយគាត់ណែនាំខ្ញុំឲ្យផ្អាកសកម្មភាពប្រឆាំងបដិវត្តន៍សិន ហើយឲ្យខ្ញុំខិតខំនិយាយល្អពីបដិវត្តន៍។ ការងាររបស់ខ្ញុំគឺចាំតែជួសជុល ឡានដែលនីរសារយកមកមិនដែលហ៊ានចេញទៅណាមកណាទេ រហូតដល់ថ្ងៃដែលអង្គការចាប់ខ្លួនខ្ញុំពីកន្លែង ឡានតូចនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៧»។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00287។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ជៅ វេង ស្រ៊ី ពិតប្រយ៉ាងណានោះទេ។**

# ទូទ័ល សារ៉ស់៖ អ្នកត្បាញក្រមាឱ្យអង្គការ

មីន សាណាស់



ទូទ័ល សារ៉ស រស់នៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ខែកក្កដា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទូទ័ល សារ៉ស់ ភេទស្រី អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កាលជំនាន់ដើមខ្ញុំប្រកបរបរត្បាញសំពត់សូត្រ និងក្រមា។ ចំណែកឪពុកខ្ញុំឈ្មោះ ទូទ័ល គឺជាអ្នកធ្វើកន្ទេល និងមានចំណេះដឹងផ្នែកសាសនាក្នុងភូមិមួយរូប ហើយម្ដាយខ្ញុំឈ្មោះ សុះ ភាស គឺជាអ្នកបង្កើតគោមសំពត់សូត្រ ត្បាញដែលជារបរបន្ទាប់បន្សំជួយជីវភាពក្នុងគ្រួសារ។ ឪពុកម្ដាយខ្ញុំមានកូនចំនួន១០នាក់គឺប្រុស៥នាក់ និងស្រីចំនួន៥នាក់។ បងៗប្រុសខ្ញុំសុទ្ធតែជាទាហានលន់ នល់។ ក្រោយរបបខ្មែរក្រហម គឺបងប្អូនខ្ញុំនៅសល់តែពីរនាក់ប៉ុណ្ណោះ គឺខ្ញុំ និងបងប្រុសខ្ញុំម្នាក់ដែលបានរត់ចេញទៅប្រទេសវៀតណាម។

កាលពីតូច ឪពុកម្ដាយខ្ញុំជំរុញខ្ញុំឲ្យសិក្សាពីក្បួនច្បាប់ផ្នែកសាសនាដល់អាយុប្រហែលជា១៥ឆ្នាំ ខ្ញុំឈប់រៀនហើយងាកមករៀនសូត្ររបរប្រពៃណីតម្បាញសូត្រពីម្ដាយខ្ញុំ។ មួយផ្នែកទៀត ខ្ញុំចង់ជួយសម្រាលការងារគាត់។ ដំបូងម្ដាយខ្ញុំឲ្យរៀនត្បាញជាមុនសិន។ បន្ទាប់ពីខ្ញុំចេះត្បាញហើយ គាត់ចាប់ផ្ដើមបង្រៀនខ្ញុំឲ្យចងគោម ហើយណែនាំខ្ញុំដាក់ពណ៌អ្វីឲ្យត្រូវជាមួយគោមសំពត់នីមួយៗ។ ទម្រាំខ្ញុំចេះចាំ និងអាចចងគោមបានដោយខ្លួនឯង វាមិនមែនជារឿងងាយស្រួលទេ គឺយូរណាស់ បានធ្វើចេញជាសំពត់មួយ។ កាលខ្ញុំនៅត្បាញសំពត់បានប្រវែងតែពីរម៉ែត្រគឺកាត់ចេញហើយ មិនដូចបច្ចុប្បន្នត្រូវត្បាញឲ្យបានបួនម៉ែត្រ រួចហៅថាមួយក្បិនទេ។ ប្រហែលនៅក្នុងកំឡុងឆ្នាំ១៩៦២ ឈ្មួញពេញនិយមទិញសំពត់គោមផ្ការំយោង ផ្កាម្ទិះ ផ្ការាំង គោមភ្នែកគោ កូនហ៊ឹង គោមផ្កាទទឹមតូចៗ គោមភ្នែកមាន់ និងគោមចំណិតសណ្ដាន់។ គោមទាំងនេះមានពណ៌លឿង ក្រហម ខ្មៅ និងបៃតង ដោយប្រើលក្ខធម្មជាតិប្រហោម៉្រាងទៀតលក្ខខ្មែរ។ គោមដែលខ្ញុំបានរៀបរាប់នេះគឺសុទ្ធតែជាគោមដែលខ្ញុំធ្លាប់ចងដោយផ្ទាល់ ហើយអតិថិជនចូលចិត្តប្រើប្រាស់។ ឈ្មួញកុម្ម៉ង់យកទៅលក់បន្តដោយកក់យកគោមទាំងនេះជាបន្តបន្ទាប់។

នៅក្នុងឆ្នាំ១៩៦៧ ឪពុកម្ដាយខ្ញុំបានរៀបចំពិធីរៀបការឲ្យខ្ញុំនិងប្ដីខ្ញុំឈ្មោះ ស្មាស់ អេល។ ខ្ញុំរៀបការហើយនៅតែបន្តការងារតម្បាញរបស់ខ្ញុំដដែល។ ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម

សីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០មិនបានប៉ុន្មានផង ស្រាប់តែឃើញមានព្រឹត្តិការណ៍ប្លែកៗនៅក្នុងភូមិ គឺខ្ញុំឃើញមានកងកម្លាំងរំដោះខ្មែរក្រហមចូលមកគ្រប់គ្រង ហើយចាត់តាំងប្តីរបស់ខ្ញុំកាន់តួនាទីខាងគ្រប់គ្រងឃុំ ឬហៅថាកាន់ខាងគមនាគមន៍។ ក្រោយមក ហាកឹម តួន និង អ្នកមានធនធានក្នុងភូមិត្រូវកងកម្លាំងរំដោះមកហៅឲ្យចុះពីលើផ្ទះនិងយកទៅរាល់យប់ៗ សូម្បីតែឪពុករបស់ខ្ញុំ និងបងប្រុសៗរបស់ខ្ញុំក៏កងកម្លាំងរំដោះខ្មែរក្រហមចាប់យកទៅដែរ ព្រោះបងប្រុសរបស់ខ្ញុំធ្វើជាទាហានលន់នល់។ ខ្ញុំខំស្រែកថា កុំយកគាត់ទៅអី គួរយោគយល់ប្តីរបស់ខ្ញុំផង គាត់ក៏ជាអ្នកធ្វើការឲ្យកងកម្លាំងរំដោះដែរ។ ប៉ុន្តែសំដីដែលកងកម្លាំងរំដោះតបមកខ្ញុំវិញពុតែ «ឯងឡើងលើផ្ទះវិញទៅ គ្មានប្រយោជន៍ទេ»។ ក្រោយពីចាប់ឪពុកខ្ញុំនិងបងៗបានបីថ្ងៃ ព្រឹកឡើងពេលខ្ញុំចុះពីផ្ទះដាន់កាំជណ្តើរ ស្រាប់តែឃើញខោអាវឪពុកនិងបងៗរបស់ខ្ញុំ។ ខ្ញុំដឹងក្នុងចិត្តរួចហើយថាពួកគាត់ត្រូវកងកម្លាំងរំដោះខ្មែរក្រហមយកទៅសម្លាប់។

នៅឆ្នាំ១៩៧៥ ក្រោយពីកងទ័ពខ្មែរក្រហមរំដោះទីក្រុងភ្នំពេញរួច ខ្មែរក្រហមចាប់ផ្តើមជម្លៀសជនជាតិចាមចេញពីភូមិ ដោយទុកតែប្រាំមួយគ្រួសារសម្រាប់ត្បាញក្រមា និងធ្វើនំពុម្ពបារាំង។ ខ្ញុំត្បាញក្រមាឲ្យកងទ័ពខ្មែរក្រហមរហូតដល់ចុងឆ្នាំ១៩៧៨។ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជាមេក្រុមកីតម្បាញ ដឹកនាំជ្រលក់ពណ៌ រវៃអំបោះ ហាលអំបោះ។ ក្រមាដែលខ្ញុំត្បាញគឺមានពណ៌ខ្មៅលាយក្រហម គឺជាប្រភេទក្រមាបង់ក។ ក្រមាដែលខ្ញុំត្បាញភាគច្រើនឃើញកម្មាភិបាលខ្មែរក្រហមជូនដល់កូនកម្លោះកូនក្រមុំ ដែលអង្គការបានរៀបចំផ្សំផ្គុំ។ ទោះបីជាប្តីរបស់ខ្ញុំគឺជាប្រធានឃុំ ប៉ុន្តែសម្ភារ ដូចជា ក្រណាត់ ក្រមា និង នំ គឺខ្ញុំមិនដែលបានបរិភោគ ឬប្រើប្រាស់ឡើយ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំរស់នៅក្នុងភូមិដដែល និងរង់ចាំមើលផ្លូវ បងប្អូន កូនក្មួយត្រឡប់មកវិញ។ ប៉ុន្តែជាអកុសល បងប្រុស បងស្រី រួមជាមួយបងថ្លៃប្រុសស្រី ខ្ញុំមិនបានវិលត្រឡប់មកវិញទេ រហូតមកដល់សព្វថ្ងៃនេះ។ ខ្ញុំនិងប្តីប្រកបមុខរបរនេសាទត្រីលក់យកប្រាក់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ និងសន្សំលុយប្រាក់ខ្លះដើម្បីទុកចាយវាយសម្រាប់ថ្ងៃខាងមុខ។ ខ្ញុំនិងប្តី មិនមានកូនទេ ដូច្នេះខ្ញុំបានយកក្មួយពីរនាក់មកចិញ្ចឹម។

នៅឆ្នាំ១៩៨៤ ខ្ញុំឃើញអំបោះសូត្រមានលក់នៅលើទីផ្សារ ហើយដោយសារខ្ញុំមានចំណេះជំនាញពីម្តាយរបស់ខ្ញុំស្រាប់ ដូច្នេះខ្ញុំក៏រៀបចំដំឡើងកីត្បាញសំពត់សូត្រឡើងវិញ។ ខ្ញុំរកឈើថ្មី និងស្វែងរកកីតម្បាញចាស់ៗមកផ្គុំគ្នាដំឡើងទៅជាកី។ ខ្ញុំរៀបចំរវៃសូត្រ ស្វែងរកល័ក្តជ្រលក់ ហាលសូត្រ ចំណែកប្តីរបស់ខ្ញុំរៀបចំកី។ គោមដែលខ្ញុំធ្វើដំបូងបន្ទាប់ពីអាក់ខានធ្វើជាយូរឆ្នាំ គឺគោមក្ញៀក បន្ទាប់មកគោមសំរោង គោមចំណិតសណ្តាន់ និងគោមជាច្រើនទៀត។ ចំណែកពណ៌ គឺមានពណ៌បៃតង ពណ៌ក្រហម ពណ៌លឿង និងពណ៌ស្វាយ។ សព្វថ្ងៃភូមិកំពង់ក្របីលែងមានកីតម្បាញសំពត់សូត្រទៀតហើយ ព្រោះសំពត់សូត្រគ្មានទីផ្សារ។ នៅក្នុងភូមិមានតែកីត្បាញក្រមា ហើយសល់តែបួនទៅប្រាំកីតែប៉ុណ្ណោះ។ ខ្ញុំពិតជាសោកស្តាយស្នាដៃត្បាញដែលជាប្រពៃណីដ៏ដូនជីតាបន្សល់ទុកឲ្យ ហើយប្រសិនបើគ្មានការចាប់អារម្មណ៍លើការត្បាញនេះទៀតទេ នឹងធ្វើឲ្យបាត់បង់នៅពេលខាងមុខ។



កីសម្រាប់ត្បាញក្រមារបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ុន យ៉ាង ៖ កងនេសាទ

ថុន ស្រីពេជ្រ



យ៉ុន យ៉ាង រស់នៅឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យ៉ុន យ៉ាង អាយុ៦៥ឆ្នាំ បច្ចុប្បន្នគឺជាកសិករ រស់នៅឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ពេលអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅវត្តសំរោង ប៉ុន្តែខ្ញុំរៀនសូត្រមិនបានជ្រៅជ្រះទេ ដោយសារតែមានសង្គ្រាមកើតឡើងនៅជំនាន់ លន់ នល់។ នៅគ្រានោះមានការទម្លាក់គ្រាប់បែកជាច្រើនកន្លែង នៅ ខាងលិចវត្តជីផុច បណ្តាលឲ្យមនុស្សចំនួន២នាក់ស្លាប់ភ្លាមៗ។

នៅចុងឆ្នាំ១៩៧០ ខ្ញុំស្ម័គ្រចិត្តចូលធ្វើជាកងឈ្លបខ្មែរក្រហម ដោយមានប្រធានកងផលិតឈ្មោះ នី សារ៉ុម គឺជាអ្នកកត់ត្រាឈ្មោះ និងទទួលស្គាល់ខ្ញុំ។ ខ្ញុំត្រូវដើរមើលការខុសត្រូវប្រជាជននៅតាមភូមិ និងត្រូវរាយការណ៍អំពីសកម្មភាពរបស់ប្រជាជននៅក្នុងភូមិទៅកាន់ថ្នាក់លើ។ ក្រោយមកខ្ញុំត្រូវបានឈ្មោះ នី សារ៉ុម ប្រធានផលិតដកខ្ញុំចេញដោយសារតែខ្ញុំមិនបានរាយការណ៍អំពីសកម្មភាពលួចដាំបបររបស់ម្តាយខ្ញុំប្រាប់ទៅកាន់ថ្នាក់លើ។

ក្រោយពីឈប់ពីការងារកងឈ្លប ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើនីរសាររបស់តំបន់វិញ ដោយខ្ញុំធ្វើការងារចែកសំបុត្រនៅក្នុងភូមិ។ ជារៀងរាល់ថ្ងៃ ខ្ញុំជិះសេះពីភូមិមួយទៅភូមិមួយដើម្បីយកសំបុត្រទៅប្រគល់ឲ្យឃុំ និងយកសំបុត្រពីឃុំមកកាន់ភូមិវិញ។ ក្រៅពីជិះសេះរត់សំបុត្រតាមភូមិ ខ្ញុំត្រូវដើរមើលប្រជាជនដែលកំពុងតែធ្វើការងារ រួចរាយការណ៍អំពីសកម្មភាពទាំងអស់នោះប្រាប់ទៅកាន់ថ្នាក់លើឃុំ។

ក្រោយថ្ងៃយោធាខ្មែរក្រហមទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការខាងផ្នែកនេសាទ នៅអ្នកលឿង។ ខ្ញុំមិនសូវបានសម្រាកភ្នែកទេ ដោយសារតែត្រូវងើបមើលត្រីជាប់សំណាញ់ជាញឹកញាប់។ ត្រីដែលខ្ញុំរកបាន ខ្ញុំយកត្រីមួយចំនួនទៅចែកចាយតាមសហករណ៍ ស្រុក និងខេត្តនានា។ ចំណែកត្រីដែលនៅសេសសល់ ខ្ញុំយកទៅធ្វើជាត្រីប្រហុក និងរម្ងាស់ធ្វើជាទឹកត្រី សម្រាប់ចែកទៅសហករណ៍ ភូមិ ឃុំ ស្រុក និងខេត្ត។ យូរៗម្តង ខ្ញុំលួចផ្ញើទឹកត្រីទៅឲ្យគ្រួសាររបស់ខ្ញុំ។

នៅឆ្នាំ១៩៧៥ អង្គការរៀបការឲ្យខ្ញុំជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ ភួន ហើយពេលខ្ញុំរៀបការនោះមានតែ៣គូប៉ុណ្ណោះ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំរស់នៅជាមួយគ្នាបានរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ប្រពន្ធរបស់ខ្ញុំក៏ស្លាប់ដោយសាររន្ទះបាញ់។ មកដល់ឆ្នាំ១៩៧៧ អង្គការបានរៀបការឲ្យខ្ញុំជាមួយនឹងប្រពន្ធទីពីរទៀត ហើយយើងបានរស់នៅជុំគ្នារហូតមកដល់សព្វថ្ងៃ។ បន្ទាប់ពីរៀបការរួច អង្គការស្នើខ្ញុំឲ្យទៅធ្វើស្រែនៅក្នុងបរិវេណវត្តជីផុច។ នៅទីនោះ ការងាររបស់ខ្ញុំកាន់តែលំបាកជាងពេលមុនទៅទៀត ពិសេសគឺមិនមានអាហារហូបចុកគ្រប់គ្រាន់។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យដឹកក្របីឲ្យស៊ីស្មៅ ភ្ជួរស្រែ និងរែកសំណាប។ នៅពេលមានផែនការបន្ទាន់ ខ្ញុំត្រូវធ្វើការរហូតដល់ម៉ោង២រំលងអធ្រាត្រទើបបានសម្រាក ព្រោះខ្ញុំត្រូវតែបញ្ចប់ការងារឲ្យរួចរាល់។ លុះដល់ម៉ោង៥ភ្លឺស្រាងៗ ខ្ញុំត្រូវងើបឡើងដើម្បីដឹកក្របីឲ្យស៊ីស្មៅបន្តទៀត។ ថ្ងៃខ្លះខ្ញុំសម្រាកបានតែ៣ម៉ោងប៉ុណ្ណោះ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅកាន់តំបន់ភាគខាងលិចដើម្បីទៅធ្វើការនៅទីនោះ។ ប៉ុន្តែខ្ញុំបានស្នើសុំកម្មាភិបាលខ្មែរក្រហមត្រឡប់មករស់នៅភូមិកំណើតវិញ ព្រោះខ្ញុំឮថាប្រជាជនដែលបានត្រូវខ្មែរក្រហមបញ្ជូនទៅខេត្តភាគខាងលិចត្រូវបានកម្មាភិបាលខ្មែរក្រហមនៅទីនោះធ្វើបាប និងយកទៅសម្លាប់ចោល។



យ៉ុន យ៉ាង (រូបខាងស្តាំ) ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់លោក ដេង ពង្សរ៉ាស៊ី និងក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ក្នុងឱកាសចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំវិលត្រឡប់មកស្រុកកំណើតវិញ តាមការប្រកាសរបស់ខ្មែរក្រហម

**ចាន់ វីន**



រ៉ូយ សារ៉ុម និង ចៅ រស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ រ៉ូយ សារ៉ុម អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ កាលពីក្មេងខ្ញុំធ្លាប់បានចូលរៀននៅសាលារៀនភូមិដើមបេង។ ខ្ញុំបានរៀនដល់ត្រឹមថ្នាក់ទី៩ចាស់ប៉ុណ្ណោះក៏ឈប់រៀន។ ក្រោយពីឈប់រៀន ខ្ញុំនៅជួយមើលប្អូន និងជួយឪពុកម្ដាយធ្វើស្រែចម្ការ។

នៅឆ្នាំ១៩៧៤ គ្រួសាររបស់ខ្ញុំទាំងអស់បានភៀសខ្លួនទៅកាន់ប្រទេសវៀតណាម ដោយសារស្រុកកំណើតខ្ញុំមានសង្គ្រាមកើតឡើង។ ពេលទៅដល់ប្រទេសវៀតណាមដំបូង ខ្ញុំត្រូវរស់នៅពឹងផ្អែកលើអំណោយពីភាគីវៀតណាម។ ខ្ញុំទទួលបានទំប៉ុងត្រីខ ទឹកត្រី អំបិល និងអង្ករ ដើម្បីចិញ្ចឹមជីវិត។ ក្រោយមក ខ្ញុំទទួលបានដីចម្ការចំនួន២កុងដើម្បីធ្វើស្រែចម្ការផ្ទាល់ខ្លួន។ ក្រៅពីធ្វើស្រែ ឪពុកម្ដាយរបស់ខ្ញុំប្រូតស្បូវ និងក្រងស្បូវលក់យកកម្រៃបន្ថែមដើម្បីចិញ្ចឹមគ្រួសារ។

បន្ទាប់ពីខ្ញុំរស់នៅវៀតណាមអស់រយៈពេល២ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៦ឪពុករបស់ខ្ញុំឮខ្មែរក្រហមប្រកាសថា ជនជាតិខ្មែរដែលរស់នៅវៀតណាមត្រូវធ្វើការដោះដូរជាមួយជនជាតិវៀតណាមដែលរស់នៅក្នុងទឹកដីកម្ពុជា។ ឪពុករបស់ខ្ញុំបាននាំក្រុមគ្រួសារត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ។ អ្នកដទៃទៀត ក៏ត្រឡប់មកកាន់ប្រទេសកម្ពុជាដូចគ្រួសារខ្ញុំដែរ។ យើងបានធ្វើដំណើរមកដល់ភ្នំដិន។ យោធាខ្មែរក្រហម បានត្រៀមរូបស្រេចចាំទទួលយើងនៅទីនោះ ហើយបានចែកអង្ករ និងត្រីងៀតដល់យើងទៀតផង។

ធ្វើដំណើរចេញពីភ្នំដិនមក ខ្ញុំត្រូវបានយោធាខ្មែរក្រហមនាំយកមកស្នាក់នៅបណ្ដោះអាសន្ននៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ រយៈពេល២យប់។ បន្ទាប់មក ទើបមានឡានយោធាខ្មែរក្រហមផ្សេងទៀតមកដឹកគ្រួសារខ្ញុំទៅកាន់វត្តត្នោតជុំ ស្ថិតនៅក្នុងភូមិខ្ពបត្របែក ឃុំអូរសារាយ ស្រុកត្រាំកក់ ដើម្បីស្នាក់នៅមួយយប់ទៀត មុននឹងបន្តដំណើរ

ឆ្ពោះទៅកាន់ភូមិត្រពាំងដងទឹក ក្នុងឃុំដដែល។ ខ្ញុំត្រូវរស់នៅជុំគ្នាជាមួយឪពុកម្តាយ ប៉ុន្តែយើងធ្វើការនៅកន្លែងផ្សេងគ្នា។ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមប្រើឲ្យកាប់ដើមរពាក់សម្រាប់ធ្វើបង្គី និងកើបអាចម៍គោនៅពេលថ្ងៃ ហើយដឹកប្រឡាយនៅពេលយប់។

នៅឆ្នាំ១៩៧៧ ខ្ញុំបានមកស្នាក់នៅភូមិត្រពាំងនាល ឃុំត្រាំកក់ ស្រុកត្រាំកក់ ព្រោះខ្ញុំត្រូវបានចាត់តាំងឲ្យចូលធ្វើការនៅក្នុងកងកុមារនៅទីនោះ។ ភារកិច្ចរបស់ខ្ញុំគឺឃ្វាលគោ និងបររទេះដឹកបន្លែត្រីសាច់ ព្រមទាំងអង្ករយកទៅឲ្យបងៗនៅតាមឃុំផ្សេងទៀតក្នុងស្រុកត្រាំកក់។ ចំណែកឪពុកម្តាយរបស់ខ្ញុំ នៅធ្វើចម្ការ និងដាំដំឡូងនៅក្នុងភូមិត្រពាំងដងទឹកដដែល។ ទោះបីជាខ្ញុំនៅឆ្ងាយពីឪពុកម្តាយ ក៏ខ្ញុំសុំច្បាប់មកលេងគាត់បានដែរ។ ខ្ញុំបានទៅមើលថែម្តាយរបស់ខ្ញុំនៅក្នុងពេទ្យពេលដែលគាត់ឈឺ។

រហូតដល់ឆ្នាំ១៧៧៩ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងកាត់តាមផ្លូវជាតិក្នុងស្រុកត្រាំកក់ និងខេត្តកំពត រួចមកស្នាក់នៅកំពង់យោលមួយយប់ទើបមកដល់ទីកន្លែងកំណើតស្ថិតនៅភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។



រ៉ូយ សារ៉ុម ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ក្នុងឱកាសចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្រេង ហុងគាវ៖ កងកុមារផលិតជី

## ភាវស្ត្រី



ស្រេង ហុងគាវ នៅផ្ទះរបស់គាត់ ស្ថិតនៅភូមិបុស្សរីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្រេង ហុងគាវ អាយុ៥៧ឆ្នាំ កើតនៅភូមិបុស្សរីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ឪពុករបស់ខ្ញុំបានដឹះកង់ទៅចូលរួមធ្វើបាតុកម្ម ទាមទារអំណាចថ្វាយព្រះអង្គវិញ។ ខ្ញុំនៅចាំថា នៅពេលឪពុករបស់ខ្ញុំធ្វើដំណើរចេញទៅបាត់ ម្តាយរបស់ខ្ញុំចាប់ផ្តើមឈឺពោះឆ្លងទន្លេប្អូនរបស់ខ្ញុំ។ នៅថ្ងៃនោះ ខ្ញុំភ័យខ្លាំងណាស់ ព្រោះបារម្ភម្តាយដែលកំពុងឈឺពោះ ប៉ុន្តែសំណាងល្អមិនមានបញ្ហាអ្វីកើតឡើង បើទោះបីជាឆ្មបមកមិនទាន់ក៏ដោយ។

រហូតដល់អាយុ៧ឆ្នាំ ខ្ញុំចូលរៀននៅតាមផ្ទះរបស់ប្រជាជន។ ការរៀនសូត្រនៅក្នុងសម័យលន់ នល់ គឺមិនមានសាលារៀនត្រឹមត្រូវទេ សិស្សទាំងអស់ត្រូវចល័តរៀនតាមផ្ទះប្រជាជនមួយទៅផ្ទះប្រជាជនមួយទៀតរៀងរាល់មួយសប្តាហ៍ម្តង។ សិស្សានុសិស្សពុំបានសិក្សារៀនសូត្រជាប់លាប់នោះទេ ព្រោះត្រូវភៀសខ្លួនទៅភូមិក្បែរៗនោះដើម្បីគេចពីការទម្លាក់គ្រាប់បែក និងការធ្វើបាបរបស់ទាហានធីវគីបុរៀតណាមខាងត្បូង។

បន្ទាប់ពី លន់ នល់ ចាញ់សង្គ្រាម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងភូមិរបស់ខ្ញុំប្រារព្ធពិធីអបអរ ហូបអាហារជុំគ្នាយ៉ាងសប្បាយរីករាយ ដើម្បីទទួលអបអរជ័យជម្នះរបស់ខ្មែរក្រហម។ ដំបូងប្រជាជនអាចហូបបាយតាមផ្ទះរៀងៗខ្លួន។ ពេលនោះខ្ញុំចូលរៀននៅពេលថ្ងៃត្រង់ រីឯពេលព្រឹក និងពេលរសៀលគឺមេកងតម្រូវឲ្យទៅធ្វើការនៅក្នុងភូមិ។ ការងាររបស់កុមារ មានដូចជា ប្រមូលលាមកមនុស្សតាមផ្ទះយកទៅកូរក្នុង ឡជីលាយជាមួយដីដំបូកដើម្បីទុកធ្វើជីលេខមួយ។ កុមារដែលមានមាឌធំប្រធានកងបានចាត់តាំងឲ្យទៅលើកដីជាមួយមនុស្សធំ និងប្រូតស្រូវ ប៉ុន្តែកុមារទាំងនោះត្រូវឡើងមកហូបអាហារមុនកងចាស់ៗ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជននៅក្នុងភូមិឲ្យហូបរួម ប៉ុន្តែសម្រាប់កុមារនៅក្នុងភូមិបុស្សីសាញ់អាចហូបបបរមួយចម្អែត និងមិនសូវខ្វះខាតឡើយ។ នៅពេលរៀបការប្រជាជននៅក្នុងភូមិ គឺប្រធានសហករណ៍គឺជាអ្នកជ្រើសរើស និងផ្សំផ្គុំឲ្យ ហើយសាមីខ្លួនមិនអាចប្រកែកបានឡើយ។ ខ្ញុំចាំថា មានពូម្នាក់នៅជិតផ្ទះរបស់ខ្ញុំបានលេបថ្នាំសម្លាប់ខ្លួនព្រោះគាត់មិនទទួលយកប្រពន្ធដែលអង្គការរៀបចំឲ្យ។ គូខ្លះទៀតរស់នៅមិនចុះសម្រុងគ្នាឡើយ រហូតដល់របបខ្មែរក្រហមដួលរលំក៏លែងលះគ្នា។

នៅចុងឆ្នាំ១៩៧៨ បងប្អូនខាងឪពុកម្តាយខ្ញុំជាច្រើនគ្រួសារត្រូវអង្គការយកទៅសម្លាប់ចោលដោយសារអង្គការស៊ើប និងចោទពូរបស់ខ្ញុំឈ្មោះ ស្រី សុផល គឺជាប្រធានផ្លង់ ថាក្បត់ជាតិ។ ពូរបស់ខ្ញុំធ្វើការនៅប្រលានយន្តហោះខេត្តកំពង់ឆ្នាំង ហើយបន្ទាប់ពីយោធាចាប់ខ្លួនគាត់សាកសួរអំពីប្រវត្តិតស៊ូរួចហើយក៏មកតាមស្វែងរកចាប់បងប្អូនពូរបស់ខ្ញុំជាបន្តទៀតដើម្បីយកទៅសម្លាប់ចោល។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជា គ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅដល់ភូមិស្វាយអណ្តូង ក៏ត្រឡប់មកផ្ទះនៅក្នុងភូមិបុស្សីសាញ់វិញ។ ខ្ញុំចាប់ផ្តើមខិតខំរកស៊ីធ្វើស្រែចម្ការដើម្បីចិញ្ចឹមគ្រួសាររហូតដល់ប្អូនៗរបស់ខ្ញុំរៀបការទាំងអស់គ្នា។ ចំណែកខ្ញុំរៀបការនៅ ខែមករា ឆ្នាំ២០០១ ជាមួយប្តីឈ្មោះ អួន អៀប និងមានកូនចំនួន២នាក់ ហើយសព្វថ្ងៃខ្ញុំធ្វើជាអនុភូមិបុស្សីសាញ់។



ស្រេង ហុងគាវ កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ សូ ហាន់ ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហេម ហ៊ីនៈ អតីតពេទ្យសម័យខ្មែរក្រហម

**គាត ស្រីឡែន**



ហេម ហ៊ីន ភេទស្រី អាយុ៦៨ឆ្នាំ រស់នៅភូមិរំចេក ឃុំរំចេកស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហេម ហ៊ីន អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ហេម ហ៊ិន ចំណែកម្តាយឈ្មោះ ប្រាក់ និងមានបងប្អូនបង្កើតចំនួន៧ នាក់ គឺស្រីចំនួន៤ នាក់ និងប្រុសចំនួន៣ នាក់។ បងប្អូនរបស់ខ្ញុំស្លាប់២ នាក់ ដោយម្នាក់បានជាន់គ្រាប់មីនផ្ទុះស្លាប់ពេលទៅឃ្វាលក្របី និងម្នាក់ទៀតស្លាប់ដោយសារជំងឺ។ ខ្ញុំមានប្តីឈ្មោះ ស៊ុនប៉ាន់ និងមានកូនចំនួន៥នាក់។ កូនៗខ្ញុំស្លាប់ពីរនាក់ដោយសារជំងឺ។

កាលពីកុមារ ខ្ញុំរៀននៅសាលាវត្តរំចេក ជាមួយគ្រូ ឈួន។ នៅក្នុងថ្នាក់រៀនមានសិស្សចំនួន២០នាក់។ ពេលព្រឹក ខ្ញុំចូលរៀននៅម៉ោង៧ និងចេញពីរៀននៅម៉ោង៩។ បន្ទាប់ពីចេញពីរៀន ខ្ញុំត្រូវឃ្វាលគោក្របីជាមួយក្មេងៗនៅភូមិ។

នៅពេលនោះមានកងទ័ពវៀតកុងបុយួនខាងជើងបានរស់នៅពេញព្រៃក្បែរៗភូមិ។ មិនយូរប៉ុន្មានក៏មានការទម្លាក់គ្រាប់បែកលើកងទ័ពវៀតកុងទាំងនោះ។ ឃើញហេតុការណ៍ដូច្នេះ តាយាយរបស់ខ្ញុំក៏ហៅខ្ញុំឲ្យចូលពួនក្នុងរណ្តៅត្រង់សេរហូតដល់ឈប់ឮសំឡេងទម្លាក់គ្រាប់បែកទើបខ្ញុំរត់មកផ្ទះវិញ។ នៅឆ្នាំ១៩៧៥ នៅក្នុងភូមិរបស់ខ្ញុំមានបង្កើតជាសហករណ៍ និងប្រមូលចាន ឆ្នាំង ដាក់រួម គឺនៅសល់តែគោ-ក្របីមិនទាន់ដាក់រួម។ បន្ទាប់មកទៀតខ្មែរក្រហមឲ្យប្រជាជនហូបរួម នៅសាលារៀនក្នុងភូមិ។

ខ្មែរក្រហមឲ្យខ្ញុំធ្វើការនៅកងចល័ត គឺ ប្រូតស្រូវ, ដក និង ស្ទូង។ ខ្ញុំក្រោកធ្វើការនៅវេលាម៉ោង៣ភ្លឺ ប៉ុន្តែខ្ញុំមិនអាចស៊ូទ្រាំនឹងការងារដូចចាស់ៗឡើយ ព្រោះខ្ញុំទើបតែអាយុ១៥ឆ្នាំ។ ឪពុករបស់ខ្ញុំគឺជាប្រធានក្រុមខ្ញុំ ហើយរយៈ៣ថ្ងៃខ្មែរក្រហមផ្លាស់ប្តូរប្រធានក្រុមម្តង ដែលប្រធានក្រុមទាំងនោះមានឈ្មោះដូចជា តា តុម, តា អួន, តា ហ៊ិន គឺជាឪពុករបស់ខ្ញុំ។ ក្រុមរបស់ខ្ញុំមានសមាជិកចំនួន១៥នាក់ ជីកប្រឡាយ និងលើកទំនប់ ហើយខ្ញុំធ្វើការនៅភូមិត្នោ។

ក្រោយពេលឪពុកខ្ញុំឈឺ និងបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យស្រោក ខ្ញុំត្រូវបានដកមកធ្វើការនៅពេទ្យស្រុក និងបម្រើឪពុកខ្ញុំនៅទីនោះ។ តាគួង គឺជាអ្នកប្រាប់ឲ្យខ្ញុំមកធ្វើការនៅមន្ទីរពេទ្យស្រោក ហើយខ្ញុំរៀនចាក់ថ្នាំនៅទីនោះ។ ពេលថ្ងៃ តា គួង ចាត់ឲ្យខ្ញុំទៅឃ្វាលក្របីនៅទួល៤ខ។ ចំណែកពេលព្រឹក និងល្ងាចដើរចាក់ថ្នាំឲ្យអ្នកជំងឺ។ ដំបូងខ្ញុំមិនហ៊ានចាក់ថ្នាំឲ្យអ្នកជំងឺឡើយ ដូច្នេះ យាយ ផុន បង្រៀនខ្ញុំពីរបៀបចាក់ថ្នាំ និងការប្រើប្រាស់ថ្នាំដោយផ្ទាល់។ បន្ទាប់មក ខ្ញុំផ្លាស់ទៅរស់នៅស្រែសង្កែរយៈពេល២ខែ ទើបយាយផុន ហៅខ្ញុំទៅរស់ចម្ការកាហ្វេនៅភូមិ ឡូ ព្រោះខ្វះពេទ្យ។ នៅទីនោះមានប្រជាជនឈឺច្រើន ហើយភាគច្រើនកើតជំងឺគ្រុនចាញ់។ មានប្រជាជនច្រើនណាស់ស្លាប់នៅចម្ការកាហ្វេ។ ខ្ញុំធ្វើការនៅទីនោះបានរយៈពេល៤ខែ កងទ័ពវៀតណាមបានវាយចូលមក។

ខ្ញុំត្រឡប់ទៅភូមិរំចេកវិញ ខណៈនោះប្រធានភូមិឈ្មោះ អែម ហោង ប្រាប់ខ្ញុំឲ្យរត់ទៅត្រពាំងរាំង។ ខ្ញុំស្នាក់នៅត្រពាំងរាំងបានរយៈពេល៧ថ្ងៃ ក៏គៀសខ្លួនបន្តទៅស្រែគ្រៀក និងវាលកន្សែង។ ក្រោយមក ខ្ញុំទៅរស់នៅភូមិជីទ្រុន ហើយនៅទីនោះខ្ញុំធ្វើការងារកាប់ពោត ហើយល្ងាចទើបត្រឡប់មកសម្រាកវិញ។ ខ្ញុំធ្វើការងារភូមិជីទ្រុនបានរយៈពេលកន្លះខែឈ្មោះ សំអាង ប្រាប់ឲ្យខ្ញុំត្រឡប់មករស់នៅភូមិរំចេកវិញ។ ប៉ុន្តែខ្ញុំគៀសខ្លួនបន្តទៅដល់ភូមិត្របែក និងខ្នងក្រពើ ហើយពេលនោះបានជួបរថយន្តវៀតណាម។ វៀតណាមបើកអង្ករ មី ឲ្យខ្ញុំនិងប្រជាជនដែលរត់គៀសខ្លួន ហើយឲ្យទៅភូមិរូងជាប់ព្រំដែនវៀតណាម។ ខ្ញុំរស់នៅទីនោះបានរយៈពេល១សប្តាហ៍ ក៏ផ្លាស់ទៅនៅភ្នំដើងអណ្តែងក្នុងប្រទេសវៀតណាម។ នៅទីនោះ ប៉ែន សុវណ្ណ បានកោះហៅប្រជាជនខ្មែរឲ្យទៅចូលរួមពិធីប្រារព្ធនៃថ្ងៃបង្កើតរណសិរ្ស២ធ្នូ ហើយខ្ញុំបានទៅចូលរួមកម្មពិធីមួយព្រឹក។

បន្ទាប់ពីចូលរួមពិធីប្រារព្ធនៃថ្ងៃបង្កើតរណសិរ្ស២ធ្នូរួច ខ្ញុំបានចូលធ្វើកងទ័ពជាមួយវៀតណាម។ ខ្ញុំហ្វឹកហាត់ពីរបៀបប្រយុទ្ធនិងប្រើប្រាស់កាំភ្លើងនៅឡុងយ៉ាវ ដោយមានជនជាតិខ្មែរគឺជាអ្នកបង្រៀន។ ក្រោយមក ខ្ញុំបានចូលរួមពិធីអបអរជ័យជម្នះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅស្តាតអូឡាំពិច ក្នុងទីក្រុងភ្នំពេញ។ បន្ទាប់មក ខ្ញុំទៅជាមួយកងទ័ពនៅព្រៃបន្ទំជិតដើងភ្នំអណ្តែងក្នុងប្រទេសវៀតណាមរយៈពេល២ខែ ប៉ុន្តែដោយសារខ្ញុំនឹកឪពុកម្តាយខ្លាំងពេក ក៏សុំច្បាប់ប្រធានអង្គភាពមកផ្ទះវិញ។ ដំបូងខ្ញុំមកស្នាក់នៅជាមួយមីងនៅក្នុងក្រុងកំពង់ចាមរយៈពេល១០ថ្ងៃ រួចក៏បន្តដំណើរមកមេមត់ ដោយពេលនោះម្តាយរបស់ខ្ញុំមកចាំទទួលខ្ញុំនៅមេមត់។ សំណាងល្អនៅតាមផ្លូវខ្ញុំបានជួបរទេះគោអ្នកស្រុកបរមក ហើយខ្ញុំនិងម្តាយបានសុំអ្នកបររទេះជិះត្រឡប់មកភូមិវិញ។

ពេលមកភូមិកំណើតវិញ ខ្ញុំឈប់ធ្វើទាហាន និងរស់នៅជុំគ្នាជាមួយម្តាយ។ ខ្ញុំរៀបការនៅអាយុ២៤ឆ្នាំ និងប្រកបរបរធ្វើការរកស៊ី ធ្វើចម្ការ ស្រែរហូតមកដល់សព្វថ្ងៃនេះ។




សាលាឃុំរំចេក ស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាយ ទូច៖ ខ្ញុំរស់នៅទាំងភ័យខ្លាច

**មឿន ហាច**



មាយ ទូច អាយុ៧៣ឆ្នាំ រស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាយ ទូច អាយុ៧៣ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិដើមបេង ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ វង និងម្ដាយឈ្មោះគន់ ស៊ុន។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ គឺស្រីចំនួន៤នាក់ និងប្រុសចំនួន៣នាក់។

ពីកុមារភាព ខ្ញុំរៀននៅសាលាដាន់ដន ដល់ថ្នាក់ទី១១សង្គមចាស់។ បន្ទាប់មក ខ្ញុំក៏ឈប់រៀនព្រោះត្រូវនៅមើលថែទាំឪពុកដែលធ្លាក់ពីលើចុងត្នោត។ ក្រៅពីនោះ ខ្ញុំនៅជួយធ្វើស្រែចម្ការឪពុកម្ដាយ។ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៦៩ ជាមួយប្ដីរបស់ខ្ញុំធ្វើជាទាហាន លន់ នល់។ បន្ទាប់ពីរៀនការរួច ខ្ញុំកើតបានកូនប្រុសម្នាក់ឈ្មោះ សម្បត្តិ។

នៅពេលយោធាខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេសកម្ពុជា ខ្ញុំនិងអ្នកភូមិទាំងអស់ត្រូវជម្លៀសឲ្យទៅរស់នៅក្នុងស្រុកតានី។ ខ្ញុំនៅទីនោះបានប្រហែលមួយឆ្នាំ ខ្មែរក្រហមផ្លាស់ខ្ញុំ ឲ្យទៅនៅវត្តសុបិន្តទៀត។ នៅក្នុងរបបខ្មែរក្រហម កម្មាភិបាលបានចាត់តាំងខ្ញុំឲ្យនៅធ្វើការក្នុងកងចាស់ៗ ដកស្ទូងនិងរែកអាចម៍គោដាក់ស្រែ។ កាលនោះ យើងអាចស្នាក់នៅខ្ទមឬក្នុងផ្ទះរបស់យើង ប៉ុន្តែត្រូវហូបបាយរួមនៅក្នុងរោងបាយទាំងអស់គ្នា។

មានថ្ងៃមួយកូនប្រុសរបស់ខ្ញុំឃ្លានបបរពេក ខ្ញុំក៏កាន់ចានទៅសុំបបរពីចុងភៅមកឲ្យកូនៗ អ្នកដួសបបរខឹងក៏យកវែកដែលកំពុងក្តៅខ្លាំងមកវាយត្រូវចំកូនដៃរបស់ខ្ញុំបាក់ ដែលបន្សល់ទុកស្លាកស្នាមរហូតដល់សព្វថ្ងៃ។ ពេលនោះខ្ញុំអាណិតកូនប្រុសរបស់ខ្ញុំខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនអាចរកអាហារឲ្យគាត់ហូបបានទេ។ នៅក្នុងភូមិខ្ញុំឃើញសាកសពមនុស្ស ៣នាក់ដែលខ្មែរក្រហមសម្លាប់ចោល រួចទម្លាក់ចូលក្នុងរណ្តៅតែមួយ។ ខ្ញុំឃើញបែបនេះ ខ្ញុំពិតជាតក់ស្លុតខ្លាំងណាស់ ព្រោះខ្លាចវាសនារបស់ខ្ញុំដូចអ្នកទាំងនោះដែរ។ ខ្ញុំរស់នៅទាំងភ័យខ្លាច។ ខ្ញុំមិនហ៊ាននិយាយស្តី និងមិនហ៊ានតវ៉ាអ្វីឡើយ ព្រោះខ្លាចខ្មែរក្រហមយកទៅវាយចោល។

ក្រោយរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ខ្ញុំបាននាំគ្រួសារត្រឡប់មកផ្ទះនៅភូមិដើមបេងវិញ។ ប៉ុន្តែជាអកុសល ផ្ទះរបស់ខ្ញុំត្រូវភ្លើងឆេះអស់គ្មានសល់ឡើយ។ ដូច្នេះខ្ញុំបានសាងសង់ផ្ទះថ្មីមួយទៀតដើម្បីស្នាក់នៅ។ រយៈពេលបីខែក្រោយមកឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺហើម ព្រោះកាលពីរបបខ្មែរក្រហម ខ្មែរក្រហមឲ្យគាត់ហូបតែបបរប៉ុណ្ណោះ។ ចំណែកប្តីរបស់ខ្ញុំក៏ស្លាប់ដែរ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីទីពីរ។ យើងមានកូន៣នាក់ជាមួយគ្នា។ បន្ទាប់ពីបានឆ្លងកាត់រឿងរ៉ាវជូរចត់ក្នុងរបបខ្មែរក្រហម ធ្វើឲ្យខ្ញុំមានការភ័យខ្លាច ហើយមិនចង់ឲ្យរបបនេះវិលត្រឡប់មកវិញទេ។ សព្វថ្ងៃនេះ ខ្ញុំអាចរស់បានហើយទោះបីជាមិនមានបានដូចគេ ក៏ប៉ុន្តែខ្ញុំមិនភ័យព្រួយរឿងហូបមិនឆ្អែតទៀតទេ។



មាឃ ទូច ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទីន ញ៉ ៖ អតីតកងចល័តវ័យកណ្តាល ក្នុងរបបខ្មែរក្រហម

*អេង ខណ្ឌីកា*



ទីន ញ៉ អាយុ៧០ឆ្នាំ រស់នៅភូមិដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទីន ញ៉ អាយុ៧០ឆ្នាំ រស់នៅភូមិដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំគឺជាដូនជីនៅវត្តដំណាក់ព្រីង។ ខ្ញុំមានប្តីឈ្មោះ ឈៀង ឈាន និងកូនចំនួន៨នាក់(ប្រុស៣ ស្រី១)។ ខ្ញុំកើតនៅភូមិទី៥ ឃុំអំពិលពក ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ សាំង ទីន និងម្តាយឈ្មោះ ពិន ឃឹម។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៧ នាក់។ កាលពីក្មេង ខ្ញុំរៀននៅសាលាវត្តស្វាយតាមឹងត្រឹមថ្នាក់ទី១១ចាស់។ បន្ទាប់មក ខ្ញុំឈប់រៀនដោយសារតែជីវភាពលំបាក និងបានមកជួយធ្វើការងារឪពុកម្តាយនៅផ្ទះ និងមើលគោ។

នៅឆ្នាំ១៩៧០ ខ្ញុំដឹងថាមានរដ្ឋប្រហារ លន់ នល់ កើតឡើង។ បន្ទាប់ពីរដ្ឋប្រហារកើតឡើងមិនយូរប៉ុន្មានផង បាតុកម្មបានផ្ទុះឡើង និងដង្ហែរតាមដងផ្លូវ។ ខ្ញុំក៏បានចូលរួមការដង្ហែរបាតុកម្ម ប៉ុន្តែមិនបានទៅណាឆ្ងាយទេ គឺទៅដល់ពាមជាំង និងបានដើរត្រឡប់មកផ្ទះវិញ។ នៅពេលនោះ ខ្ញុំឃើញអ្នកចូលរួមបាតុកម្មបានចាប់ប្អូនប្រុសរបស់ លន់ នល់ គឺឈ្មោះ លន់ និល។ បាតុករបានវាយដំ និងបណ្តើរ លន់ និល ទាំងហូរឈាមពេញខ្លួន ចេញពីបន្ទាយវ៉ាំងសែង យកទៅសម្លាប់ចោលនៅម្តុំផ្សារអូររាំងឪ។ នៅចុងឆ្នាំ១៩៧០ មានវត្តមានកងទ័ពរំដោះខ្មែរក្រហម

ចូលមកដល់ភូមិ។ ប្អូនប្រុសរបស់ខ្ញុំបានស្ម័គ្រចិត្តចូលព្រៃម៉ាក់គីដើម្បីតស៊ូប្រឆាំងរបបលន់ នល់។ ខ្ញុំត្រៀមរត់ចូលព្រៃម៉ាក់គីដែរ ប៉ុន្តែគ្មានអ្នកនាំទៅ។

នៅឆ្នាំ១៩៧១ ខ្ញុំរៀបការប្តី។ នៅឆ្នាំ១៩៧២ ខ្ញុំបង្កើតបានកូនប្រុសម្នាក់។ នៅភូមិសាស្ត្រអូររាំងឪតែងតែមានយន្តហោះមកទម្លាក់គ្រាប់បែក។ នៅថ្ងៃមួយ យន្តហោះអាដើងបង្កងបានហោះផ្លែលក្រឡឹងចុះឡើងប្រហែល២០នាទី និងបាញ់ផ្សែងជាសញ្ញា។ បន្ទាប់មក យន្តហោះស្ទាបកាត់បានហោះមកទម្លាក់គ្រាប់បែកចាប់ពីម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង៥ល្ងាច។ ខ្ញុំនាំកូនរត់ចូលក្នុងរណ្តៅត្រង់សេ។ នៅឆ្នាំ១៩៧២ ខ្ញុំនិងគ្រួសាររត់ភៀសខ្លួនទៅនៅភូមិមាសស្នេហ៍ ឃុំអំពិលពក ស្រុកកំពង់សៀមវិញ។ រយៈពេល៣ខែក្រោយមក គ្រួសារខ្ញុំបានវិលត្រឡប់មកផ្ទះវិញ។

របហូតដល់ខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យចូលធ្វើការនៅកងចល័តវ័យកណ្តាលដើម្បីទៅធ្វើការងាររួមមាន រែកដី ធ្វើស្រែ និងដាំដំណាំនៅក្នុងភូមិ។ កងចល័តវ័យកណ្តាលមានសមាជិកប្រហែល៤០នាក់ និងមានប្រធានឈ្មោះមិត្តយឿន។ នៅឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវទៅធ្វើការដកស្ទូងស្រូវនៅតាមសហករណ៍ផ្សេងៗ។ នៅឆ្នាំ១៩៧៨ យោធាខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកចាប់ប្រធានកង មេភូមិ និងកម្មាភិបាលមូលដ្ឋានយកទៅសួរចម្លើយ និងសម្លាប់ចោល។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅជ្រែដីសូរបានមួយរយៈ។ ក្រោយមកទៀត ខ្ញុំត្រូវបានអង្គការឲ្យទៅធ្វើការនៅស្រុកពារាំង។ នៅពេលនោះ ខ្ញុំបានប្រកែកមិនទៅ ពីព្រោះប្តីរបស់ខ្ញុំកំពុងតែឈឺនៅពេទ្យ។ ប៉ុន្មានថ្ងៃក្រោយមក ប្តីរបស់ខ្ញុំបានស្លាប់ដោយសារតែគ្មានថ្នាំព្យាបាល។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំឮសំលេងគ្រាប់បាញ់គ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ ពេលនោះ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម និងបន្តជីវិតរស់នៅជាកសិកររហូតមក។



ស្ត្រីកំពុងហាលដំឡូង នៅឃុំពង្រ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រាក់ តាំង ៖ អតីតកងចល័តនៅភូមិភាគបូព៌ា សម័យខ្មែរក្រហម

ឈុំ រ៉ា



ប្រាក់ តាំង បច្ចុប្បន្នរស់នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប្រាក់តាំង ភេទប្រុស កើតនៅឆ្នាំ១៩៤១ នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានម្ដាយឈ្មោះ ជា ហឿន និងឪពុកឈ្មោះ ប្រាក់គុប និងមានបងប្អូនចំនួន ៦នាក់ស្រី២នាក់។ ខ្ញុំគឺជាកូនទី២នៅក្នុងគ្រួសារ។

កាលពីកុមារ ខ្ញុំមិនសូវបានរៀនជាប់លាប់ទេ។ នៅសម័យមុននៅក្នុងភូមិមានផ្ទះប្រជាជនត្រឹមតែ២០ ទៅ៣០ខ្នងប៉ុណ្ណោះ។ ប្រជាជនទាំងអស់នៅក្នុងភូមិរំចេកត្រូវបានបារាំងកេណ្ឌចេញពីភូមិឲ្យទៅរស់នៅខាងកំពង់រាំង ព្រោះមានមេទ័ពរបស់បារាំងម្នាក់ឈ្មោះ ពាំង សេនា ត្រូវបានខ្មែរឥស្សរលួចសម្លាប់ចោល។ ខ្ញុំរស់នៅកំពង់រាំងបានមួយឆ្នាំ ក្រុមខ្មែរឥស្សរចូលមកវាយប៉ុស្តិ៍របស់បារាំងទៀត ចំណែកប្រជាជនដែលមានការភ័យខ្លាចប្រមាណជាង១០០នាក់ បាននាំគ្នាទៅរស់នៅក្នុងព្រៃ។

នៅពេលខ្ញុំអាយុ២៣ឆ្នាំ ខ្ញុំបានរៀបការ និងមានកូនចំនួន៣នាក់។ រហូតដល់ឆ្នាំ១៩៧០ ក៏មានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ពេលនោះនៅក្នុងភូមិរំចេកមិនមានការធ្វើបាតុកម្មឡើយ ព្រោះជាភូមិដាច់ស្រយាល។ ប៉ុន្តែខ្ញុំធ្លាប់បានឮប្រជាជននិយាយយោសនាតៗគ្នាថា "ជយោ សម្ដេចឪអ្នកណាមិនទៅសម្លាប់ចោល"។

ប្រជាជនដែលរស់នៅក្នុងភូមិរំចេកភាគច្រើនធ្វើការងារកាប់ឫស្សី កាប់ឈើ កាប់វល្លិ រកត្រីនិងធ្វើស្រែសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ក្រៅពីនោះប្រជាជនប្រកបមុខរបរធ្វើឈ្នាង ធ្វើទ្រូ ល្អី និងចងសន្ទូច ។ កាលពីមុន នៅក្នុងភូមិសម្បូរសាច់ សម្បូរត្រីណាស់ ប្រជាជនចេញទៅរកតែមួយភ្លែត អាចហូប២ទៅ៣ថ្ងៃមិនទាន់អស់ផង។

នៅក្នុងឆ្នាំ១៩៧០ដដែល នៅក្នុងភូមិរំចេកមានការទម្លាក់គ្រាប់បែកយ៉ាងច្រើនដែលធ្វើឲ្យផ្ទះសម្បែងប្រជាជនចំនួន៣ខ្នងត្រូវភ្លើងឆេះ និងស្លាប់ឈ្មោះ ម៉ន ម្នាក់។ ការទម្លាក់គ្រាប់បែកមិនមានបំណងសម្លាប់ប្រជាជនខ្មែរនោះទេ គឺសំដៅទៅលើកងទ័ពវៀតកុង (វៀតណាមខាងជើង) ព្រោះមានកងទ័ពវៀតកុងច្រើនបានចូលមកលាក់ខ្លួនក្នុងព្រៃនៅឃុំរំចេក។ កងទ័ពវៀតកុងខ្លះបានចូលមកនៅក្នុងភូមិ ប៉ុន្តែមិនបានប៉ះពាល់ប្រជាជនខ្មែរទេ គឺគ្រាន់តែចូលមកសុំកន្លែងស្នាក់នៅ និងរកម្ហូប។ កងទ័ពវៀតកុងមានសម្លៀកបំពាក់ពណ៌ស្វាយចេក ហើយនៅពេលចេញដើរកងទ័ពវៀតកុងទាំងនោះយកស្លឹកឈើមកគ្របលើក្បាល ដើម្បីការពារកុំឲ្យសត្រូវមើលឃើញ។

នៅពេលនោះ ប្រជាជនរស់នៅក្នុងភូមិរំចេកហូបចុក និងរស់នៅតាមផ្ទះរៀងៗខ្លួន។ ប្រជាជនធ្វើការងារប្រវាស់ដៃគ្នាទៅវិញទៅមក ហើយធ្វើទាល់តែរួចរាល់មួយកន្លែង ទើបនាំគ្នាទៅធ្វើមួយកន្លែងទៀត

ដែលជាទូទៅប្រជាជនហៅថា ក្រុមសាមគ្គីគ្នា។ បន្ទាប់ពីធ្វើការងារប្រវាស់ដៃបានមួយឆ្នាំ ស្រាប់តែខ្មែរក្រហមចាប់ផ្តើមប្រមូលប្រជាជនឲ្យហូបរួម។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមជម្លៀសប្រជាជនប្រមាណ២០០នាក់ចេញពីទីក្រុងភ្នំពេញឲ្យមករស់នៅក្នុងភូមិរំចេក ឃុំរំចេក។ ចំពោះនារីៗនៅក្នុងភូមិត្រូវបានជ្រើសរើសឲ្យធ្វើជាគ្រូពេទ្យ ចំណែកប្រុសៗឲ្យចូលធ្វើជាយោធា។ ពេលនោះប្រជាជនជម្លៀសមកពីភ្នំពេញពុំមានផ្ទះសម្រាប់ស្នាក់នៅទេ ដូច្នេះប្រជាជនទាំងនោះត្រូវទៅស្នាក់នៅតាមផ្ទះបណ្តោះអាសន្នជាមួយអ្នកភូមិ។ ផ្ទះរបស់ខ្ញុំក៏មានអ្នកជម្លៀសមកពីភ្នំពេញស្នាក់នៅដែរ ទម្រាំអង្គការសង់ខ្ទមសម្រាប់ប្រជាជនថ្មីរស់នៅ។ ពេលហូបបាយអ្នកជម្លៀសមកថ្មីត្រូវហូបជាមួយប្រជាជនថ្មីដូចគ្នា។ ចំណែកប្រជាជនមូលដ្ឋានហូបជាមួយអ្នកនៅក្នុងភូមិ។ ពេលជម្លៀសមកដល់ដំបូងប្រជាជនថ្មីចាញ់ទឹកដី ហើយឈឺគ្រុនចាញ់ស្លាប់អស់ជាច្រើននាក់ ព្រោះគ្មានថ្នាំសម្រាប់ព្យាបាល។ ប្រជាជនជម្លៀសមកថ្មី និងប្រជាជនមូលដ្ឋានត្រូវចេញទៅធ្វើការគ្មានពេលឈប់សម្រាកឡើយ។ ប្រជាជនថ្មីមកពីភ្នំពេញមិនសូវចេះធ្វើស្រែដូចប្រជាជនមូលដ្ឋានឡើយ យូរៗទៅទើបប្រជាជនថ្មីទាំងនោះអាចធ្វើស្រែបានដូចអ្នកភូមិ។ ប្រជាជនជម្លៀសមកពីភ្នំពេញស្លាប់ច្រើននាក់ណាស់ ដោយសារអត់បាយ គ្រុនចាញ់ និងខ្មែរក្រហមយកទៅសម្លាប់ចោល។ អ្នកស្លាប់ទាំងនោះត្រូវបានខ្មែរក្រហមយកទៅកប់ចោលនៅខាងក្រោយវត្ត។

មួយរយៈក្រោយមក អង្គការចាប់ផ្តើមសួរនាំអ្នកជម្លៀសមកពីភ្នំពេញរកអ្នកដែលមានចំណេះដឹង មានបុណ្យស័ក្តិ និងអតីតអ្នកធ្វើការកាលពីជំនាន់មុនឲ្យទៅរៀនសូត្របន្ថែម និងចូលធ្វើការងារវិញ។ ពេលនោះអ្នកដែលឆ្លើយថា មានស័ក្តិ ធ្វើជាទាហាន លន់ នល់ ធ្វើគ្រូបង្រៀន និងមានចំណេះដឹង ប្រមាណ៤០នាក់ត្រូវខ្មែរក្រហមចាប់ខ្លួន និងយកទៅវាយទម្លាក់នៅក្នុងអណ្តូង គឺមានតែមនុស្សពីរនាក់ប៉ុណ្ណោះបានរត់រួចខ្លួន ហើយត្រឡប់មកនៅក្នុងភូមិវិញ។

ចំណែកខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាមេក្រុម ប៉ុន្តែខ្ញុំបានប្រកែកព្រោះខ្ញុំមិនចេះប្រើមនុស្ស ហើយម្យ៉ាងទៀតខ្ញុំមិនចេះអក្សរ។ ខ្មែរក្រហមមិនបានរករឿងខ្ញុំទេ ហើយជ្រើសរើសអ្នកផ្សេងទៀតឲ្យធ្វើជាប្រធានក្រុម។ ក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការនៅកងចល័ត និងលើកទំនប់នៅបឹងក្រចាប់នៅតំបន់២១ ហើយប្រសិនបើប្រជាជនណាប្រកែកមិនទៅតាមការចាត់តាំង អង្គការនឹងយកទៅសម្លាប់ចោលភ្លាមៗ។ ពេលនោះប្រជាជនមកពីគ្រប់ស្រុកបានទៅលើកទំនប់នៅបឹងក្រចាប់។ នៅទីនោះពុំមានអាហារហូបចុកគ្រាប់គ្រាន់ទេ គឺក្នុងមួយថ្ងៃមានតែរបបអាហារពីរពេលតែប៉ុណ្ណោះ គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ ក្នុងមួយថ្ងៃប្រជាជនត្រូវតែធ្វើឲ្យហើយរួចរាល់លើផ្ទៃដីដែលអង្គការបានកំណត់។ សម្រាប់ខ្ញុំអាចធ្វើបាន ប៉ុន្តែមានអ្នកផ្សេងនៅក្នុងក្រុមជាមួយគ្នាធ្វើមិនរួច ដូច្នេះដល់ពេលម៉ោងហូបបាយគឺអង្គការអត់ឲ្យគាត់ហូបទេ។ ខ្ញុំជីកប្រឡាយនៅបឹងក្រចាប់រយៈពេល៤ខែ។

ក្រោយមក កម្មាភិបាល និងកងទ័ពមកពីខាងនិរតីចូលមកនិងមានការវាយប្រយុទ្ធគ្នា ធ្វើឲ្យប្រជាជនមានការច្របូលច្របល់។ ពេលនោះខ្ញុំបានរត់ត្រឡប់មកផ្ទះធ្វើស្រែជាមួយប្រជាជននៅក្នុងភូមិវិញ។ ខ្ញុំមកនៅផ្ទះបានមួយខែ កងទ័ពមជ្ឈិមចូលមកទៀត ធ្វើឲ្យប្រជាជនរស់នៅភូមិភាគបូព៌ារត់ចូលព្រៃលាក់ខ្លួន ហើយខ្លះទៀតបានគេចខ្លួនទៅប្រទេសវៀតណាម។ ពេលនោះ ប្រជាជនទៅដេកនៅព្រំដែនមួយយប់ បន្ទាប់មកកងទ័ពវៀតណាមយកឡានមកដឹកប្រជាជនទាំងនោះទៅដាក់នៅជើងអណ្តែង។ វៀតណាមចែកអង្ករ ម្ហូប ស្រូវសាឡី ឲ្យប្រជាជនហូបចុកគ្រប់គ្រាន់។ ខ្ញុំរស់នៅប្រទេសវៀតណាមរយៈពេល៤ខែ ក្រោយមកវៀតណាមបានបញ្ជូនខ្ញុំនិងប្រជាជនភៀសខ្លួនត្រឡប់មកស្រុកកំណើតវិញ។ ពេលមកភូមិវិញ ផ្ទះសម្បែងខ្លះបានបាក់បែកស្ទើរតែទាំងអស់ ចំណែកផ្ទះខ្ញុំមិនមានខូចឡើយ។ ក្រោយមកខ្ញុំចាប់ផ្តើមកាប់ឆ្ការព្រៃដាំដំណាំ និងធ្វើស្រែទម្រាំមានអាហារហូបគ្រប់គ្រាន់។ នៅក្នុងរបបខ្មែរក្រហមប្អូនរបស់ខ្ញុំម្នាក់ឈ្មោះ ប្រាក់ សឿន ត្រូវបានខ្មែរក្រហមចាប់ធ្វើជាទាហាន ហើយត្រូវបានខ្មែរក្រហមសម្លាប់ចោល។

# គឿម ជនៈ កងកុមារក្នុងរបបខ្មែរក្រហម

**យន់ ឃីម**



គឿម ជន អាយុ៥៩ឆ្នាំ គឺជាកសិករ រស់នៅភូមិប្រាសាទ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ យន់ ឃីម អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តសៀមរាប។ (យន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គឿម ជន ភេទស្រី អាយុ៥៩ឆ្នាំ គឺជាកសិករ រស់នៅភូមិប្រាសាទ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ ប្តីរបស់ខ្ញុំឈ្មោះ អ៊ូ សុខបាន ស្លាប់កាលពី២០ឆ្នាំមុន។ សព្វថ្ងៃខ្ញុំគឺជាស្រ្តីមេម៉ាយ និងមានកូនចំនួន៦នាក់។ ឪពុករបស់ខ្ញុំឈ្មោះ សួន គឿម និង ម្តាយឈ្មោះ មាស ជូ។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ហើយខ្ញុំគឺជាកូនច្បងក្នុងគ្រួសារ។ នៅពេលខ្ញុំធំដឹងក្តីបន្តិច ខ្ញុំត្រូវទូលដំឡូងទៀន ដំឡូងជ្វា ដំឡូងគ និងចេកលក់ ប្តូរយកអង្ករនិងស្រូវពីអ្នកភូមិមកដាំហូប នៅពេលគ្រួសារខ្ញុំមិនមានអង្ករគ្រប់គ្រាន់។

នៅឆ្នាំ១៩៧០ គ្រួសារខ្ញុំធ្វើស្រែចម្ការប៉ុន្តែជីវភាពគ្រួសារកាន់តែយ៉ាប់យ៉ឺនទៅៗ។ នៅដើមឆ្នាំ១៩៧០ដដែល ខ្ញុំបានឆ្លៀតចូលរៀននៅសាលាដែលស្ថិតនៅក្នុងវត្តជាមួយក្មេងៗនៅក្នុងភូមិធ្វើឲ្យខ្ញុំអាចអានអក្សរខ្លះ។ កាលនោះមានគ្រូវ័យចំណាស់ម្នាក់ គឺជាអ្នកបង្រៀនខ្ញុំនិងក្មេងៗក្នុងភូមិ ហើយគាត់គឺជាគ្រូដ៏ល្អ។ គ្រូបានខិតខំបង្រៀនសិស្សឲ្យចេះអានអក្សរគ្រប់ៗគ្នា។ នៅពេលខ្មែរក្រហមចូលមកដល់ក្នុងភូមិ ខ្ញុំលែងបានរៀនទៀតហើយ ចំណែកគ្រូរបស់ខ្ញុំក៏ដឹងមិនទៅដល់ទីណាដែរ។

នៅដើមឆ្នាំ១៩៧៥ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំមិនទាន់ផ្លាស់ទៅណាទេ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៥ ទើបខ្មែរក្រហមចាប់ផ្តើមជម្លៀស

អ្នកភូមិ រួមទាំងគ្រួសាររបស់ខ្ញុំចេញ។ ខ្ញុំត្រូវបានចាត់តាំងទៅស្រុកវ៉ារិនដើម្បីលើកទំនប់គោកស្រុក។ កាលនោះខ្ញុំមានអាយុប្រហែល១២ឆ្នាំ ត្រូវរែកដីចាក់លើខ្នងទំនប់គោកស្រុក បន្ទាប់មកទើបត្រឡប់មកធ្វើស្រែនៅក្នុងភូមិវិញ។ រហូតដល់អាយុ១៨ឆ្នាំ ខ្ញុំត្រូវចល័តទៅស្រុកវ៉ារិនលើកទំនប់គោកស្រុកម្តងទៀត។ បន្ទាប់ពីលើកទំនប់គោកស្រុករួចរាល់ខ្ញុំនិងគ្រួសារចល័តទៅធ្វើស្រែចម្ការនៅភ្នំបាយដុស។ នៅទីនោះ ខ្ញុំនិងគ្រួសារស្ទើរតែបាត់បង់ជីវិតដោយសារខ្មែរក្រហមចោទថាជាខ្មាំង ប៉ុន្តែសំណាងល្អខ្ញុំបាននាំឪពុកម្តាយ និងប្អូនរត់គេចខ្លួន។ អំឡុងពេលរត់គេចខ្លួន ម្តាយ និងឪពុករបស់ខ្ញុំ មានជំងឺដោយម្តាយរបស់ខ្ញុំអាចដើរបានជិតៗ ចំណែកឪពុកខ្ញុំឈឺធ្ងន់ដូច្នេះត្រូវលើកគាត់ដាក់លើរទេះឈើគ្មានកង់ដើម្បីអូសចេញទៅ។ យើងជិតនឹងត្រូវខ្មែរក្រហមចាប់បាននៅបាក់រនាស់ ប៉ុន្តែខ្ញុំបានយកឪពុកនិងម្តាយរបស់ខ្ញុំទៅលាក់ក្នុងព្រៃ ហើយប្អូនដែលពរនៅបីដាប់នឹងដៃរួមជាមួយនឹងអ៊ីវ៉ាន់លាក់ទុកនៅគុម្ពោធព្រៃម្ខាងទៀត។ បន្ទាប់ពីខ្មែរក្រហមដើរចេញទៅផុត ខ្ញុំទៅយកឪពុកម្តាយ ប្អូន និងរបស់របរបន្តដំណើរទៅមុខទៀត។ នៅពេលឃ្លានម្តងៗខ្ញុំ និងគ្រួសារមិនមានបាយសម្រាប់ហូបឡើយ គឺមានតែដំឡូងដុត។

គ្រួសាររបស់ខ្ញុំបានធ្វើដំណើរមកដល់ភូមិវិញ ពេលនោះប្រធានសហករណ៍ប្រកាសថា ប្រជាជនមកពីភូមិណាទៅនៅកន្លែងនោះវិញ។ កាលនោះស្រុកកំណើតរបស់ឪពុកខ្ញុំនៅនគរភាស ស្ថិតនៅក្នុងអង្គរជុំ ដូច្នេះគ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅកាន់ទីនោះ។ ទៅដល់នគរភាស គ្រួសារខ្ញុំត្រូវបំបែកឲ្យទៅធ្វើការរៀងៗខ្លួន នៅសល់តែឪពុករបស់ខ្ញុំដែលឈឺនៅផ្ទះជាមួយប្អូនរបស់ខ្ញុំ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើជីដាក់ស្រែ កាប់ដីដំបូកទម្លាក់ចូលក្នុងរណ្តៅដើម្បីច្របល់ចូលគ្នាជាមួយអាចម៍គោ និងលាមកមនុស្ស។ យើងច្របល់វាឲ្យចូលគ្នាហើយទើបយកវាទៅចាក់លើពុម្ពហើយហាលថ្ងៃឲ្យស្ងួត បន្ទាប់មកយើងយកវាទៅដាក់ក្នុងជំរំដើម្បីទុកដាក់ស្រែ។ ម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែ ស្ទូងស្រូវ ប៉ុន្តែបើម្តាយខ្ញុំស្ទូងមិនហើយតាមផែនការ អង្គការមិនឲ្យឈប់សម្រាកជាដាច់ខាត។ ដូច្នេះពេលខ្ញុំធ្វើជីរួចរាល់ ខ្ញុំតែងតែមកជួយស្ទូងម្តាយជានិច្ចដោយមានការអនុញ្ញាតពីប្រធានសហករណ៍។ ចំណែកឪពុករបស់ខ្ញុំ ទោះបីគាត់ឈឺក៏គាត់ខំប្រឹងដើរទៅយករបបអាហារមកទុកហូប ប្រសិនបើគាត់ទៅមិនទាន់ម៉ោងទេគឺគ្មានអាហារហូបឡើយ។

ខ្ញុំធ្វើការនៅខាងផលិតជីបានមួយរយៈ ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅដេញសេកនៅស្រែក្រុង និងអំពៅបីដើម នៅពេលស្រូវជិតទុំ។ ពេលខ្ញុំត្រឡប់មកជិតដល់ទីរួមស្រុកពួកវិញ ស្រាប់តែខ្មែរក្រហមប្រមូលខ្ញុំនិងក្មេងៗឲ្យចូលក្នុងជំរំ ព្រោះនៅខាងក្រៅមានការវាយប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហម។ ខ្ញុំបានស្នាក់នៅក្នុងជំរំមួយយប់។ នៅពេលកងទ័ពវៀតណាមដេញយោធាខ្មែរក្រហមចេញទៅអស់ ខ្ញុំក៏ចេញពីជំរំមកខាងក្រៅវិញ។ កងទ័ពវៀតណាមបានដាំបាយ២០ឆ្នាំងសម្រាប់ឲ្យខ្ញុំនិងក្មេងៗហូប។ បន្ទាប់មកខ្ញុំបានជួបឪពុកម្តាយ និងបងប្អូនវិញ ហើយនាំគ្នាត្រឡប់មករស់នៅភូមិប្រាសាទវិញ។ នៅពេលខ្ញុំមានអាយុ២២ឆ្នាំ ខ្ញុំបានរៀបការបែកចេញពីឪពុកម្តាយ និងបានប្រកបរបរធ្វើស្រែចម្ការរហូតមកដល់បច្ចុប្បន្ន។




សាលាឃុំជប់តាត្រាវ ស្ថិតនៅក្នុងស្រុកអង្គរធំ ខេត្តសៀមរាប។
(យន់ ឃីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ងួន ខេន ៖ ខ្មែរក្រហមបានអូសទាញ និង គិះដៀល ថាយើងជាមនុស្សកំសាកញីប្រសិនបើមិនចូលរួមជាមួយចលនាគស៊ូ

ស្ងួត វិចិត្រ



ងួន ខេន នៅផ្ទះរបស់គាត់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ងួន ខេន អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកស្ទោង ខេត្តកំពង់ធំ។ បច្ចុប្បន្នខ្ញុំរស់នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ នៅជំនាន់ខ្មែរក្រហម ខ្ញុំធ្លាប់ធ្វើជាកងទ័ព និងកងចល័ត។ ខ្ញុំចូលបម្រើជាកងទ័ពខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧១ នៅពេលដែលប្រជាជននៅក្នុងឃុំរបស់ខ្ញុំចាប់ផ្តើមចលាចលក្រោយ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ។ យុវជន-យុវនារីភាគច្រើននៅក្នុងឃុំរបស់ខ្ញុំ បានចូលរួមនៅក្នុងចលនានេះ ហើយមនុស្សតិចតួចបំផុតដែលមិនចូលរួម។

ខ្មែរក្រហមបានអូសទាញ និងតិះដៀលថាយើងជាមនុស្សកំសាកញី និងអន់ជាងនារីទៅទៀត បើកាលណាមិនចូលរួមក្នុងចលនាតស៊ូរបស់ខ្លួន។ ស្ថានភាពបែបនេះ បង្ខំឲ្យខ្ញុំនិងយុវជនផ្សេងទៀតក្នុងភូមិនាំគ្នាចូលរួមទៅក្នុងចលនាខ្មែរក្រហម។ ភ្លាមៗបន្ទាប់ពីចូលទៅក្នុងចលនានេះ យុវជនម្នាក់ៗមិន

ទទួលបានការបង្ហាត់បង្រៀនអំពីយុទ្ធសាស្ត្រកងទ័ព និងសូម្បីតែការហាត់បាញ់កាំភ្លើង។ ខ្ញុំបានតស៊ូនិងវាយប្រយុទ្ធតទល់ជាមួយនឹងទាហានលន់នល់នៅក្នុងសមរភូមិខេត្តកំពង់ធំ ក្រោមការគ្រប់គ្រងរបស់ ឆន មេបញ្ជាការ តំបន់៤០៥ អស់រយៈពេលពីរឆ្នាំ។

ក្រោយមក ខ្ញុំត្រូវផ្លាស់ទៅឈរជើងនៅខេត្តកំពង់ចាម បន្ទាប់ពីយោធាខ្មែរក្រហមទទួលជ័យជម្នះទាំងស្រុងនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្លាំងរបស់ខ្ញុំត្រូវបានផ្ទាក់លើរំសាយចេញពីអង្គភាពទ័ព ហើយបញ្ជូនទៅធ្វើការងារបង្កបង្កើនផលស្រូវដូចប្រជាជនផ្សេងទៀតនៅក្នុងតំបន់នោះដែរ។ ការងាររបស់ខ្ញុំមមាញឹកខ្លាំងណាស់ ហើយការហូបចុកមិនមានភាពប្រសើរឡើយ។ ចុងភៅបានបបរដើមចេក និងគល់ល្ហុងឲ្យយើងហូប ដោយក្នុងម្នាក់ទទួលបានបបរមួយចានក្នុងមួយពេល។ គ្មានប្រជាជនណាម្នាក់ហ៊ានរអ៊ូរទាំ និងប្រកែកតវ៉ាឡើយ។ មិត្តៗនៅក្នុងក្រុមបាននាំគ្នាទៅរើសផ្លែត្នោតទុំមកហូប ប៉ុន្តែដោយសារមិនសូវមានត្នោតទុំជ្រុះមកច្រើន ទើបមិត្តៗទាំងនោះឆ្លាស់គ្នាជញ្ជាក់ផ្លែត្នោតដែលរើសបានម្នាក់ម្តងៗ។ ភាពអត់ឃ្លានបែបនេះបានបណ្តាលឲ្យប្រជាជនមួយចំនួនមានសភាពស្គមស្គាំង និងមិនសូវមានកម្លាំងធ្វើការងារឡើយ។ ប្រជាជនភាគច្រើនដួលសន្លប់ពេលកំពុងធ្វើការ ហើយត្រូវបញ្ជូនទៅសង្គ្រោះបន្ទាន់ជាបន្តបន្ទាប់។ មិនត្រឹមតែភាពអត់ឃ្លានប៉ុណ្ណោះទេ ខ្ញុំឃើញមានការកត់ប្រវត្តិរូប និងយកមនុស្សទៅរៀនសូត្រទៀតផង។

ខ្ញុំធ្វើការនៅទីនោះរហូតកងទ័ពវៀតណាមវាយចូលមកនៅដើមឆ្នាំ១៩៧៩ ទើបខ្ញុំផ្លាស់មករស់នៅខេត្តឧត្តរមានជ័យរហូតមកដល់សព្វថ្ងៃ។



ង៉ួន ខេន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅអំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅខែកញ្ញា ឆ្នាំ២០២២ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាស វេន៖ កម្មករនៅឃ្លាំងរដ្ឋជ្រោយចង្វារ

***ហ៊ាន ពិសី***



មាស វេន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ ហ៊ាន ពិសី បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាស វេន អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកកងមាស ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ខ្ញុំត្រូវខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាពេទ្យតាំងពីឆ្នាំ១៩៧៣។ ខ្ញុំរៀនវិជ្ជាពេទ្យនៅមន្ទីរពាមជីកងដោយមានឈ្មោះ យ៉ាត គឺជាអ្នកបង្រៀន ហើយមានឈ្មោះ វេន និង សម គឺជាប្រធានពេទ្យនៅទីនោះ។ ការរៀនគឺទៅតាមផ្នែកផ្សេងៗពីគ្នាចំណែកខ្ញុំនៅខាងផ្នែកផ្សំថ្នាំ និងចាក់ថ្នាំ។ ការព្យាបាលនៅអំឡុងពេលនោះយើងមានថ្នាំពេទ្យគឺមិនមានថ្នាំបុរាណទេ ហើយអ្នកជំងឺភាគច្រើន ឈឺគ្រុនផ្តាសាយ ក្តៅខ្លួន ឬរបួសតិចតួចពុំសូវមានជំងឺធ្ងន់ធ្ងរទេ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៤ ខ្មែរក្រហមបញ្ជូនក្រុមពេទ្យឲ្យមកព្យាបាលខាងភ្នំបាសិត ព្រោះនៅទីនោះកងទ័ពរបួសច្រើនណាស់ដោយសារសង្គ្រាម។ ក្រុមគ្រូពេទ្យត្រូវធ្វើការឆ្លាស់គ្នាដើម្បីសែងអ្នករបួសដែលបញ្ជូនមកពីសមរភូមិមុខ។ អ្នកខ្លះរបួសស្រាលខ្លះរបួសធ្ងន់រហូតដាច់ដៃជើងក៏មាន។

លុះដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមទទួលជ័យជម្នះនៅទីក្រុងភ្នំពេញ ខ្ញុំត្រូវបានផ្លាស់ឲ្យមកធ្វើការនៅឃ្លាំងរដ្ឋជិតស្ពានជ្រោយចង្វារវិញ។ អំឡុងពេលខ្ញុំចូលទៅដល់ក្នុងទីក្រុង

ភ្នំពេញដំបូងគឺស្ងប់ស្ងាត់ណាស់ គឺមានតែក្រុមយោធាដែលឈរយាមនៅតាមផ្លូវប៉ុណ្ណោះ។ ចំណែកប្រជាជនត្រូវជម្លៀសចេញអស់។ ពេលទៅដល់ឃ្លាំងរដ្ឋ ខ្មែរក្រហមបង្គាប់ឲ្យខ្ញុំធ្វើការបោសសម្អាតជាមុនសិន។ បន្ទាប់មកទើបខ្ញុំឃើញមានឡានដឹកអំបិល ស្រូវ កៅស៊ូ យកមកដាក់ក្នុងឃ្លាំង។ ស្រូវទាំងអស់ត្រូវកិនទៅជាអង្ករ ហើយជ្រើសរើសយកតែអង្ករណាដែលល្អលេខមួយ ទុកសម្រាប់បញ្ជូនទៅលក់នៅប្រទេសចិន តាមរយៈកប៉ាល់ធំៗ។ ចំណែកការងារនារីៗគឺមិនសូវលំបាកទេនៅពេលនោះ ភាគច្រើនគឺជួយជួសបាវណាដែលដាច់រហែក ប្រសិនបើខ្វះកម្លាំងលើកស្រូវអង្ករ នារីជួយសែងខ្លះៗដែរ។ ខ្ញុំរស់និងធ្វើការនៅឃ្លាំងរដ្ឋរហូតដល់ឆ្នាំ១៩៧៨ ទើបខ្មែរក្រហមរៀបចំឲ្យខ្ញុំមានប្តី និងក្រោយមកមានកូនចំនួនពីរនាក់។

នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចាប់ផ្តើមវាយលុកចូលមកប្រទេសកម្ពុជា ខ្ញុំនិងគ្រួសារបានភៀសខ្លួនមករស់នៅភ្នំដងរែកដែលមានតាម៉ុក គឺជាអ្នកគ្រប់គ្រងនិងផ្គត់ផ្គង់ស្បៀងអាហារ។ ចាប់ពីពេលនោះមកស្ត្រីៗណាដែលមានគ្រួសារ និងមានកូនត្រូវនៅសមរភូមិក្រោយដើម្បីថែទាំកូនៗ ចំណែកអ្នកនៅលីវគឺជួយដឹកជញ្ជូនស្បៀង និងគ្រាប់ឲ្យកងទ័ពនៅសមរភូមិមុខទៅតាមសមត្ថភាពដែលខ្លួនអាចធ្វើបានដោយពុំមានការបង្ខិតបង្ខំឡើយ។ នៅឆ្នាំ១៩៨៩ ទើបខ្ញុំនិងគ្រួសារចុះមករស់នៅស្រុកត្រពាំងប្រាសាទ។ ចំណែកប្តីរបស់ខ្ញុំដែលជាកងទ័ពនៅតស៊ូជាមួយខ្មែរក្រហមនៅអន្លង់វែងបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៨ បន្ទាប់មកគាត់ឈប់ពីកងទ័ពមករស់នៅជុំគ្រួសារវិញ។



មាស វេន និងចៅស្រី នៅពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅខែកញ្ញា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ
អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!















# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
## ទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

*អេង វណ្ណីកា និង ទូច វណ្ណេត*



គាន់ ជៀប អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃពុធ ទី១៤ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩:៣០នាទីព្រឹក ទូច វណ្ណេត និងអេង វណ្ណីកា បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលស្វាគមន៍លោក គាន់ ជៀប អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

ជាកិច្ចចាប់ផ្តើម អេង វណ្ណីកា ធ្វើបទបង្ហាញស្តីពីពិព័រណ៍រូបថតប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជនដោយបង្ខំ និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចងក្រងដោយ



គាន់ ជៀប កំពុងមើលផ្ទាំងពិព័រណ៍រូបថតនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកស្ម័គ្រចិត្តកម្ពុជា ដែលត្រូវបានរៀបចំដាក់តាំងបង្ហាញនៅបរិវេណខាងមុខនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និង ក្នុងសាលពិព័រណ៍។

បន្ទាប់ពីការដើរទស្សនាពិព័រណ៍រូបថតបានបញ្ចប់ ទូច វណ្ណេត បង្ហាញលោក គាន់ ជៀប អំពីបន្ទប់បណ្ណសារដែលមានតម្កល់ឯកសារ ទាក់ទងរបបខ្មែរក្រហមជាច្រើន។ គាន់ ជៀប បានអាន និងស្នើសុំឯកសារមួយចំនួនដើម្បីយកទៅធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត។ ជាចុងក្រោយ គាន់ ជៀប បានសរសេរចំណាប់អារម្មណ៍ថា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំបានល្អ និងសំណូមពរឲ្យមានបុគ្គលិកជំនាញជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវ និងជួយស្វែងរកឯកសារ។



អេង វណ្ណីកា កំពុងបង្ហាញផ្ទាំងពិព័រណ៍រូបថតទៅកាន់ គាន់ ជៀប។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា
## ទស្សនកិច្ចសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ នៃប្រទេសកម្ពុជា

***សោម ប៊ុនថន***



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនកិច្ចសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ (ព្រះឆ្លាំសាននវវ្ន័) នៃប្រទេសកម្ពុជា នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា៣២នាក់ ទស្សនកិច្ចសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុនៃប្រទេសកម្ពុជា ដើម្បីស្វែងយល់អំពីប្រវត្តិនៃការប្រើប្រាស់រូបបិយវត្ថុនៃប្រទេសកម្ពុជា។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបែងចែកចេញជាពីរក្រុម និងមានមគ្គុទ្ទេសក៏២នាក់របស់សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុនៃប្រទេសកម្ពុជាធ្វើបទបង្ហាញ។

ទស្សនកិច្ចនេះមានរយៈពេលពីរម៉ោង គឺចាប់ពីម៉ោង១០ ដល់ម៉ោង១២ថ្ងៃត្រង់ ហើយជាកិច្ចចាប់ផ្ដើម មគ្គុទ្ទេសក៍នាំបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទៅទស្សនាវិដេអូឯកសារខ្លីដែលលើកឡើងអំពីចក្ខុវិស័យនៃសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុនៃប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីផ្ដល់នូវទស្សនវិស័យ ទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ព្រមទាំងផ្ដល់នូវការយល់ដឹងដល់សាធារណជនកាន់តែច្បាស់អំពីទំនាក់ទំនងរវាងសេដ្ឋកិច្ច រូបិយវត្ថុ និងនយោបាយ

របស់ប្រទេសកម្ពុជា ចាប់តាំងពីសម័យហ្វូណនរហូតមកដល់បច្ចុប្បន្ន។

សារមន្ទីរនេះត្រូវបានបែងចែកជា១២ទីតាំងខុសៗគ្នា ដែលបង្ហាញអំពីហេតុការណ៍ និងមេរៀនសំខាន់ៗដែលបានដកស្រង់ចេញពីសេដ្ឋកិច្ច និងប្រវត្តិរូបិយវត្ថុរបស់ប្រទេសកម្ពុជា និងបង្ហាញអំពីទំនាក់ទំនងដ៏ស្មុគស្មាញរវាងរូបិយវត្ថុឥណទានកំណើនសេដ្ឋកិច្ច អតិផរណា ជាដើម។

វត្ថុជាច្រើនដែលដាក់តាំងនៅក្នុងសារមន្ទីរនេះគឺប្រមែប្រមូលបានពីការធ្វើកំណាយ និងការស្រាវជ្រាវដែលរួមមាន របស់របរប្រើប្រាស់ ក្អម ចាន ឆ្នាំងធ្វើអំពីដីដុត គ្រឿងអលង្ការ កាក់ធ្វើអំពីមាស និងលោហធាតុម៉ាស៊ីនបោះពុម្ពកាក់ ព្រមជាមួយក្រដាស់ប្រាក់ដែលអាណានិគមនិយមបារាំង បោះពុម្ពដើម្បីប្រើប្រាស់នៅក្នុងតំបន់ឥណ្ឌូចិនរួមមានប្រទេសកម្ពុជា ឡាវ និងប្រទេសវៀតណាម។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ធនាគាជាតិកម្ពុជាត្រូវបានបង្កើតឡើង ហើយរូបិយវត្ថុប្រាក់រៀលកម្ពុជាក៏ត្រូវបានបោះពុម្ពឡើងដើម្បីប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដែលបានជំរុញឲ្យមានការលូតលាស់យ៉ាងខ្លាំងក្លាលើវិស័យធនាគារឥណទាន ពាណិជ្ជកម្ម និងសេដ្ឋកិច្ច។ ប៉ុន្តែការប្រើប្រាស់រូបិយវត្ថុរបស់ប្រទេសកម្ពុជាត្រូវបានលុបបំបាត់ចោលទាំងស្រុង នៅពេលរបបខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មិនត្រឹមតែប៉ុណ្ណោះ របបខ្មែរក្រហមបានបំផ្លាញស្ទើរតែស្រុងនូវហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សរបស់កម្ពុជា។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រូបិយវត្ថុប្រទេសកម្ពុជាត្រូវបានបោះពុម្ព និងដាក់ឲ្យប្រើប្រាស់នៅលើទីផ្សារឡើងវិញ។

តាមរយៈដំណើរទស្សនកិច្ចនេះ ធ្វើឲ្យបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាយល់ដឹងកាន់តែច្រើនអំពីសារសំខាន់នៃការប្រើប្រាស់រូបិយវត្ថុរបស់ប្រទេសកម្ពុជា នៅខណៈពេលដែលប្រទេសកម្ពុជាកំពុងជំរុញឲ្យមានប្រើប្រាស់រូបិយវត្ថុ ឬប្រាក់រៀលកម្ពុជាឲ្យកាន់តែទូលំទូលាយ ។



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនកិច្ចសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តកំពង់ចាម ចូលរួមស្តាប់និងទស្សនាការប្រកាសសាលដីកា ខៀវ សំផន

**ទូច វណ្ណាត**



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីស្រុកកំពង់សៀម មកចូលរួមស្តាប់និងទស្សនាការផ្សាយបន្តផ្ទាល់ការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង ខៀវ សំផន របស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម កាលពីវេលាម៉ោង៩:៣០នាទីព្រឹក ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលស្វាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីស្រុកកំពង់សៀម មកចូលរួមស្តាប់និងទស្សនាការផ្សាយបន្តផ្ទាល់ការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង ខៀវ សំផន របស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់ពីវេលាម៉ោង៩:៣០នាទីព្រឹក ដល់ម៉ោង១២:០០នាទី ថ្ងៃត្រង់។

នៅចុងបញ្ចប់នៃសវនាការ អង្គជំនុំជម្រះតុលាការកំពូលប្រកាសសម្រេចដាក់ពន្ធនាគារ ខៀវ សំផន អស់មួយជីវិតក្នុងសំណុំរឿង០០២/០២ ដែលត្រូវអនុវត្តត្រួតគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង០០២/០១ កន្លងមក។ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឲ្យ ខៀវ សំផន ត្រូវស្ថិតនៅ

ក្នុងមន្ទីរឃុំឃាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញលេញ និងការបញ្ចប់នូវការរៀបចំសម្រាប់ផ្ទេរដោយអនុលោមតាមច្បាប់ទៅពន្ធនាគារ ដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលចូលរួមស្តាប់និងទស្សនាការប្រកាសសាលដីការបស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញនូវការយល់ឃើញដូចខាងក្រោម ៖

ខ្ញុំឈ្មោះ គុង ស៊ីថាត់ អាយុ៦៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបច្ចុប្បន្នរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមិនដែលមើលការប្រកាសសាលដីកា និងការកាត់ទោសមេដឹកនាំខ្មែរក្រហមពីមុនមកទេ។ ខ្ញុំឃើញមានការលើកឡើងជាច្រើនអំពីបទឧក្រិដ្ឋរបស់ ខៀវ សំផន។ ខ្ញុំឯកភាពថា ការកាត់ទោសរបស់មេដឹកនាំខ្មែរក្រហម គឺពិតជាត្រឹមត្រូវ។ ខ្ញុំយល់ថា លោក ខៀវ សំផន ទទួលទោសនូវអ្វីដែលគាត់បានសាងពីមុនមកគ្រប់យ៉ាងទាំងអស់។

ខ្ញុំឈ្មោះ បួន ឈុនឡោម អាយុ៦៧ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបច្ចុប្បន្នរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមិនដែលធ្លាប់មើលការកាត់ទោសមេដឹកនាំខ្មែរក្រហមនោះឡើយ។ ខ្ញុំឃើញ ខៀវ សំផន នៅក្នុងតុលាការខ្មែរក្រហមជាលើកដំបូង គឺនៅពេលនេះតែម្តង។ ខ្ញុំឃើញ ខៀវ សំផន មានសភាពជរា និងធាត់។ ខ្ញុំនឹកឃើញបទពិសោធន៍ដែលខ្ញុំឆ្លងកាត់ក្នុងរបបខ្មែរក្រហម គឺវេទនាខ្លាំងណាស់។ នៅពេលដែលខ្ញុំឃើញមានបរទេសនៅក្នុងបន្ទប់សវនាការ ខ្ញុំយល់ថា នេះជាការល្អដែលមានការដឹងឮជាអន្តរជាតិ។ ខ្ញុំមិនយល់ស្របចំពោះការលើកឡើងរបស់លោកខៀវ សំផន ថាគាត់មិនបានដឹងឮ និងទទួលស្គាល់អំពើរបស់គាត់ក្នុងរបបខ្មែរក្រហមទេ។ ប្រជាជនក្មេងចាស់បានស្លាប់ និងរងទុក្ខវេទនាខ្លាំងណាស់នៅពេលនោះ។

ខ្ញុំឈ្មោះ ឃួង យុន អាយុ៧៧ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបច្ចុប្បន្នរស់នៅភូមិគគរ១ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំធ្លាប់មើលការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈការផ្សាយបន្តផ្ទាល់នៅតាមទូរទស្សន៍។ ខ្ញុំគាំទ្រចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានធ្វើបាបប្រជាជនខ្មែរយ៉ាងព្រៃផ្សៃ ឃោរឃៅ ដែលប្រជាជនមិនដែលបានជួបប្រទះពីមុនមក។ ការកាត់ទោស ខៀវ សំផន គឺពិតជាត្រឹមត្រូវ។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនាពិព័រណ៍។ (ស៊ាង ចិន្តា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនាការផ្សាយបន្តផ្ទាល់ការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង ខៀវ សំផន។ (ស៊ាង ចិន្តា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ
## ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិព្រៃតាម៉ៅ

*ផេង ពង្សរ៉ាស៊ី*



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី៨ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានចុះទៅធ្វើការនៅក្នុងភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ ក្នុងគម្រោងស្តីពីប្រវត្តិសាស្ត្រគ្រួសារ។

គម្រោងនេះ រៀបចំឡើងដើម្បីពិភាក្សា និងចែករំលែករឿងរ៉ាវពីរបបខ្មែរក្រហមតាមរយៈកិច្ចសម្ភាសន៍រវាងបុគ្គលិកគម្រោង និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលសុទ្ធសឹងជា «ខ្មែរកម្ពុជាក្រោម» មានស្រុកកំណើតរស់នៅក្នុងស្រុកស្វាយទង និងស្រុកឃឺនយ៉ាវ ខេត្តមាត់ជ្រូក ប្រទេសវៀតណាម។

ជាលទ្ធផលនៃការអនុវត្តគម្រោង ក្រុមការងារបានសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់។ តាមរយៈការសម្ភាសន៍នេះ យើងដឹងថា អ្នករស់រានមានជីវិតទាំងអស់មានបទពិសោធន៍ត្រឹមតែរយៈខ្លីប៉ុណ្ណោះគឺនៅក្នុងឆ្នាំ១៩៧៨ ឆ្លងកាត់របបខ្មែរក្រហម។ ទោះបីជាអ្នកទាំងនោះមានសាច់

រឿងស្រដៀងគ្នាយ៉ាងណាក៏ដោយ ក៏សាច់រឿងរបស់មនុស្សម្នាក់ៗគឺមានភាពខុសគ្នាដូចជា ការភ័យខ្លាច ការខ្លាចខ្មែរក្រហមសម្លាប់ ការចូលធ្វើជាទាហានខ្មែរក្រហម និងការហូបចុកមិនគ្រប់គ្រាន់។



សិស្សសាលាចេញពីរៀន។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះរបស់ប្រជាជននៅក្នុងឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្មេងស្រីនៅក្នុងឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ភ្នំជិនស្ថិតនៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជន-យុវនារី១៥នាក់មកពីសហគមន៍ជនជាតិចាម
## នៅស្រុកត្បូងឃ្មុំ និង ស្រុកកំពង់សៀម ចូលរួមក្នុងវេទិកាពិភាក្សាអន្តរជំនាន់ ក្រោមប្រធានបទសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

*មីន សាណាស់*



*យុវជន-យុវនារី១៥នាក់មកពីសហគមន៍ជនជាតិចាម នៅស្រុកត្បូងឃ្មុំ និង ស្រុកកំពង់សៀម ចូលរួមក្នុងវេទិកាពិភាក្សាអន្តរជំនាន់ ក្រោមប្រធានបទសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅរសៀលថ្ងៃព្រហស្បតិ៍ ទី២២ ខែកញ្ញា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាពិភាក្សាអន្តរជំនាន់ ក្រោមប្រធានបទសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីយុវជនជនជាតិចាមមកពីស្រុកត្បូងឃ្មុំ និងស្រុកកំពង់សៀម។ វេទិកាពិភាក្សាអន្តរជំនាន់នេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីលើកកម្ពស់ការយល់ដឹងបន្ថែមលើប្រវត្តិសាស្ត្រខ្មែរក្រហម ដោយមានការចែករំលែកអំពីបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ជាការចាប់ផ្តើមកម្មវិធី ទូចវណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានសម្តែងការស្វាគមន៍ និងបានដឹកនាំយុវជនទស្សនាផ្ទាំងពិព័រណ៍នៅបរិវេណមជ្ឈមណ្ឌលខេត្តកំពង់ចាម រួមមាន ប្រវត្តិរូបមេដឹកនាំខ្មែរក្រហម ក្នុងនោះមានខៀវ សំផន ដែលតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជា ទើបនឹងប្រកាសដីកាពាក់ព័ន្ធនឹងអង្គហេតុសម្លាប់ជនជាតិចាម, ការ



យុវជនកំពុងអានឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ជម្លៀសប្រជាជនដោយបង្ខំ, ការបង្ខំឲ្យធ្វើការងារនៅតាមការដ្ឋាន និងផ្ទាំងសាច់រឿងរបស់អ្នករស់រានមានជីវិតក្នុងខេត្តកំពង់ចាម។ បន្ថែមពីលើពិព័រណ៍ យុវជនក៏ឆ្លៀតចូលអាន និងទស្សនាបន្ទប់ឯកសារខ្មែរក្រហមភូមិភាគបូព៌ាដែលផ្ទុកឯកសារជាច្រើនប្រភេទ និងរាប់សែនទំព័រ។ កម្មវិធីបន្ទាប់ គឺជាការចាក់បញ្ចាំងវីដេអូបទសម្ភាសន៍ក្នុង «គម្រោងសូត្រចាម» មានរយៈពេលប្រមាណ១០នាទី ដែលបង្ហាញពីជីវិតអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការស្តារឡើងវិញនូវជីវភាពក្នុងគ្រួសារដ្បិតភ្ជាប់ជាមួយនឹងចំណេះជំនាញតម្បាញសូត្រ បែបប្រពៃណីវប្បធម៌របស់ជនជាតិចាម ទៅកាន់យុវជនជំនាន់ក្រោយ ឲ្យបានយល់ដឹងបន្ថែម។

បន្ទាប់មកទៀត អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចែករំលែករឿងរ៉ាវជីវិតទៅកាន់យុវជនដូចខាងក្រោម ៖

«ខ្ញុំឈ្មោះ សា សាតះ អាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ មុនរបបខ្មែរក្រហម គ្រួសារខ្ញុំមានសមាជិក ១០នាក់។ ដល់របបខ្មែរក្រហមដួលរលំទៅគឺនៅសល់តែ៣នាក់ប៉ុណ្ណោះ។ ខ្ញុំមិនចាំឆ្នាំនោះទេ ដឹងតែដំបូងយោធាខ្មែរក្រហមបានយកឪពុករបស់ខ្ញុំចេញពីផ្ទះ ព្រោះឪពុកខ្ញុំជាប់ឈ្មោះជាអ្នកមានធនធានក្នុងភូមិ។ អ្នកនៅផ្ទះរបស់ខ្ញុំមិនដឹងថាយោធាយកឪពុកខ្ញុំទៅទីណាទេ គ្រាន់តែដឹងថាយោធាទាំងនោះប្រាប់ម្តាយខ្ញុំឲ្យរៀបចំវេចបាយ រួចដាក់មុខផ្ទះសម្រាប់ឲ្យឪពុកខ្ញុំហូបរាល់ថ្ងៃគឺ ព្រឹកមួយកញ្ចក់ ល្ងាចមួយកញ្ចក់ ថែមទាំងមានយោធាដើរមកយកបាយទៅឲ្យឪពុករបស់ខ្ញុំរយៈពេលមួយខែទើបយោធាទាំងនោះឈប់មកយកបាយទៀត។ ដោយសារបាត់ដំណឹងប្តីយូរពេក ម្តាយខ្ញុំក៏សួរយោធាទាំងនោះ ទើបទទួលដំណឹងថាអង្គការបញ្ជូនគាត់ឲ្យ




យុវជនជនជាតិចាមនៅស្រុកត្បូងឃ្មុំ និងស្រុកកំពង់សៀម ចូលរួមវេទិកាពិភាក្សាអន្តរជំនាន់នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ទៅធ្វើការនៅភូមិស្រែវាល ស្ថិតក្នុងស្រុកស្ទឹងត្រង់បាត់ហើយ។ ប្រសិនបើអ្នកណាចង់ទៅតាមគឺអាចទៅបាន អង្គការអនុញ្ញាតឲ្យទៅរស់នៅជុំគ្នា។ ម្តាយខ្ញុំក៏សម្រេចចិត្តនាំកូនចៅទៅរស់នៅតាមប្តីនៅភូមិស្រែវាល។ យើងរស់នៅស្រែវាលបានមួយរយៈ ភាពអត់ឃ្លានក៏ចូលមក។ បន្ទាប់មកអង្គការបានចាត់តាំងគ្រួសារខ្ញុំឲ្យទៅធ្វើស្រែនៅតំបន់ស្ទឹងជីនិតដែលជាតំបន់គ្រុនចាញ់។ យើងរស់នៅស្ទឹងជីនិតមិនទាន់ទាំងបានប្រមូលផលស្រូវផង យើងចាប់ផ្តើមឈឺគ្រុនចាញ់គ្រប់គ្នា។ ឪពុកខ្ញុំស្លាប់មុនគេ ក្រោយមកបងប្អូន និងក្មួយប្រុសខ្ញុំ។ ក្នុងរយៈពេល៣ខែប៉ុណ្ណោះ គ្រួសារខ្ញុំស្លាប់ស្ទើរគ្មានសល់ សូម្បីតែការបញ្ចុះសពក៏មិនបានត្រឹមត្រូវតាមប្រពៃណីសាសនាដែរ។ ការស្លាប់ប្តី និងកូនចៅ ធ្វើឲ្យម្តាយរបស់ខ្ញុំធ្លាក់ខ្លួនឈឺ។ ខ្ញុំទើបមានអាយុ១២ឆ្នាំ ត្រូវទៅរស់នៅក្នុងកងកុមារ។ ការងាររបស់ខ្ញុំគឺត្រូវចាំដេញចាបដែលចុះមកស៊ីស្រូវ និងធ្វើការងារផ្សេងទៀតតាមតែអង្គការបញ្ជា។

រឿងរ៉ាវរបស់ សាគះ ធ្វើឲ្យយុវជនស្តាប់យ៉ាងយកចិត្តទុកដាក់ ហើយលើកជាសំណួរ ដែលបង្កើតជាកិច្ចពិភាក្សាគ្នានៅក្នុងថ្នាក់។

បន្ទាប់មក យុវសិស្ស រ៉ាន់ រ៉ូស៊ីណា អាយុ១៩ឆ្នាំ ជានិស្សិតឆ្នាំទី២ នៃសាកលវិទ្យាល័យខេត្តកំពង់ចាម ជំនាញផ្នែកពេទ្យធ្មេញ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា «ខ្ញុំមិនបានដឹងពីមុនមកទេ នូវសុខទុក្ខរបស់អ៊ំពូមីងដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ មុននេះខ្ញុំស្តាប់ហើយ ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ ព្រោះស្មានមិនដល់ថាការរស់នៅក្នុងរបបខ្មែរក្រហមលំបាកខ្លាំង សូម្បីតែអាហារក៏មិនបានហូបគ្រប់គ្រាន់ដែរ។ នេះគឺជាលើកទីមួយសម្រាប់ខ្ញុំ ដែលបានចូលរួមស្តាប់សាច់រឿងផ្ទាល់ពីជនរងគ្រោះក្នុងរបបខ្មែរក្រហម ព្រោះម្តាយឪពុករបស់ខ្ញុំកើតមិនទាន់របបខ្មែរក្រហមទេ។ ខ្ញុំធ្លាប់បានរៀនមេរៀនខ្មែរក្រហមនៅក្នុងសាលាតាមឯកសារតែមួយមុខ គឺខ្ញុំយល់មិនច្បាស់ដូចបានស្តាប់សាក្សីរស់ផ្ទាល់ដូចពេលនេះទេ។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់។ ចំណុចដែលធ្វើខ្ញុំរន្ធត់ខ្លាំងជាងគេ គឺការសម្លាប់មនុស្សដោយគ្មានចិត្តអាណិតអាសូរ ការជម្លៀសមនុស្សពីកន្លែងមួយទៅកន្លែងមួយទៀត ការបង្អត់អាហារ ហើយបង្ខំគាត់ឲ្យធ្វើការធ្ងន់ៗ ទាំងគាត់នៅវ័យក្មេង។ បើប្រៀបធៀបជាមួយនឹងក្មេងសព្វថ្ងៃគឺធ្វើមិនបានទេ។



យុវជនកំពុងទស្សនាវីដេអូឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )




យុវជនទស្សនារូបបថតនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនឹងយកចំណេះដឹងទាំងនេះ ទៅចែករំលែកដល់សិស្សានុសិស្ស មិត្តភក្តិ និងប្អូនៗដែលស្នាក់នៅសមាគមន៍ជាមួយគ្នាឲ្យគាត់មានមោនកភាពជាមួយការរស់នៅសព្វថ្ងៃ ព្រោះចាស់ៗពីមុនរស់នៅលំបាកខ្លាំងណាស់។ ជាចុងក្រោយ ខ្ញុំពិតជាអរគុណដល់ថ្នាក់ដឹកនាំដែលចេះរិះរកវិធីជួយសង្គ្រោះប្រជាជនខ្មែរយើងឲ្យផុតពីរបបខ្មែរក្រហម និងរស់នៅបានសុខសន្តិភាព មកដល់សព្វថ្ងៃ»។

ចំណែកយុវសិស្ស អ៊ី ស្រីណា អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១០ នៃវិទ្យាសម្តេចម៉ែ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា «វេទិកានេះបានផ្តល់ចំណេះដឹងច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំបានអាន និងស្តាប់បទបង្ហាញទាក់ទងផ្ទាំងពិព័រណ៍ថ្នាក់ដឹកនាំខ្មែរក្រហមបន្ទប់តម្កល់ឯកសារខ្មែរក្រហមជាពិសេសបានស្តាប់ការចែករំលែករឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ទាល់។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញទេ។ ពេលខ្ញុំត្រឡប់ទៅវិញ ខ្ញុំនឹងយកអ្វីដែលខ្ញុំបានដឹងនៅថ្ងៃនេះទៅប្រាប់ម្តាយខ្ញុំមុនគេ ព្រោះម្តាយខ្ញុំក៏ជាអ្នកកើតក្រោយរបបខ្មែរក្រហមដែរ។ ជាចុងក្រោយ ខ្ញុំពិតជាអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមដែលបានអនុញ្ញាតឲ្យខ្ញុំបានចូលរួមវេទិកាក្នុងថ្ងៃនេះ»។

ជាចុងក្រោយគឺយុវជន ម៉ាត់ ណាវី អាយុ២៦ឆ្នាំ មកពីភូមិទួលពន្លៃ ឃុំជីរោទ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ណាវី រៀបរាប់ថា «ខ្ញុំធ្លាប់បានស្តាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហមពីចាស់ៗនៅក្នុងភូមិកន្លងមកដែរ ជាពិសេសគឺម្តាយរបស់ខ្ញុំតែងតែនិយាយពីភាពលំបាករបស់គាត់ក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំមិនសូវយកចិត្តទុកដាក់ទេ។ ថ្ងៃនេះខ្ញុំមានអារម្មណ៍រំភើបដែលបានចូលរួមជាមួយមិត្តភក្តិដទៃទៀត ព្រមទាំងបានស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំបានដឹងកាន់តែច្បាស់ពីអ្វីដែលបានកើតឡើងចំពោះម្តាយឪពុករបស់ខ្ញុំ។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញទេ។ វេទិកានេះផ្តល់ឱកាសឲ្យខ្ញុំស្តាប់រឿងរ៉ាវរបស់ចាស់ៗ ហើយខ្ញុំនឹងចែករំលែកសាច់រឿងរបស់គាត់ទៅមិត្តភក្តិដែលមិនបានមកចូលរួមនៅថ្ងៃនេះ។




អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចូលរួមវេទិកាអន្តរជំនាន់នៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនមកពីស្រុកបាធាយ ខេត្តកំពង់ចាម

## ចូលរួមវេទិកាអន្តរជំនាន់ចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍

*ទូច វណ្ណាត*



*យុវជនកំពុងមើលផ្ទាំងពិព័រណ៍រូបថតនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។*
*( លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា )*

យុវជនចំនួន៣៥នាក់មកពីស្រុកបាធាយ ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃអាទិត្យទី១៧ ខែកញ្ញា ឆ្នាំ២០២២នេះ។ ទស្សនកិច្ចសិក្សានេះប្រព្រឹត្តទៅឡើងគឺដើម្បីទទួលបានការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) តាមរយៈ៖ ការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការទស្សនាពិព័រណ៍ ការចាក់បញ្ចាំងវីដេអូឯកសារ ការជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការចុះទស្សនកិច្ចទៅកាន់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍។

ជាកិច្ចចាប់ផ្តើម ទូច វណ្ណាត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលស្វាគមន៍និងដឹកនាំយុវជនទស្សនាផ្ទាំងពិព័រណ៍ធំៗពីប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋាន និងពិព័រណ៍រូបភាពអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតនៅក្នុងខេត្តកំពង់ចាម។ បន្ទាប់ពីការដើរទស្សនាពិព័រណ៍ យុវជនទាំងអស់បានទៅមើលបន្ទប់ឯកសារខ្មែរក្រហមដែលផ្ទុកឯកសាររាប់

យុវជនកំពុងមើលការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»។ (លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា)





យុវជនកំពុងមើលផ្ទាំងពិព័រណ៍រូបថតនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា)

សែនទំព័រ។ ជាកិច្ចបន្ត យុវជនត្រូវបាននាំទៅកាន់សាលពិព័រណ៍ដើម្បីទស្សនាវីដេអូរឯកសារដែលមានចំណងជើងថា «កុំស្មានបងភ្លេច» ដែលមានរយៈពេលជិត២ម៉ោង។ វីដេអូឯកសារនេះដែលឆ្លុះបញ្ចាំងអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។

បន្ទាប់ពីការចាក់បញ្ចាំងវីដេអូឯកសារនេះបានបញ្ចប់ សឹង ណាំ អតីតយុទ្ធជនខ្មែរក្រហម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រំឭកអំពីបទពិសោធន៍របស់ខ្លួនមុនពេល និងក្នុងរបបខ្មែរក្រហមទៅកាន់យុវជនដែលបានចូលរួម។ ណាំបានរៀបរាប់ថា «នៅពេលដែលខ្ញុំឃើញក្មួយៗទាំងអស់គ្នាកំពុងអង្គុយនៅទីនេះ ខ្ញុំនឹកឃើញអំពីការរត់គេចពីសង្គ្រាមនៅដើមទសវត្សរ៍ទី៧០ និងការតាមចាប់ខ្លួននិងសម្លាប់ក្នុងរបបខ្មែរក្រហម។ យុវវ័យរបស់ខ្ញុំគឺស្ថិតនៅក្នុងពេលដែលប្រទេសជាតិកើតមានសង្គ្រាម។ ខ្ញុំពិតជាចង់រៀនសូត្រឲ្យបានខ្ពង់ខ្ពស់ណាស់ ប៉ុន្តែខ្ញុំមិនអាចទៀតឡើយ។ ខ្ញុំចាប់ផ្តើមរត់ចេញពីផ្ទះ នៅពេលដែលសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង គឺបន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ជីវិតរបស់ខ្ញុំនៅពេលនោះគឺពោរពេញទៅដោយការរត់ភៀសខ្លួន ការចូលប្រយុទ្ធក្នុងសមរភូមិ ការតាមចាប់សម្លាប់របស់កងទ័ពខ្មែរក្រហមកពីភូមិភាគនិរតី និងការរស់នៅក្នុងភាពភ័យខ្លាច»។ បន្ទាប់ពី សឹង ណាំ បញ្ចប់ការចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម យុវជនបានចោទសួរសំណួរផ្តោតទៅលើការរស់នៅ ការរៀបការ និងមូលហេតុនៃការតាមចាប់ខ្លួន នៅក្នុងរបបខ្មែរក្រហម។

កម្មវិធីបន្ត គឺដំណើរទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ ដែលស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ តុង សុភា ដែលជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប ដឹកនាំនិងបង្ហាញយុវជនទាំងអស់អំពីការរំឭកដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម នៅចេតិយរំឭកសម្រាប់សហគមន៍។ តុង សុភា បាននិយាយថា «នៅភូមិចំការសាមសិប ខ្មែរក្រហមបានសម្លាប់ប្រជាជននៅវាលស្រែ ឡដុតថ្នាំជក់ និងមន្ទីរសន្តិសុខគគរ ដែលស្ថិតនៅក្នុងវត្តគគរ»។ សុភា បានរំឭកអំពីការបាត់បង់ឪពុករបស់ខ្លួននៅពេលនោះដែរ។



យុវជនទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលទស្សនាវដ្ដីស្វែងរកការពិត។
( លី ដេវីដ / មជ្ឈមណ្ឌលឯកសារកម្ពុជា )

ម៉ន ស្រីពេជ្រ កំពុងរៀនថ្នាក់ទី១២គ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កើប យល់ថា «ការចូលរួមវេទិកាអន្តរជំនាន់ចុងសប្ដាហ៍រៀបចំនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនេះបានធ្វើឲ្យខ្ញុំ និងមិត្តភ័ក្តិទទួលបានចំណេះដឹងបន្ថែម ទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ( ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ) ។ ខ្ញុំមើលវីដេអូឯកសារ និងស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានឆ្លងកាត់ការលំបាកវេទនាយ៉ាងខ្លាំងនៅពេលនោះ»។

សុខ ម៉េងហ៊ាង កំពុងរៀនថ្នាក់ទី១២គ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កើប បង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំពេញចិត្តចំពោះដំណើរទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ខ្ញុំយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរ នៅសម័យប៉ុល ពត ដែលប្រជាជនខ្មែរស្លូតត្រង់ទទួលរងការធ្វើទារុណកម្ម និងការកាប់សម្លាប់។ បន្ថែមលើនេះទៀត ខ្ញុំទទួលបានឱកាសស្ដាប់បទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំពិតជាអាណិតអាសូរដល់គាត់»។

ពេញ អ៊ីណា កំពុងរៀនថ្នាក់ទី១២គ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កើប លើកឡើងថា «វេទិកាអន្តរជំនាន់ចុងសប្ដាហ៍គឺល្អសម្រាប់ខ្ញុំ និងមិត្តផ្សេងទៀតដែលរៀនថ្នាក់ទី១២ និងត្រៀមប្រឡង ពីព្រោះយើងទទួលបានចំណេះដឹងបន្ថែមពីរបបខ្មែរក្រហមនេះ»។

ឡី មករា កំពុងរៀនថ្នាក់ទី១២គ មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កើប បង្ហាញទស្សនយល់ឃើញថា «ការទស្សនាវីដេអូឯកសារ ការស្ដាប់សាច់រឿងរបស់អ៊ំៗដែលរួចផុតជីវិតពីរបបខ្មែរក្រហម និងការចុះទៅដល់ទីតាំងចេតិយរំឭកដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម បានធ្វើឲ្យខ្ញុំយល់ដឹងអំពីសោកនាកម្មបន្សល់ទុកដោយរបបខ្មែរក្រហម និងសារសំខាន់នៃការដឹងអំពីបទពិសោធន៍ជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការចងចាំជនរងគ្រោះដែលបានស្លាប់នៅពេលនោះ»។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅខេត្តត្បូងឃ្មុំទៅពិនិត្យសុខភាព

ឈុំ រ៉ា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់ មកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្មៗ (ឈុំ រ៉ា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីដើមខែកញ្ញា ឆ្នាំ២០២២ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន១០នាក់ រួមមាន៖ ១) ឈ្មោះ ជាង អ៊ឹម ភេទប្រុស អាយុ៦១ឆ្នាំ ២) ឈ្មោះ ពេជ្រ សំបូរ ភេទប្រុស អាយុ៦៣ឆ្នាំ ៣) ទុំ សាគុំ ភេទស្រី អាយុ ៥៧ឆ្នាំ ៤) ឈ្មោះ ម៉ឹក លិ្អតភេទប្រុស អាយុ ៥៩ឆ្នាំ ៥) ឈ្មោះ ស៊ិន់ ហឿន ភេទស្រី អាយុ៥៩ឆ្នាំ ៦) ឈ្មោះមួក រឿន ភេទប្រុស អាយុ៥៦ឆ្នាំ ៧) ឈ្មោះ លន់ សាវិន ភេទស្រី អាយុ៦៩ឆ្នាំ ៨) ឈ្មោះ ធឹម ម៉ៅ ភេទស្រី អាយុ៥៨ឆ្នាំ ៩) ឈ្មោះ ណន សាវី ភេទប្រុស អាយុ៥៥ឆ្នាំ និង ១០) ឈ្មោះ យុត ហេង ភេទស្រី អាយុ៥៥ឆ្នាំ បានទាក់ទងមកបុគ្គលិក និងអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីជួយសម្របសម្រួលជូនទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យឯកជនដៃគូររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ស្ថិតនៅក្នុងខេត្តត្បូងឃ្មុំៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង១០នាក់ខាងលើ គឺជាអ្នកដែលបានចែករំលែករឿងរ៉ាវជីវិតនៅក្នុងរបបខ្មែរក្រហម ដល់អ្នកស្ម័គ្រចិត្តកម្ពុជា និងបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដើម្បី

ពិភាក្សាពីការថែទាំសុខភាព និងការបង្កើតសៀវភៅណែនាំសុខភាពមួយដើម្បីជួយសម្រួលដល់ការថែទាំសុខភាពដោយខ្លួនឯង ទាក់ទងនឹងជំងឺសំខាន់ៗចំនួន១០ប្រភេទ ដែលសុទ្ធសឹងជាប្រភេទជំងឺដែលកំពុងកើតមានទៅលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុច្រើននាពេលបច្ចុប្បន្ននេះ។

នៅព្រឹកថ្ងៃសុក្រ ទី០៩ ខែកញ្ញា ឆ្នាំ២០២២ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង១០នាក់ខាងលើបានមកជួបជុំគ្នានៅមជ្ឈមណ្ឌលឯកសារកោះថ្មប្រចាំខេត្តត្បូងឃ្មុំ ដើម្បីពិភាក្សាគ្នាមុនពេលទៅពិនិត្យសុខភាព។ ឈុំ វ៉ា បុគ្គលិកប្រចាំនៅមជ្ឈមណ្ឌលឯកសារកោះថ្មបានផ្តល់ព័ត៌មានជូន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា ចំពោះការចំណាយលើការពិនិត្យសុខភាព និងព្យាបាល គឺការទទួលខុសត្រូវរបស់ពួកគាត់រៀងៗខ្លួន។ ចំណែកមជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់ជូនពួកគាត់ចំពោះថ្លៃអាហារហូបចុក និងការចំណាយលើការធ្វើដំណើរ។ ក្រោយពីបានជួបប្រជុំរួច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង១០នាក់ បានធ្វើដំណើរទៅកាន់បន្ទប់ពិគ្រោះ និងព្យាបាលជំងឺរបស់វេជ្ជបណ្ឌិត តាំង ស៊ីមាន ដែលជាមន្ទីរពេទ្យឯកជនដៃគូរបស់មជ្ឈមណ្ឌលឯកសារកោះថ្មមួយ ស្ថិតនៅក្នុងភូមិក្តុលក្រោម ឃុំទន្លូង ស្រុលមេមត់ ខេត្តត្បូងឃ្មុំ។ អ្នករស់រានពីរបបខ្មែរក្រហមបានចូលពិនិត្យសុខភាពចាប់តាំងពីម៉ោង៧:៣០នាទីព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ទើបចប់សព្វគ្រប់។ លោកវេជ្ជបណ្ឌិត តាំង ស៊ីមាន បានចេញវេជ្ជបញ្ជា និងប្រាប់អំពីស្ថានភាពជំងឺរបស់អ្នករស់រានពីរបបខ្មែរក្រហមទាំង១០នាក់។ មុនពេលត្រឡប់ទៅផ្ទះរៀងៗខ្លួន លោកវេជ្ជបណ្ឌិតក៏បានណែនាំឲ្យពួកគាត់អនុវត្តតាមវេជ្ជបញ្ជា ថែទាំសុខភាពឲ្យបានខ្ជាប់ខ្ជួន និងត្រូវមកពិនិត្យសុខភាពឲ្យបានទៀងទាត់យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

ខាងក្រោមនេះជាចំណាប់អារម្មណ៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ខ្ញុំឈ្មោះ ជាង អ៊ឹម ភេទប្រុស អាយុ៦១ឆ្នាំ សព្វថ្ងៃ



បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម កំពុងប្រជុំជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម។
(វី ស៊ីថា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



គ្រូពេទ្យកំពុងពិនិត្យជំងឺជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

មានទីលំនៅ ស្ថិតនៅភូមិកោះថ្ម ឃុំទន្ទង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ នៅពេលក្មួយៗជាអ្នកស្ម័គ្រចិត្តរបស់មណ្ឌលឯកសារកោះថ្មចុះមកសួរសុខទុក្ខខ្ញុំ ដែលជាអ្នកធ្លាប់បានឆ្លងកាត់សម័យសង្គ្រាម និងជាអ្នកនៅរស់ពីសម័យខ្មែរក្រហម ធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយរីករាយ។ នៅពេលខ្ញុំប្រាប់រឿងរ៉ាវដែលខ្ញុំឆ្លងកាត់នោះធ្វើឲ្យខ្ញុំធូរស្បើយនៅក្នុងចិត្ត ។ ម្យ៉ាងទៀតរឿងរ៉ាវដែលខ្ញុំធ្លាប់បានឆ្លងកាត់ក្នុងសម័យនោះហាក់ដូចជានៅថ្មីៗសម្រាប់ខ្ញុំ។ នៅពេលដែលបានឮថាក្មួយៗ នឹងយកទៅធ្វើជាឯកសារ ទុកឲ្យក្មេងជំនាន់ក្រោយបានសិក្សារៀនសូត្រទៀតខ្ញុំពិតជាត្រេកអរ។ ក្មួយៗក៏បានសួរនាំខ្ញុំអំពីសុខទុក្ខ អំពីសុខភាពក៏ដូចជាស្ថានភាពនៃការរស់នៅរបស់ខ្ញុំទៀតធ្វើឲ្យខ្ញុំកាន់តែរីករាយ។ មជ្ឈមណ្ឌលឯកសារកោះថ្មបានគិតគូដល់សុខភាពរបស់ខ្ញុំក៏ដូចជាអ្នកដែលនៅរស់ពីសម័យខ្មែរក្រហម។ ខ្ញុំពិតជាមានអារម្មណ៍ត្រេកអរដែលមជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់ជាកញ្ចប់អនុស្សាវរីយ៍ និងផ្តល់មធ្យោបាយដល់ខ្ញុំដើម្បីមានលទ្ធភាពទៅពិនិត្យសុខភាព។ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ខ្ញុំបានទៅចូលរួមក្នុងកម្មវិធីនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខ្ញុំមានអារម្មណ៍ថាសប្បាយរីករាយ ដោយសារតែពេលទៅដល់មានការសម្របសម្រួលបានល្អ មានការពន្យល់ពីរបៀបដោះស្រាយពីបញ្ហាផ្លូវចិត្តក៏ដូចជាអារម្មណ៍ ត្រូវធ្វើបែបណាដើម្បីធ្វើឲ្យអារម្មណ៍ស្ងប់។ ម្យ៉ាងទៀតមានការពន្យល់ពីអាការជំងឺដល់ខ្ញុំដើម្បីឲ្យខ្ញុំដឹងថាខ្លួនថាមានអាការបែបណាហើយត្រូវហ្នឹងជំងឺអ្វី។ បន្ទាប់ពីចប់កម្មវិធីមជ្ឈមណ្ឌលឯកសារកោះថ្មក៏មានជាកញ្ចប់អនុស្សាវរីយ៍ដល់ខ្ញុំថែមទៀត។ នៅក្នុងសារមន្ទីរមជ្ឈមណ្ឌលឯកសារកោះថ្មមានការរៀបចំតុបតែងបានស្អាត និងមានរូបភាពមើលទៅដូចយើងនៅក្នុងសម័យសង្គ្រាម។

ខ្ញុំឈ្មោះ លន់ សារីន ភេទស្រី មានអាយុ ៦៩ឆ្នាំ បច្ចុប្បន្នមានទីលំនៅ ស្ថិតនៅភូមិកោះថ្ម ឃុំទន្ទង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ នៅពេលដែលអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានចុះទៅជួបខ្ញុំសួរនាំអំពីរឿងរ៉ាវជីវិត ដែលធ្លាប់ឆ្លងកាត់ពី



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងរង់ចាំពិនិត្យសុខភាពនៅបន្ទប់ពិគ្រោះ និងព្យាបាលជំងឺ។
( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងអង្គុយរង់ចាំពិនិត្យសុខភាពនៅមុខបន្ទប់ពិគ្រោះ និង ព្យាបាលជំងឺ។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




បន្ទប់ពិគ្រោះនិងព្យាបាលជំងឺ ។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម័យសង្គ្រាម និងបានសួរនាំពីបញ្ហាសុខភាព ស្ថានភាពនៃការរស់នៅតាំងពីតូចរហូតមកដល់ពេលបច្ចុប្បន្ន ខ្ញុំមានអារម្មណ៍ថាបានធូរស្រាលក្នុងចិត្ត ពីព្រោះខ្ញុំមិនធ្លាប់និយាយរឿងរ៉ាវជីវិត ដែលធ្លាប់ជួបប្រទះនៅក្នុងសម័យសង្គ្រាមនោះទៅប្រាប់នរណាម្នាក់ទេ។ នៅពេលខ្ញុំនិយាយប្រាប់អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកោះថ្មរួច ខ្ញុំមានអារម្មណ៍ថារីករាយ ពីព្រោះក្មេងៗ ជំនាន់ក្រោយបានដឹង និងបានសិក្សារៀនសូត្រ។ ខ្ញុំមិនចង់ឲ្យមានសង្គ្រាមម្តងទៀតទេ។ ក្រោយពីខ្ញុំបានចែករំលែករឿងរ៉ាវជីវិតរួចមក ធ្វើឲ្យអារម្មណ៍និងចិត្តរបស់ខ្ញុំបានស្ងប់ និងបានដឹងអំពីបញ្ហាសុខភាព។ ជាចុងក្រោយ ខ្ញុំពិតជាអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់កញ្ចប់អនុស្សាវរីយ៍ និងផ្តល់មធ្យោបាយដល់ខ្ញុំក៏ដូចជាអ្នករស់រានមានជីវិតផ្សេងទៀតបានទៅពិនិត្យសុខភាព។ ខ្ញុំសូមជូនពរមជ្ឈមណ្ឌលឯកសារកោះថ្មជួបប្រទះតែពុទ្ធពរទាំង ឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

ខ្ញុំឈ្មោះ ពេជ្រ សំបូរ ភេទប្រុស អាយុ ៦៣ឆ្នាំ រស់នៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំពិតជាត្រេកអរដែលឃើញអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកោះថ្មចុះមកសួរនាំរឿងរ៉ាវអំពីសម័យ ប៉ុល ពត។ នៅពេលដែលអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកោះថ្មចុះមកសួរនាំរឿងនេះ ហាក់ធ្វើឲ្យខ្ញុំនឹកឃើញនូវហេតុការណ៍ដែលបានកើតឡើងក្នុងរបបនេះ មានពេលខ្លះខ្ញុំក៏ធ្លាប់បាននិយាយរឿងរ៉ាវដែលកើតឡើងក្នុងសម័យខ្មែរក្រហមឲ្យកូនចៅស្តាប់ថាជំនាន់ឪពុកមិនស្រួលដូចកូនៗរាល់ថ្ងៃនេះទេ សូម្បីតែបាយមិនបានហូបគ្រាប់គ្រាន់ និងមានយោធាខ្មែរក្រហមមកចាប់មនុស្សយកទៅសម្លាប់ថែមទៀត។ ខ្ញុំនិយាយប្រាប់ទៅកូនចៅ តែកូនចៅមិនជឿ និងបាននិយាយថាគ្មានអ្នកណាចាប់មនុស្សយកទៅសម្លាប់ស្រួលៗទេ។ ចំពោះបញ្ហាសុខភាព រាល់ថ្ងៃខ្ញុំខស្សាហ៍ឈឺសន្លាក់ដៃ ជើង ហើយពេលយប់ដេកមិនសូវលក់។ ក្រោយពេលដែលខ្ញុំទទួលបានការពិនិត្យសុខភាពរួចមកគ្រូពេទ្យបានប្រាប់មកខ្ញុំវិញថា ជាតិស្ករឡើងខ្ពស់រហូត៣២០ អាចបណ្តាលឲ្យមានជំងឺទឹកនោមផ្អែម។ ជាចុងក្រោយ ខ្ញុំពិតជាអគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានផ្តល់កញ្ចប់អនុស្សាវរីយ៍ និងមធ្យោបាយដល់ខ្ញុំ និងអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមផ្សេងទៀតបានទៅពិនិត្យសុខភាព។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១នាក់ មកពីស្រុកកំពង់សៀមទទួលការពិនិត្យសុខភាពដោយឥតគិតថ្លៃ

**ទូច វណ្ណេត**



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម មកពិនិត្យសុខភាព ដោយមិនគិតថ្លៃ។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយ ទូច វណ្ណេត និងអេង វណ្ណីកា ទទួលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១១នាក់ មកពីស្រុកកំពង់សៀម ដើម្បីទទួលការពិនិត្យសុខភាពនៅគ្លីនិកឯកជនៗ កន្លងមក អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានចូលរួមវេទិកាអភិវឌ្ឍសារសុខភាព និងការផ្សាយផ្ទាល់ស្តីពីការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង ខៀវ សំផនរបស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខាងក្រោមនេះ គឺជាទស្សនយល់ឃើញរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បន្ទាប់ពីទទួលបានការពិនិត្យសុខភាពរបស់ខ្លួន៖

អ៊ុំស្រី តៅ វត្ថា អាយុ៧០ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំ



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីស្រុកកំពង់សៀម មកចូលរួមស្តាប់និងទស្សនាការផ្សាយបន្តផ្ទាល់ការប្រកាសសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹង ខៀវ សំផនរបស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម កាលពីវេលាម៉ោង៩:៣០នាទីព្រឹក ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

គគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាននិយាយថា «នៅពេលដែលក្មួយៗដែលជាអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះមកសួរសុខទុក្ខខ្ញុំដែលជាអ្នកធ្លាប់បានឆ្លងកាត់សង្រ្គាម និងរបបខ្មែរក្រហម។ ខ្ញុំពិតជាទទួលបានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំង ពីព្រោះរបបនោះគឺមានការលំបាកយ៉ាងខ្លាំង។ ក្មួយៗមកសួរនាំដំណើរជីវិតខ្ញុំ។ ខ្ញុំរៀបរាប់ពីបទពិសោធន៍ដែលខ្ញុំបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ដែលបានធ្វើឲ្យខ្ញុំធូរស្បើយនៅក្នុងចិត្ត។ រឿងរ៉ាវដែលខ្ញុំឆ្លងកាត់ក្នុងសម័យខ្មែរក្រហម គឺហាក់ដូចជានៅថ្មីៗសម្រាប់ខ្ញុំ។ នៅពេលដែលខ្ញុំឮថាក្មួយៗសួរនាំរឿងរ៉ាវរបស់ខ្ញុំដើម្បីយកទៅចងក្រងធ្វើជាឯកសារ ទុកឲ្យក្មេងជំនាន់ក្រោយសិក្សារៀនសូត្រ ខ្ញុំពិតជាមានអារម្មណ៍ត្រេកអរ។ ក្មួយៗសួរនាំអំពីសុខទុក្ខ ស្ថានភាពសុខភាព និងការរស់នៅរបស់ខ្ញុំទៀត គឺធ្វើឲ្យខ្ញុំកាន់តែរីករាយថែមទៀត។ បន្ថែមលើនេះទៀត ខ្ញុំមានអារម្មណ៍ថាមានការយកចិត្តទុកដាក់ទៅលើបទពិសោធន៍ជីវិតនិងសុខភាពរបស់ខ្ញុំ»។

អ៊ុំស្រី តុង ស៊ីថាត អាយុ៦៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចែករំលែកថា «ខ្ញុំធ្លាប់និយាយអំពីបទពិសោធន៍ជីវិតខ្ញុំប្រាប់ក្មួយៗដែលជាអ្នកស្ម័គ្រចិត្ត។ ខ្ញុំមានអារម្មណ៍ធូរស្បើយនៅពេលនោះ។ នៅពេលដែលក្មួយៗអ្នកស្ម័គ្រចិត្តប្រាប់ថា ខ្ញុំអាចទទួលបានការពិនិត្យសុខភាព ខ្ញុំកាន់តែសប្បាយចិត្ត។ ខ្ញុំធ្លាប់ចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ វេទិកាអភិវឌ្ឍសារសុខភាព និងការផ្សាយផ្ទាល់ស្តីពីការប្រកាសសាលដីកាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន រៀបចំនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ នៅថ្ងៃនេះ ខ្ញុំទទួលបានឱកាសដើម្បីពិនិត្យសុខភាព ដោយសារតែខ្ញុំចង់

ដឹងអំពីស្ថានភាពរបស់ខ្ញុំ។ បច្ចុប្បន្ននេះ ខ្ញុំតែងតែឈឺក្បាល និងឈឺតាមសន្លាក់ជើង។ ខ្ញុំសូមជូនពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងបុគ្គលិកទាំងអស់ជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ»។

អ៊ុំស្រី ជុំ សុខហេង អាយុ៦៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម រៀបរាប់ថា «ថ្មីៗនេះ ខ្ញុំចូលរួមស្ដាប់ការប្រកាសសាលដីការបស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាត់ក្ដីរឿង ខៀវ សំផន និងវេទិកាអភិវឌ្ឍសារសុខភាពរបស់គម្រោងប្រវត្តិសាស្ត្រគ្រួសារ និងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលដែលមានអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះមកជួបខ្ញុំនៅផ្ទះដើម្បីសួរសុខទុក្ខ និងបទពិសោធន៍ជីវិតរបស់ខ្ញុំក្នុងសង្គ្រាម និងរបបខ្មែរក្រហម ខ្ញុំទទួលអារម្មណ៍ធូរស្រាលក្នុងចិត្ត ពីព្រោះខ្ញុំមិនដែលបាននិយាយចែករំលែករឿងរ៉ាវខ្ញុំឆ្លងកាត់នោះឡើយ។ នៅថ្ងៃនេះ ខ្ញុំទើបតែបានទៅពិនិត្យសុខភាព និងដឹងពីស្ថានភាពសុខភាពខ្លួនឯង ដែលចុះខ្សោយទៅៗ»។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម មកពិនិត្យសុខភាព ដោយមិនគិតថ្លៃ។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# នៅសល់តែប្រវត្តិរូបនិងរូបថត



កាន់ វ៉ាត គឺជាឪពុករបស់ កាន់ សុទ្ធាវ៉ា។ (កាន់ សុទ្ធាវ៉ា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)




រូបថត អោម យិនដូនី នៅមន្ទីរសន្តិសុខស-២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់បានចាកចេញពីស្រុកកំណើតនៅភូមិក្រាំងចេក ព្រោះសម័យមុនមានក្រុមខ្មែរឥស្សរៈដើរចាប់មនុស្សប្រុសឲ្យចូលធ្វើទាហាន ចំណែករដ្ឋការបារាំងក៏តាមចាប់គាត់ដែរដោយសង្ស័យថា គាត់ចូលដៃជើងជាមួយក្រុមខ្មែរឥស្សរៈ។ មនុស្សប្រុសក្នុងភូមិដែលមានប្រពន្ធកូន និងមិនចង់ចូលធ្វើទាហានក៏បានចាកចេញពីភូមិកំណើត។ ឪពុកម្តាយនិងបងៗរបស់ខ្ញុំបានមករស់នៅជិតវត្តមហាមន្ត្រី ក្នុងទីក្រុងភ្នំពេញ ដោយមានការជួយទំនុកបម្រុងពីបងប្អូនខាងឪពុករបស់ខ្ញុំធ្វើជាកុងស៊ីយ៍នៅសម័យនោះ។ ឪពុករបស់ខ្ញុំឈ្មោះ កាន់ វ៉ាត និងម្តាយរបស់ខ្ញុំឈ្មោះ ឆេង ផុន។ ចំណែកខ្ញុំឈ្មោះ កាន់ សុទ្ធាវ៉ា បច្ចុប្បន្នមានអាយុ៧០ឆ្នាំ កើតនៅទីក្រុងភ្នំពេញ រីឯបងប្រុសរបស់ខ្ញុំឈ្មោះ ដឹម ឡាង និងបងស្រីឈ្មោះ កាន់ សុខា ហៅ ស្ងួន សុភាព កើតនៅភូមិក្រាំងចេក ឃុំក្រាំងចេក ស្រុកខដុង្គ ខេត្តកំពង់ស្ពឺ។

បងប្រុសរបស់ខ្ញុំមានអាយុបងខ្ញុំ១០ឆ្នាំ និងបងស្រីអាយុបងខ្ញុំ៧ឆ្នាំ នៅពេលនោះ។ឪពុករបស់ខ្ញុំស្រឡាញ់បង ឡាង ខ្លាំងណាស់ដោយសារគាត់គឺជាកូនច្បង ហើយរៀនពូកែតាំងពីតូចៗ គ្រូតែងតែឲ្យបង ឡាង រៀនឆ្លោះថ្នាក់រហូត។ ខ្ញុំចាំរូបរាងបងប្រុសរបស់ខ្ញុំដែលមានច្រមុះស្រួច ហើយនិយាយម៉ឺងម៉ាត់។ ឪពុកខ្ញុំតែងតែផ្គត់ផ្គង់សម្ភារឲ្យបង ឡាង រៀនមិនឲ្យខ្វះខាតឡើយ។ ខ្ញុំចាំកាលនោះផ្ទះរបស់ខ្ញុំធំទូលាយ ហើយ បង ឡាង តែងហៅមិត្តភក្តិរបស់គាត់មករៀនបន្ថែមនៅផ្ទះ។ មិត្តភក្តិបង ឡាង ច្រើននាក់សុទ្ធតែប្រុសៗ។ តុអង្គុយរបស់បង ឡាង មួយគឺឪពុករបស់ខ្ញុំកុម្ម៉ង់ជាងឲ្យធ្វើដោយអាចបញ្ឈរធ្វើជាក្តារខៀនក៏បាន ឬធ្វើជាតុសម្រាប់សរសេរក៏បាន។ ក្រោយមកបង ឡាងចូលរៀនផ្នែកវិស្វករអគ្គិសនីនៅសាលាពហុបច្ចេកវិទ្យាជំនាន់ទី១ ហៅកាត់សាលាតិចណូ។

បន្ទាប់មកបង ឡាងបានរៀបការជាមួយប្រពន្ធរបស់គាត់ឈ្មោះ អោម យិនដូនី។ បងប្រុសរបស់ខ្ញុំរៀបការអស់រយៈពេល១០ឆ្នាំប៉ុន្តែគាត់មិនមានកូនឡើយ។ បង ឡាង ចេញធ្វើការដំបូងនៅសូនិចស៊ីមគឺជាក្រុមហ៊ុននាំផលិតផលពីបរទេសចូលមកតាមកប៉ាល់ និងដឹកបន្តមកដែនៅទីក្រុងភ្នំពេញ។ ដូច្នេះនៅផ្ទះរបស់បង ឡាង មានរបស់របរប្រើប្រាស់ដូចជាម៉ាស៊ីនបោកខោអាវទោះបីវាមានតម្លៃថ្លៃក៏ដោយ។ មិនយូរប៉ុន្មានបង ឡាង បានផ្លាស់ទៅធ្វើការផ្នែកអគ្គិសនីតាមជំនាញរបស់គាត់។

ក្រោយមកបងស្រីរបស់ខ្ញុំ កាន់ សុខា ក៏រៀបការទៀត ដោយប្តីរបស់គាត់គឺជាសាស្ត្រាចារ្យផ្នែកគណិតវិទ្យា និងរូបវិទ្យា។ បងថ្លៃរបស់ខ្ញុំតែងតែប្រាប់ម្តាយរបស់ខ្ញុំឲ្យលក់សម្ភារប្រើប្រាស់និងចានល្អៗដើម្បីយកប្រាក់ចាយ ព្រោះសភាពការណ៍ក្នុងប្រទេសមិនស្រួល ប៉ុន្តែម្តាយរបស់ខ្ញុំមិនជឿបងថ្លៃខ្ញុំទេ។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានរៀបការ។ ដំបូងប្តីរបស់ខ្ញុំគឺជាអ្នករកស៊ីក្រោយមកគាត់ចូលធ្វើការផ្នែកហិរញ្ញវត្ថុក្នុងជួរទាហានប៉ុន្តែគាត់ធ្វើបានរយៈពេលខ្លីប៉ុណ្ណោះ។

# ថ្ងៃជម្លៀសដំបូង

នៅមុនពេលចូលឆ្នាំខ្មែរ ក្នុងឆ្នាំ១៩៧៥ បង ឡាង និងប្រពន្ធរបស់គាត់ត្រូវទៅប្រទេសបារាំង ប៉ុន្តែគាត់បានពន្យារពេលរង់ចាំចូលឆ្នាំខ្មែររួចសិន។ បង ឡាង មកជប់លៀងនៅផ្ទះរបស់ខ្ញុំ ហើយយកខោអាវរបស់គាត់មកគរទុកនៅផ្ទះរបស់ខ្ញុំទៀត។ ខ្ញុំបានខោអាវ បង ឡាង ស្លៀកពាក់នៅក្នុងរបបខ្មែរក្រហម ព្រោះខ្ញុំមិនបានរៀបខោអាវខ្លួនឯងយកមកជាមួយ។ នៅមុនពេលខ្មែរក្រហមចូលមកម្តាយរបស់ខ្ញុំបានសុបិនឃើញក្រពើក្រៀមស្រកា ហើយមានបាយជាប់នៅមាត់ក្រពើមួយគ្រាប់ៗ និងឃើញពស់ក្បាលពីរលូនកាត់មុខគាត់ទៅបាត់។ បន្ទាប់ពីសុបិននោះ ម្តាយរបស់ខ្ញុំតែងតែខ្វល់ក្នុងចិត្តរហូត និងនឹកគិតថានឹងមានរឿងអ្វីកើតឡើង។

នៅថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលមកប្រាប់ខ្ញុំឲ្យចាកចេញពីផ្ទះ ហើយពេលនោះខ្ញុំគិតតែយំ ព្រោះប្តីរបស់ខ្ញុំទៅលេងឪពុកម្តាយរបស់គាត់ ចំណែកឪពុករបស់ខ្ញុំទៅលេងបងប្អូនរបស់គាត់ដែរ។ ខ្ញុំមិនទាន់ចាកចេញភ្លាមៗទេ គឺនៅរង់ចាំប្តីរបស់ខ្ញុំទល់ល្ងាចទើបគាត់ត្រឡប់មកដល់ផ្ទះ។ បន្ទាប់មកយើងធ្វើដំណើរចេញពីផ្ទះនៅម្តុំផ្សារដើមអំពិល ជិតអូរ ឡាំពិក ដែលមានគ្រួសារបងស្រីរបស់ខ្ញុំ និងគ្រួសារខ្ញុំ។ ចំណែកឪពុករបស់ខ្ញុំយើងមិនបានជួបគាត់ទេ។ យើងមានកូនឡានមួយសម្រាប់ដឹកអង្ករខ្លះដើម្បីទុកដាំបាយហូបតាមផ្លូវ និងដឹកក្មេងៗ ព្រោះកូនរបស់បងស្រីខ្ញុំ៣នាក់ និងកូនរបស់ខ្ញុំម្នាក់នៅតូចៗពិបាកដើរ។ ខ្ញុំកាច់ចង្កូតឡាន ហើយបងៗនិងប្តីរបស់ខ្ញុំរុញពីក្រោយ។ នៅពេលទៅដល់ផ្លូវទូលាយ ទើបយើងបញ្ឆេះម៉ាស៊ីនឡានបើកយឺតៗ។ យើងធ្វើដំណើរដល់ក្បាលថ្នល់ក៏ជាប់ទ្រឹង។ នៅក្បែរនោះ ខ្ញុំឃើញមានឃ្លាំងអង្ករ គ្រាប់សណ្តែកស្ករ ទឹកដោះគោ និងឃ្លាំងមី ដូច្នេះប្រជាជនបាននាំគ្នាឈប់រួចហើយចូលទៅយកម្ហូបអាហារទាំងនោះទុកហូប។ យើងអង្គុយរង់ចាំអស់រយៈពេល២ទៅ៣ថ្ងៃ ទើបអាច



ជឹម ឡាង និង ភរិយា អោម យិនដូនី នៅផ្ទះរបស់ខ្លួននៅទួលគោក ក្នុងឆ្នាំ១៩៧៤ មុនពេលរបបខ្មែរក្រហមចូលកាន់អំណាច។
( កាន់ សុន្ទរ៉ា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

ចេញផុតពីក្បាលថ្នល់។ ចំណែកបង ឡាង ចាកចេញពីផ្ទះនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥។ ខ្ញុំបានដឹងព័ត៌មានរបស់ បង ឡាង បន្ថែមទៀត តាមរយៈមិត្តភក្តិរបស់គាត់ប្រាប់ថា បង ឡាង ធ្វើដំណើរដល់កោះក្របីត្រូវអង្គការឃាត់ និងឆែកប្រវត្តិរូបរបស់គាត់។ អង្គការឃើញប័ណ្ណសម្គាល់ខ្លួនរបស់បង ឡាង ធ្វើការនៅអគ្គិសនីវិត្តភ្នំ ក៏ហៅគាត់ចូលមកភ្នំពេញធ្វើការវិញ។ បង ឡាង គិតថា គាត់បានចូលធ្វើការវិញ ក៏នាំក្មួយពីរនាក់គឺស្រីម្នាក់និងប្រុសម្នាក់ដែលជាសាច់ញាតិខាងប្រពន្ធទៅជាមួយដែរ។

នៅតាមផ្លូវកូនរបស់ខ្ញុំនិងក្មួយៗដែលនិយាយមិនទាន់ច្បាស់តែងតែរំអុកថា «ម៉ែទៅផ្ទះយើងវិញ»។ ក្មួយស្រីរបស់ខ្ញុំដែលធ្លាប់តែដេកជាមួយឪពុករបស់ខ្ញុំ តែងតែសួរម្ដាយរបស់ខ្ញុំថា «ណាលោកតា?»។ ពេលឮដូច្នេះម្ដាយខ្ញុំយំ ហើយជារឿយៗក្មួយនិងកូនរបស់ខ្ញុំតែងតែសួររកអ្នកនេះសួររកអ្នកនោះមិនចេះចប់។

# នៅសិត្បូ

អង្គការជម្លៀសគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្ដាល។ កន្លែងនោះមានដើមទឹកដោះគោធំមួយដើមនៅខាងមុខផ្ទះ ហើយអង្គការហាមមិនឲ្យបេះផ្លែទឹកដោះគោជាដាច់ខាត។ នៅពេលយប់ប្ដីរបស់ខ្ញុំលួចឡើងប្របាច់ផ្លែទឹកដោះគោរកផ្លែណាដែលទុំលួចបេះមកឲ្យខ្ញុំនិងកូនហូប។ កូនស្រីរបស់ខ្ញុំអាយុប្រាំឆ្នាំ ចេះហូបផ្លែទឹកដោះគោក្នុងមុងយ៉ាងស្ងៀមស្ងាត់។ នៅថ្ងៃបន្ទាប់ អង្គការចាត់តាំងខ្ញុំឲ្យទៅស្ទូង ច្រូតស្រូវ កាប់ព្រៃ។ ដំបូងការងារអ្វីក៏ខ្ញុំមិនចេះធ្វើដែរ។ ក្រោយមក អង្គការវាស់ដីព្រៃប្រវែង៥ម៉ែត្រឲ្យខ្ញុំកាប់ឆ្ការ។ ខ្ញុំកាប់ឆ្ការយឺតជាងគេ ដូច្នេះម្ដាយរបស់ខ្ញុំបានលួចជួយកាប់ឆ្ការព្រៃឲ្យខ្ញុំរហូត។ ខ្ញុំស្ទូងមិនទាន់មេកងឈរសម្លឹងមុខខ្ញុំ។ លើសពីនោះកងស្ទូងជាមួយគ្នា បានស្ទូងបិទពីក្រោយខ្ញុំរកផ្លូវដើរចេញមិនរួច។ នៅពេលច្រូតស្រូវម្ដងៗ ក៏ខ្ញុំច្រូតយឺតជាងគេដែរ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៥ ខ្ញុំឆ្លងទន្លេបានកូនប្រុសម្នាក់ទៀត។ កាលនោះមានឆ្មបក្មេងៗ អាយុប្រមាណជាង១០ឆ្នាំជួយបង្កើតកូនឲ្យខ្ញុំ។ ពេលកូនរបស់ខ្ញុំអាយុបាន១០ខែ អង្គការបានចាត់តាំងខ្ញុំឲ្យចូលធ្វើការងារវិញ។ កូនរបស់ខ្ញុំនៅបៅដោះនៅឡើយ ដូច្នេះខ្ញុំមានអង្រឹងមួយចងឲ្យកូនខ្ញុំដេកនៅព្រៃជិតកន្លែងខ្ញុំធ្វើការ ពេលកូនខ្ញុំឃ្លានទើបខ្ញុំឡើងមកឲ្យកូនបៅ ចំណែកកូនស្រីរបស់ខ្ញុំឲ្យយាយៗមើលថែទាំ។ ខ្ញុំរែកដីបោចស្មៅលើកភ្លឺ និងកាស់គល់ឈើ។ រាល់ថ្ងៃខ្ញុំធ្វើការត្រាំនៅក្នុងទឹក ព្រោះនៅសិត្បូគឺជាស្រុកទន្លេធ្វើឲ្យខ្ញុំកើតបន្ទាលត្រអាក និងរមាស់ ប៉ុន្តែមេកងមិនឲ្យខ្ញុំដើរចេញពីទឹកទេ ទាល់តែដល់ម៉ោងទើបខ្ញុំអាចឡើងគោកបាន។ ខ្ញុំឈរហាលថ្ងៃទើបបាត់រមាស់។ នៅទីនោះខ្ញុំឈឺគ្រុនចាញ់ជាច្រើនលើក គឺឲ្យតែដល់ពេលរសៀលខ្ញុំចាប់ផ្ដើមញាក់។ ដូច្នេះមុនពេលថ្ងៃរសៀល ខ្ញុំដាក់ដាំបាយរួចហើយឲ្យកូនស្រីរបស់ខ្ញុំនៅចាំមើលភ្លើង។ ដល់ពេលបាយពុះកូនស្រីរបស់ខ្ញុំក៏រត់មកប្រាប់ខ្ញុំ។ ខ្ញុំបានបង្រៀនកូនស្រីខ្ញុំពីរបៀបដាំបាយដោយឲ្យគាត់បើកគម្របឆ្នាំងនៅពេលទឹកបាយពុះ ហើយពេលរីងទឹកខ្ញុំឲ្យគាត់គ្របវិញ។

ល្ងាចមួយក្នុងឆ្នាំ១៩៧៦ ពេលខ្ញុំចេញពីធ្វើការនៅកងចល័ត ខ្ញុំមកទាន់កូនរបស់ខ្ញុំនិងមិត្តភក្តិកូនរបស់ខ្ញុំដែលមានអាយុប្រមាណ៥ឆ្នាំស្របាលគ្នា កំពុងអង្គុយដុតខ្យងដែលនៅរស់យកសំបកចេញ និងយកសាច់ខ្យងដាក់ចូលក្នុងមាត់។ ឃើញដូច្នេះ ខ្ញុំក៏ស្ទុះទៅវាយកូនរបស់ខ្ញុំមួយដៃឲ្យទម្លាក់ខ្យងចុះវិញ។ រឿងនេះធ្វើឲ្យខ្ញុំសោកស្ដាយ និងអាណិតកូនដែលស្រេកឃ្លាន។



កាន់ សុន្ទរ៉ា ថតនៅវត្តបរទុមពេលមករៀនវគ្គបណ្ដុះបណ្ដាលគ្រូអនុវិទ្យាល័យនៅអំឡុងឆ្នាំ១៩៨១-១៩៨២។ (កាន់ សុន្ទរ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆ្នាំដែលសោកសៅ


ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

១- ឈ្មោះដើម

- ឈ្មោះក្លែង

២- អាយុ ឆ្នាំ ជនជាតិ ខ្មែរ ភេទ ស្រី

៣- ទីលំនៅកំណើតនៅភូមិ

ឃុំ ស្រុក ខេត្ត

៤- ក្រសួងមុខរបរ មុនថ្ងៃរំដោះភ្នំពេញ (១៧មេសា ១៩៧៥)

៥- ក្រសួងមុខរបរ បច្ចុប្បន្ន

៦- ឪពុកឈ្មោះ ម្ដាយឈ្មោះ

៧- ប្រពន្ធ ឬ ប្ដី ឈ្មោះដើម ឈ្មោះក្លែង

៨- ទីលំនៅកំណើតនៅភូមិ ឃុំ

ស្រុក ខេត្ត

៩- បច្ចុប្បន្ន នៅ

១០- មានកូនប្រុសចំនួន នាក់ កូនស្រី នាក់

១១- ទីកន្លែងចាប់ខ្លួន

១២- ចាប់ខ្លួនថ្ងៃទី ខែ ឆ្នាំ ១៩៧៦ វេលា

ប្រវត្តិរូប អោម យិនដូនី នៅមន្ទីរសន្តិសុខស-២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៧ កូនស្រីរបស់ខ្ញុំឈ្មោះ ថាវី ឈឺរាកមូល កូនប្រុសខ្ញុំក៏ឈឺ ចំណែកក្មួយស្រីរបស់ខ្ញុំក៏ឈឺហើមទៀត។ ខ្ញុំគឺជាអ្នកនៅមើលថែទាំពួកគេ។ ពេលកូនស្រីរបស់ខ្ញុំរាកដំបូង ខ្ញុំស្នើសុំអង្គការនាំគាត់ទៅព្យាបាលនៅពេទ្យដោយសារយើងមិនមានថ្នាំឲ្យគាត់លេប។ អង្គការមិនឲ្យយកកូនខ្ញុំទៅពេទ្យភ្លាមទេ រហូតកូនខ្ញុំរាកមូលចេញឈាមទើបអង្គការអនុញ្ញាត។ ខ្ញុំយកកូនទៅព្យាបាលនៅពេទ្យឃុំ ពេទ្យឃុំមើលមិនជាទើបខ្ញុំយកកូនទៅព្យាបាលនៅពេទ្យស្រុកស្អាង។ កូនរបស់ខ្ញុំឈប់រាក ប៉ុន្តែនៅហើម ដូច្នេះពេទ្យប្រាប់ខ្ញុំឲ្យទៅរកស្ករឲ្យកូន ហូប ដូច្នេះខ្ញុំក៏ទៅសុំស្ករពីខាងពេងបាយ។ ពេលនោះខ្ញុំមិនដឹងវិធីព្យាបាលរាកមូលដោយត្រូវយកស្ករទៅកូរឲ្យឆ្អិន (ឡើងតាំងម៉ែ) សិនទើបឲ្យអ្នកជំងឺហូបទេ គឺខ្ញុំឲ្យកូនហូបស្ករឆៅ ទើបធ្វើឲ្យកូនខ្ញុំហូបរួចហើយ លាប់រាកវិញ។

នៅពេលនោះអ្នកស្គាល់ខ្ញុំបានឲ្យផ្លែល្ហុងមក ដូច្នេះខ្ញុំក៏យកល្ហុងមកជ្រក់ជាមួយអំបិល ហើយទុកនៅចុងជើងក្អួយ។ ចំណែកកូនប្រុសរបស់ខ្ញុំទើបតែអាយុ២ឆ្នាំ យំឲ្យខ្ញុំបីវាចេញមកក្រៅ ស្រាប់តែក្មួយរបស់ខ្ញុំឈ្មោះ មុំ លួចហូបជ្រក់ល្ហុងធ្វើឲ្យវាឈឺលាប់មើលមិនជា។ នៅពេលនោះបងស្រីរបស់ខ្ញុំបានទៅលេងកូនស្រីរបស់គាត់ (ក្មួយរបស់ខ្ញុំ) នៅមន្ទីរពេទ្យដែរ។ ក្មួយរបស់ខ្ញុំបានប្រាប់បងស្រីរបស់ខ្ញុំថា «ម៉ាក់មិននៅមើលកូន ឲ្យតែម៉ាក់មីងនៅមើល ម៉ាក់មីងមិនមើលមុំទេ មើលតែកូនរបស់គាត់»។ ពេលឮដូច្នេះបងស្រីរបស់ខ្ញុំហាក់ដូចជាអន់ចិត្តជាមួយខ្ញុំដែរ។ ក្រោយមកកូនរបស់ខ្ញុំពីរនាក់ និងកូនបងស្រីរបស់ខ្ញុំម្នាក់ទៀតបានស្លាប់ទាំងអស់។ ចំណែកម្ដាយខ្ញុំឈឺហើម និងរាកមូល ហើយត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យចំថ្ងៃដែលចៅស្លាប់ដែរ។ ម្ដាយរបស់ខ្ញុំមិនទាន់ដឹងថាចៅៗស្លាប់ទេ។ ខ្ញុំបានទៅជួយបោកសារុងឲ្យម្ដាយរបស់ខ្ញុំ។ ក្រោយមកទើបម្ដាយខ្ញុំដឹងថា ចៅស្លាប់ហើយគាត់យំយ៉ាងខ្លាំង។ គាត់ប្រាប់ខ្ញុំថា ម៉ាក់ប្រហែលជាទៅតាមចៅហើយ។ ម្ដាយរបស់ខ្ញុំបានពោតស្ងោរមួយផ្លែពីអ្នកជិតខាងឲ្យមកគាត់។ គាត់ហូបពោតនោះក៏លាប់ជំងឺរាកមូលវិញ។ ខ្ញុំមិនអាចសុំអង្គការនៅមើលថែម្ដាយរបស់ខ្ញុំបានយូរទេ ព្រោះអង្គការថាខ្ញុំមិនមែនជាពេទ្យ។ ក្រោយមកម្ដាយរបស់ខ្ញុំបានស្លាប់។ ខ្ញុំស្នើសុំអង្គការមកមើលមុខម្ដាយខ្ញុំចុងក្រោយ ប៉ុន្តែអង្គការមិនឲ្យខ្ញុំមក ថែមទាំងនិយាយថាមកធ្វើអីបើស្លាប់ហើយ។

# ជីវិតឯកោ



កាន់ សុន្ធរ៉ា (រូបខាងឆ្វេង) នៅវត្តបទុមវត្តីពេលរៀនវគ្គបណ្តុះបណ្តាលគ្រូអនុវិទ្យាល័យ នៅអំឡុងឆ្នាំ ១៩៨១-១៩៨២។ (កាន់ សុន្ធរ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំលែងមានកូនទៀតហើយ អង្គការយកខ្ញុំទៅដាក់ក្រុមកម្លាំងស្រួចធ្វើស្រែមួយ ហិកតាមនុស្សចំនួន២០នាក់។ ខ្ញុំហាក់ដូចជាសាំនឹងការងារប្រូតស្ទូង លើកទំនប់ និងវែកដីប្រណាំងប្រជែងគ្នា។ បងស្រីរបស់ខ្ញុំត្រូវបានអង្គការចាត់ទៅកងមនុស្សចាស់ធ្វើការជិតៗផ្ទះ។ ចំណែកខ្ញុំទៅធ្វើការនៅឆ្ងាយផ្ទះពិតមែន ប៉ុន្តែខ្ញុំមានសំណាងធ្វើការនៅចម្ការអំពៅ ចម្ការពោត អាចលួចយកមកផ្ញើអ្នកផ្ទះខ្លះ។ ពេលចប់ពីការងារ មេកងឲ្យខ្ញុំទូលស្មៅមួយពំនូកត្រឡប់មកវិញ ដូច្នេះខ្ញុំយកអំពៅដែលកណ្តុរកកេរយកមកហូប និងយកអំពៅខ្លះលាក់ក្នុងពំនូកស្មៅ ទុកផ្ញើអ្នកផ្ទះ។ ខ្ញុំមិនយកអំពៅល្អៗរបស់អង្គការទេ ចំណែកពោតក៏ខ្ញុំយកតែផ្លែតូចៗដែលអង្គការទុកចោល ព្រោះពេលឈ្លបខ្មែរក្រហមចាប់យើងបាន គឺមិនសូវយកទោសពៃរ៍យើងទេ។

ថ្ងៃមួយ ខ្ញុំទៅងូតទឹកនៅមាត់ទន្លេនៅពេលយប់ស្រាប់តែខ្ញុំឃើញត្រីមួយកញ្ច្រែងដែលគេធ្វើរួច និងលាងស្អាតទុកនៅទីនោះ។ ខ្ញុំមិនឃើញមនុស្សនៅក្បែរត្រីនោះឡើយ ដូច្នេះខ្ញុំក៏លួចយកត្រីមួយក្បាលលាក់ទុកក្នុងចង្កេះខោ។ បន្តិចក្រោយមក ខ្ញុំឮខ្មែរក្រហមជជែកគ្នា អើផ្អែអូសត្រីមួយទៅបាត់ហើយ។ ខ្ញុំអរខ្លាំងណាស់ពេលបានឮខ្មែរក្រហមនិយាយថាឆ្កែអូសត្រីទៅបាត់ដោយមិនសង្ស័យមានអ្នកលួច។ ខ្ញុំយកត្រីនោះមកស្ងោរដាក់អំបិលតិចៗ។ ខ្ញុំហូបត្រីនោះឆ្ងាញ់ខ្លាំងណាស់ ទោះបីមិនមានបាយហូបជាមួយក៏ដោយ។

ខ្ញុំធ្វើការនៅសិត្បូបានរយៈពេល ១ឆ្នាំជាងអង្គការបានផ្លាស់ប្តូរទីកន្លែងខ្ញុំ។ អង្គការឲ្យខ្ញុំដើរពីសិត្បូ ទៅកោះទឹកវិល។ ខ្ញុំឃើញសុទ្ធតែស្រីៗ និងក្មេងៗរស់នៅទីនោះ។ អង្គការឲ្យខ្ញុំឃ្វាលគោនៅទឹកវិល។ ខ្ញុំមិនដែលឃ្វាលគោពីមុនមកទេ ហើយក៏មិនចំណាំគោដែរ។ ខ្ញុំយកគោទៅចងនៅក្រោមដើមឈើ ហើយវង្វេងកន្លែងចងគោទៀត។ ខ្ញុំរកគោមិនឃើញ

ក៏ភិតភ័យខ្លាំងណាស់។ សំណាងល្អពេលល្ងាចគោបម្រះរួចពីចំណងហើយរត់ចូលក្រោលដោយខ្លួនឯង។ ខ្មែរក្រហមលត់ដៃខ្ញុំគ្រប់សព្វបែបយ៉ាង។ ថ្ងៃមួយពេលខ្ញុំកំពុងជម្រះស្មៅនៅក្នុងចម្ការ ប្រធានកងហៅប្រជាជនមកតម្រង់ជួរ។ បងស្រីរបស់ខ្ញុំមកមិនទាន់បានចូលជួរយើត ដូច្នេះខ្ញុំថយក្រោយដើម្បីឲ្យបងស្រីរបស់ខ្ញុំឈរពីមុខខ្ញុំ។ ប្រធានកងរាប់ពីលេខរៀងទី១ដល់៥០ក៏ឈប់ ហើយឲ្យអ្នកទាំងនោះទៅផ្ទះរៀបចំអីវ៉ាន់ទាំងយប់ ប៉ុន្តែមិនបានប្រាប់ថាទៅទីណាឡើយ។ ខ្មែរក្រហមនាំយើងមកស្ទឹងសៀមរាបកន្ទួត។ ខ្មែរក្រហមរៀបចំបាយឲ្យយើងហូបមួយចម្អែតទាំងយប់ ហើយថ្ងៃបន្ទាប់ខ្មែរក្រហមចាត់តាំងយើងទាំង៥០នាក់ឲ្យជួយប្រូតស្រូវបន្ទាន់។ ពេលនោះមនុស្សពាក់កណ្ដាលឈឺក្រពះ ដោយសារយើងមិនដែលបានហូបបាយឆ្អែតជាយូរមកហើយ។ ខ្ញុំក៏ឈឺរាករូសដែរ ចំណែកបងស្រីរបស់ខ្ញុំបានចេញទៅធ្វើការធម្មតា។ ពេលប្រូតស្រូវហើយរួចរាល់ ខ្ញុំបានត្រឡប់ទៅនៅត្រើយខាងលិចទន្លេ គឺនៅព្រែករាំង ក្នុងស្រុកស្អាង ខេត្តកណ្ដាល រហូតដល់កងទ័ពវៀតណាមវាយចូលមកនៅដើមឆ្នាំ១៩៧៩។

## សាងជីវិតថ្មី

ក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ ខ្ញុំមករស់នៅឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺវិញ។ ខ្ញុំបានចូលធ្វើជាគ្រូបង្រៀន។ ដំបូងខ្ញុំបង្រៀនសិស្សក្រោមម្លប់ឈើព្រោះយើងមិនទាន់មានសាលារៀន។ ក្រៅពីធ្វើជាគ្រូបង្រៀន ខ្ញុំប្រកបរបរចិញ្ចឹមជ្រូក ប៉ុន្តែជ្រូកក៏ងាប់អស់។ ពេលនោះខ្ញុំមានកង់មួយ ដូច្នេះខ្ញុំបានជិះកង់ដើររកស៊ីទិញស្រូវយកមកស្តុកទុកដើម្បីលក់ ប៉ុន្តែខ្ញុំខាតដោយសារខ្ញុំទុកស្រូវចំកន្លែងដែលមានទឹកស្រក់ពីលើបណ្ដាលឲ្យស្រូវដុះ។ បន្ទាប់មកខ្ញុំដើរទិញស្ករត្នោតទុកលក់ ប៉ុន្តែស្ករចុះថោកទៀត។




កាន់ សុន្ទរ៉ា ផ្ដល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅកាត់សាលាក្ដីខ្មែរក្រហម។ (កាន់ សុន្ទរ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៨៤ ខ្ញុំឡើងមករៀននៅសាលាគរុកោសល្យនៅភ្នំពេញ ផ្នែកគីមីវិទ្យា។ ពេលនោះ ខ្ញុំនឹកឃើញបង ឡាង ដែលអង្គការហៅឲ្យទៅធ្វើការវិញ ដែលខ្ញុំតែងតែសង្ឃឹមថាគាត់នៅរស់។ ប៉ុន្តែក្តីសង្ឃឹមនេះបានរលត់ទៅវិញ នៅពេលខ្ញុំរកឃើញឯកសារចម្លើយសារភាពរបស់ បង ឡាង ចុះកាលបរិច្ឆេទថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៥ រក្សាទុកនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍សាសន៍ទួលស្លែង។ នៅក្នុងឯកសារនេះក៏បានបញ្ជាក់អំពីកូនរបស់បង ឡាងពីរនាក់ ដែលបង ឡាង នាំយកទៅជាមួយគាត់ដែរ ហើយក្រោយមកអង្គការយកកុមារទាំងពីរនាក់នោះទៅដាក់នៅមន្ទីរកុមារចម្ការដូង។ ក្រោយមកខ្ញុំរកឃើញរូបថតនិងឯកសាររបស់បងថ្លៃខ្ញុំចុះលេខ ០៩៥៨១ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឈ្មោះ អោម យិនដូនី (ត្រូវជាប្រពន្ធរបស់បង ឡាង) ដែលត្រូវបានឃាត់ខ្លួននៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ទៀត។ ខ្ញុំបានបាត់បង់ឪពុកម្តាយ បងបង្កើតបងថ្លៃកូនក្មួយជាទីស្រឡាញ់។ នៅក្នុងឆ្នាំ ២០០៧ ខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនសមាជិកគ្រួសាររបស់ខ្ញុំ។ កន្លងមក សាលាក្តីខ្មែរក្រហមបានកាត់ទោសឲ្យមេដឹកនាំខ្មែរក្រហមជាប់គុកអស់មួយជីវិតធ្វើឲ្យខ្ញុំស្ងប់ចិត្តបានខ្លះ។

ខ្ញុំចូលនិវត្តន៍ពីគ្រូបង្រៀនរយៈពេល១០ឆ្នាំមកហើយ ប៉ុន្តែខ្ញុំសប្បាយចិត្តពេលឃើញសិស្សជាច្រើនដែលខ្ញុំធ្លាប់បានបង្រៀនមានការងារធ្វើ ចំណែកកូនៗរបស់ខ្ញុំខិតខំប្រឹងប្រែងរៀនសូត្រ កសាងគ្រួសារនិងអាចរស់នៅដោយខ្លួនឯងបាន។ ឆ្លៀតពេលទំនេរពីការងារ ខ្ញុំទៅវត្តធ្វើបុណ្យស្តាប់ព្រះធម៌ ។ បច្ចុប្បន្ន ខ្ញុំរស់នៅឃុំសុព័រទេព សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**ជារ៉ារដ្ឋ មេត្តា**


KO8129
TSL 1158
មន្ទីរ ស ២១
សេចក្តីរាយការណ៍
អំពីការពិតរបស់ឈ្មោះ : ជឹម ឡាង

ចម្លើយសារភាពរបស់ ជឹម ឡាង នៅមន្ទីរសន្តិសុខស-២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិយាដ» (ត)

## អ្នកភូមិព្រៃក្រឡាញ់ធំចិត្តធម៌ ករងចល័តកុមារ (ត)

...ពេលថ្ងៃបរក្របីទៅចាំនៅវាលបឹងទ្រាំង ខាងលិចភូមិព្រៃក្រឡាញ់ធំ។ មកដល់វាលប្រធានក្រុមកុមារគេបែងចែកឲ្យកុមារខ្លះនៅចាំក្របី ឯខ្លះទៀតដើររកត្រី ឬចាប់សត្វកណ្ដុរសម្រាប់ធ្វើអាហារ។

មកពីវាលឃ្វាលក្របីវិញ កុមារទាំងអស់បានជួបជុំគ្នានៅរោងបាយ។ មិត្តកុមារខ្លះដើរបេះស្លឹកគ្រៃ ឬបេះស្លឹកក្រូចសើចយកមកឆាជាមួយសាច់កណ្ដុរ ដើម្បីធ្វើម្ហូបបន្ថែមលើម្ហូបរបបដែលអង្គការរៀបចំ ដោយមានសហការជ្រោមជ្រែងពីមេចុងភៅរោងបាយមិនមានការរើសអើងឡើយ។

ខ្ញុំស្នាក់នៅភូមិព្រៃក្រឡាញ់ធំប្រហែលពីរបីខែ គេចាត់តាំងឲ្យកុមាររួមទាំងខ្ញុំផងមកកាប់ព្រៃនៅទួលចុងប្រាសាទ ភូមិជ្រៃ នៅក្នុងនោះមានកុមារម្នាក់ឈ្មោះជុំ ដែលស្រឡាញ់និងតែងតែបង្រៀនខ្ញុំឲ្យចេះធ្វើការ។ ប្រហែលបួនប្រាំថ្ងៃគេឲ្យត្រឡប់ទៅភូមិព្រៃក្រឡាញ់ធំវិញ។



រូបភាពបច្ចុប្បន្នឆ្នាំ២០២០៖ សាលាបឋមសិក្សាព្រៃក្រឡាញ់។ (ឡុង វង្សសមិទ្ធ/ សៀវភៅទួលពិយាដ)

## ក្អែកក្លែងជាហង្ស ពួកខោអាវត្រួយចេកខ្មែរក្រហម

នៅភូមិព្រៃក្រឡាញ់ធំបានប្រហែលមួយឆ្នាំ ពួកខ្មែរក្រហមនិរតីមកកាន់កាប់នៅតំបន់បូព៌ា ដោយគេចោទពួកកងឈ្លបអាវខ្មៅបូព៌ាថា ពួកនេះសម្លុតគំរាមកំហែង និងជម្លៀសប្រជាជនចេញពីភូមិមួយទៅភូមិមួយគ្មានត្រាប្រណី។

គេបានប្រាប់ប្រជាជនអ្នកថ្មីទាំងអស់ថា "បើបងប្អូនអ្នកថ្មីណាចង់ទៅរស់នៅផ្ទះកេរដំណែលក្នុងភូមិកំណើតរបស់ខ្លួនវិញ អង្គការយើងអនុញ្ញាតឲ្យទៅនៅបានដោយមិនយកទោសពៃរ៍អ្វីទេ"។

ព្ឋដូច្នេះឪពុកម្ដាយខ្ញុំបានពិភាក្សាគ្នាជាមួយជីតាជីដូន ម៉្យាងទៀតដោយមានការនឹករឭកភូមិកំណើតរបស់ខ្លួន ហើយគិតថា របបប្រហែលមានការផ្លាស់ប្ដូរនយោបាយធូរស្រាល ក៏សម្រេចចិត្តមករស់នៅភូមិក្រាំងវិញ។

មកនៅភូមិក្រាំងមិនបានប៉ុន្មានខែផង ខ្ញុំបានឃើញពួកគេដេញបាញ់ចាប់កងឈ្លប ប្រធានភូមិ ប្រធានក្រុម ចាប់តាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់គណៈតំបន់ និងភូមិភាគ យកទៅសម្លាប់ចោល ខ្លះរត់ចូលព្រៃ ដោយចោទថា ជាពួកក្បត់នឹងអង្គការបដិវត្តន៍ ឬភាសាមួយទៀតដែលគេប្រើថា ពួកបូព៌ាក្បត់។ បន្ទាប់ពីនោះមក ពួកកងឈ្លប និងមេកងកម្មាភិបាលខ្មែរក្រហមអាវត្រួយចេកចាប់ផ្ដើមធ្វើទុក្ខបុកម្នេញដល់ប្រជាជនក្នុងឃុំព្រៃស្រឡិត និងភូមិក្រាំងទាំង

ចាស់ទាំងថ្មីមិនបន្ទូរដៃ ប្រមូលទៅសម្លាប់ស្ទើររាល់ថ្ងៃដោយចោទថាជាខ្មាំងស៊ីរូងផ្ទៃក្នុងប្រឆាំងអង្គការបដិវត្តន៍ៗ ទន្ទឹមនឹងនោះដែរ ខ្ញុំបានឃើញការចូលរួមរបស់អ្នកភូមិដែលពួកនិរតីទើបតែចាត់តាំងឲ្យធ្វើជាប្រធានឈ្លបបុគណៈពេងបាយថ្មី កាន់កាំបិតខ្វែវ ដបង ប្រនង់ជួយដេញចាប់ ឬកាប់សម្លាប់ចោលអ្នកធ្លាក់ពីតំណែងចាស់យ៉ាងស្រស់ៗនៅនឹង



ទិដ្ឋភាព៖ ពួកកងឈ្លបខោអាវត្រួយចេកចាប់អតីតប្រធានភូមិ គណៈ ក, ខ, គ របស់ខ្មែរក្រហមៗ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

ក្មេកៗ ទាំងនេះបង្ហាញពីការគុំគួនសងសឹកសម្លាប់គ្នាទៅវិញទៅមកក្រោមការជួយជ្រោមជ្រែងពន្យះលើកទឹកចិត្តពីពួកកម្មាភិបាលនិរតីថ្មីដែលមកកាន់កាប់តំបន់បូព៌ា ទោះអ្នកតំណែងចាស់ជាបងប្អូននឹងគ្នាក៏ដោយ ហើយបានសម្លាប់ពួកកម្មាភិបាលបូព៌ាស្ទើរគ្មានសល់ ដែលយើងអាចនិយាយបានថា "ទឹកឡើងត្រីស៊ីស្រមោច ដល់ទឹកហោចស្រមោចស៊ីត្រី" ជាប្រវត្តិសាស្ត្រ វប្បធម៌អាក្រក់ ដែលពួកគេបានប្រើមកលើជនជាតិឯង ដើម្បីតែអំណាចបុណ្យសក្តិស្មោកគ្រោកនេះ រហូតដល់ក្រុមគ្រួសារខ្ញុំត្រូវកងឈ្លបខ្មែរក្រហមធ្វើឃាតនៅលើទួលស្វាំងនេះ តាមការចាត់តាំងរបស់មេកងសយៗ

សម្តីពួកខោអាវត្រួយចេកហាក់ដូចជាល្អជាមួយប្រជាជនណាស់ៗ តាមពិតរូបរាងជាហង្សតែចិត្តជាក្អែកៗ មិនគួរណាយើងវិលត្រឡប់ចូលមកទំលើទ្រនំក្អែកខ្មៅសោះៗ តែអ្វីៗគ្មាននរណាទស្សទាយបានមុនឡើយ នៅក្នុងសង្គមទុច្ចរិតដ៏អប្រិយនេះៗ

ក្រោយពីគេសម្លាប់ឪពុកម្តាយខ្ញុំ បានប្រហែលប្រាំខែ កូនៗសល់ប៉ុន្មានត្រូវពួកកងឈ្លបខ្មែរក្រហមកៀរបន្តទៅទៀតដើម្បីសម្លាប់ផ្តាច់ពូជលើកចុងក្រោយលើដំណើរវិថីមរណៈគ្មានព្រំដែនៗ




(តនៅលេខក្រោយ)

ឡុង វង្សសមិទ្ធ

រូបក្របមុខ៖

ខៀវ សំផន នៅក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ខៀវ សំផន ត្រូវបានប៉ូលិសចាប់ខ្លួននៅផ្ទះរបស់គាត់នៅប៉ៃលិន រួចបញ្ជូនមកឃុំឃាំង
នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ដើម្បីកាត់ទោស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 273, September 2022 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.